បណ្ណសារដ្ឋានជាតិ
ថ្ងៃទី 25 ខែ 6 ឆ្នាំ 2003

# មាតិកា

## I- រាជរដ្ឋាភិបាល

### ១_ អនុក្រឹត្យ


| | | |
|---|---|---|
| ២៧-៣-២០០១ | - អនុក្រឹត្យលេខ ៣០ អនក្រ.បក ស្តីពីការកែសំរួលអនុក្រឹត្យលេខ ០៧ អនក្រ.បក ចុះថ្ងៃទី ២២ ខែមករា ឆ្នាំ ២០០១ ស្តីពីការលុបនាទីឡូត៍នេសាទ និងកាត់បន្ថយដែននេសាទក្នុងនាទីឡូត៍នេសាទខេត្តតាកែវ ទុកសំរាប់ប្រជាពលរដ្ឋធ្វើនេសាទ ជាលក្ខណៈគ្រួសារ | ៨៣៧ |
| ២៨-៣-២០០១ | -អនុក្រឹត្យលេខ ៣១ អនក្រ.បក ស្តីពីការបំពេញបន្ថែមគណៈកម្មាធិការតម្រង់ទិសអន្តរក្រសួង ដើម្បីដឹកនាំដំណើរការនៃគំរោងការជំនួយបច្ចេកទេស និងរៀបចំយុទ្ធសាស្ត្រពាណិជ្ជកម្មសំរាប់គាំទ្រការកាត់បន្ថយភាពក្រីក្រនៅកម្ពុជា | ៨៤០ |
| ២៨-៣-២០០១ | -អនុក្រឹត្យលេខ ៣២ អនក្រ.បក ស្តីពីការផ្ទេរឥណទានថវិកា | ៨៤២ |
| ២៦-៣-២០០១ | -អនុក្រឹត្យលេខ ១២២ អនក្រ.តត ស្តីពីការតែងតាំងមន្ត្រីរាជការ | ៨៤៤ |
| ២៧-៣-២០០១ | -អនុក្រឹត្យលេខ ១២៣ អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ | ៨៤៥ |
| ២៧-៣-២០០១ | -អនុក្រឹត្យលេខ ១២៤ អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ | ៨៤៧ |
| ២៧-៣-២០០១ | -អនុក្រឹត្យលេខ ១២៥ អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ | ៨៤៨ |
| ២៧-៣-២០០១ | -អនុក្រឹត្យលេខ ១២៦ អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ | ៨៤៩ |
| ២៧-៣-២០០១ | -អនុក្រឹត្យលេខ ១២៧ អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ | ៨៥១ |
| ២៧-៣-២០០១ | -អនុក្រឹត្យលេខ ១២៨ អនក្រ.តត ស្តីពីការជូនមេដាយការងារ | ៨៥៣ |
| ២៧-៣-២០០១ | -អនុក្រឹត្យលេខ ១២៩ អនក្រ.តត ស្តីពីការតែងតាំងមន្ត្រីរាជការ | ៨៥៦ |
| ២៧-៣-២០០១ | -អនុក្រឹត្យលេខ ១៣០ អនក្រ.តត ស្តីពីការតែងតាំងមន្ត្រីរាជការ | ៨៥៧ |
| ២៨-៣-២០០១ | -អនុក្រឹត្យលេខ ១៣១ អនក្រ.តត ស្តីពីការតែងតាំងមន្ត្រីត្រួតពិនិត្យរដ្ឋ អមធនាគារអភិវឌ្ឍន៍ជនបទ | ៨៥៨ |

គឺជាបន្ទាត់ហើយស្មោះ
ថ្ងៃទី ... ខែ ... ២០០៣



២៨-៣-២០០១ -អនុក្រឹត្យលេខ ១៣២ អនក្រ.តត ស្ដីពីការជូនមេដាយស្ថាបនាជាតិ ៨៥៩

២៨-៣-២០០១ -អនុក្រឹត្យលេខ ១៣៣ អនក្រ.តត ស្ដីពីការជូនមេដាយស្ថាបនាជាតិ ៨៦០

២៩-៣-២០០១ -អនុក្រឹត្យលេខ ១៣៤ អនក្រ.តត ស្ដីពីការជូនមេដាយការងារ ៨៦១

២៩-៣-២០០១ -អនុក្រឹត្យលេខ ១៣៥ អនក្រ.តត ស្ដីពីការជូនមេដាយស្ថាបនាជាតិ ៨៧០

២៩-៣-២០០១ -អនុក្រឹត្យលេខ ១៣៦ អនក្រ.តត ស្ដីពីការជូនមេដាយស្ថាបនាជាតិ ៨៧១

២៩-៣-២០០១ -អនុក្រឹត្យលេខ ១៣៧ អនក្រ.តត ស្ដីពីការតែងតាំងមន្ត្រីរាជការ ៨៧២

## ២-សេចក្ដីសំរេច

២៧-៣-២០០១ -សេចក្ដីសំរេចលេខ ១៤ សសរ ស្ដីពីការបង្កើតគណៈកម្មការដោះស្រាយគោលនយោបាយសំណង់ស្នាក់នៅបណ្ដោះអាសន្នក្នុងមជ្ឈមណ្ឌលកូលាបទី ១ ៨៧៣

# II- អាជ្ញាធរបណ្ដាក្រសួង

## ១-ធនាគារជាតិនៃកម្ពុជា

### ប្រកាស

៣០-៣-២០០១ -ប្រកាសលេខ ធ.៥.០១.៦៥ ប្រក ស្ដីពីការដាក់អោយប្រើប្រាស់មូលប្បទានប័ត្រគំរូថ្មី ៨៧៦

៣០-៣-២០០១ -ប្រកាសលេខ ធ.៧.០១.៦៦ ប្រក ស្ដីពីការដកហូតអាជ្ញាប័ណ្ណ និងជំរះបញ្ជីធនាគារកសិករថៃ មហាជនចំកាត់ សាខាភ្នំពេញ ៨៨០

## ២-ទីស្ដីការរដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល

### ប្រកាស

២៦-៣-២០០១ -ប្រកាសលេខ ២១២ ឧរថកឧ.ប្រក អនុញ្ញាតអោយក្រុមហ៊ុនជ្រេហ្គន វីវើរ វីសស តំណាងដោយលោក IYER SESHADRI RISHINARADA MANGALAM VENKATES WARAN សញ្ជាតិឥណ្ឌា បង្កើតរោងចក្រផលិតសង្កសី ៨៨២

គ

៣០-៣-២០០១ -ប្រកាសលេខ ២២៩ ឧរថកឧ.ប្រក ស្តីអំពីស្តង់ដារឧស្សាហកម្មកម្ពុជា CS 022-2001 គោលការណ៍ទូទៅនៃប្រព័ន្ធចេញវិញ្ញាបនប័ត្របញ្ជាក់ផលិតផលដោយភាគីទី៣ ៨៨៤

# I- រាជរដ្ឋាភិបាល

## ១-អនុក្រឹត្យ

### អនុក្រឹត្យលេខ ៣០ អនក្រ.បក

### ស្តីពីការកែសំរួលអនុក្រឹត្យលេខ ០៧ អនក្រ.បក ចុះថ្ងៃទី ២២ ខែមករា ឆ្នាំ ២០០១ ស្តីពីការលុបនាទីឡូត៍នេសាទ និងកាត់បន្ថយដែននេសាទក្នុងនាទីឡូត៍នេសាទខេត្តតាកែវ ទុកសំរាប់ប្រជាពលរដ្ឋធ្វើនេសាទជាលក្ខណៈគ្រួសារ

### រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៣ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការបង្កើតក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ
- បានឃើញក្រឹត្យច្បាប់លេខ ៣៣ ក្រច ចុះថ្ងៃទី ០៩ ខែ មីនា ឆ្នាំ ១៩៨៧ ស្តីពីការគ្រប់គ្រងវិស័យជលផល
- បានឃើញអនុក្រឹត្យលេខ ១៧ អនក្រ.បក ចុះថ្ងៃទី ០៧ ខែ មេសា ឆ្នាំ ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

### សំរេច

**មាត្រា១ .-**

ត្រូវបានកែសំរួលមាត្រា១ នៃអនុក្រឹត្យលេខ ០៧ អនក្រ.បក ចុះថ្ងៃទី ២២ ខែ មករា ឆ្នាំ ២០០១ ស្តីពីការលុបនាទីឡូត៍នេសាទ និងកាត់បន្ថយដែននេសាទ ក្នុងនាទីឡូត៍នេសាទ ខេត្តតាកែវ ទុកសំរាប់ប្រជា ពលរដ្ឋធ្វើនេសាទជាលក្ខណៈគ្រួសារ មានដូចខាងក្រោម :

**មាត្រា១ថ្មី ..**

- ត្រូវបានកែសំរួលប្រកាសលេខ ០០៤០ ប្រក.កសក ចុះថ្ងៃទី ២៤ ខែឧសភា ឆ្នាំ ១៩៨៩ របស់ក្រសួង កសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ស្តីពីការកំណត់ព្រំប្រទល់នៃនាទីឡូត៍នេសាទ និងកន្លែងនេសាទបំរុងទុកនៅ ទឹកសាបក្នុងខេត្តតាកែវ ដូចខាងក្រោម :

- លុបចេញនាទីឡូត៍នេសាទលេខ ២, ៣, ៤, ៦, ៧, ៨, ៩, ១០, ១៣, ១៧, ១៩, និងលេខ ២០ ចាប់ពីរដូវនេសាទ ឆ្នាំ ២០០១-២០០២ តទៅ ។

- កាត់ចេញពីនាទីឡូត៍នេសាទនៃផ្ទៃដែនទនេសាទក្នុងខេត្តតាកែវ និងកំណត់ព្រំប្រទល់ឡូត៍នេសាទ ជាថ្មីចាប់ពីពេលនេះតទៅ ដូចមាននៅក្នុងតារាងខាងក្រោម និងផែនទីភ្ជាប់ជាមួយ ។

**តារាងស្ថិតិផ្ទៃឡូត៍នេសាទក្នុងខេត្តតាកែវ ដែលត្រូវលុបនិងកាត់បន្ថយ**

(គិតជា ហិកតា)

| ប្រភេទ និង លេខឡូត៍ | ផ្ទៃឡូត៍ នេសាទ | ផ្ទៃឡូត៍ កាត់ចេញ | ផ្ទៃឡូត៍ នៅសល់ | ផ្ទៃឡូត៍កាត់ គិតជាភាគរយ | ផ្សេងៗ |
|---|---|---|---|---|---|
| បឹងព្រែក | | | | | |
| ១ | ២.៨៣៦ | ២៤ | ២.៨១២ | ០.៨ | |
| ២ | ១.៧៣៣ | ១.៧៣៣ | ០ | ១០០ | លុបចេញ |
| ៣ | ៩៩១ | ៩៩១ | ០ | ១០០ | លុបចេញ |
| ៤ | ២.១០៥ | ២.១០៥ | ០ | ១០០ | លុបចេញ |
| ៥ | ៣៩៤ | ០ | ៣៩៤ | ០ | |
| ៦ | ១.២២៣ | ១.២២៣ | ០ | ១០០ | លុបចេញ |
| ៧ | ១.១៤៨ | ១.១៥៨ | ០ | ១០០ | លុបចេញ |
| ៨ | ៦៣០ | ៦៣០ | ០ | ១០០ | លុបចេញ |
| ៩ | ១.២២១ | ១.២២១ | ០ | ១០០ | លុបចេញ |
| ១០ | ១.៧៦០ | ១.៧៦០ | ០ | ១០០ | លុបចេញ |

| | | | | | |
|---|---|---|---|---|---|
| ១១ | ១.៣៦៥ | ០ | ១.៣៦៥ | ០ | |
| ១២ | ៩០២ | ០ | ៩០២ | ០ | |
| ១៣ | ៣ ៩២២ | ៣.៩២២ | ០ | ១០០ | លុបចេញ |
| ១៤ | ៧.៥៧៤ | ២.៤៦១ | ៥.១១៣ | ៣២.៤៩ | |
| ១៥ | ២.៦៣៦ | ០ | ២.៦៣៦ | ០ | |
| ១៦ | ២.០៨៣ | ១.០២៣ | ១.០៦០ | ៤៩.១១ | |
| ១៧ | ១.៨៥៧ | ១.៨៥៧ | ០ | ១០០ | លុបចេញ |
| ១៨ | ៩១៩ | ០ | ៩១៩ | ០ | |
| ១៩ | ៤.០៧៥ | ៤.០៧៥ | ០ | ១០០ | លុបចេញ |
| ២០ | ៦.៦៧៣ | ៦.៦៧៣ | ០ | ១០០ | លុបចេញ |
| សរុប | ៤៦.០០៧ | ៣០.៨០៦ | ១៥.២០១ | ៦៦.៩៥ | |

**មាត្រា២ .-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ រដ្ឋមន្ត្រី ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួងស្ថាប័នដែលពាក់ព័ន្ធ និងអភិបាលខេត្តតាកែវ ត្រូវអនុវត្តអនុក្រឹត្យនេះតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ២៧ ខែ មីនា ឆ្នាំ ២០០១

**នាយករដ្ឋមន្ត្រី**

**ហត្ថលេខា និងត្រា**

**ហ៊ុន សែន**

===

# អនុក្រឹត្យលេខ ៣១ អនក្រ.បក ស្តីពីការ
# បំពេញបន្ថែមគណៈកម្មាធិការតម្រង់ទិសអន្តរក្រសួង
# ដើម្បីដឹកនាំដំណើរការនៃគំរោងការជំនួយបច្ចេកទេស
## និងរៀបចំយុទ្ធសាស្ត្រពាណិជ្ជកម្ម សំរាប់គាំទ្រការកាត់
## បន្ថយភាពក្រីក្រនៅកម្ពុជា

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញអនុក្រឹត្យលេខ ១៨ អនក្រ.បក ចុះថ្ងៃទី ១៣ ខែ មីនា ឆ្នាំ ២០០១ ស្តីពីការបង្កើតគណៈកម្មាធិការតម្រង់ទិសអន្តរក្រសួង ដើម្បីដឹកនាំដំណើរការនៃគម្រោងការជំនួយបច្ចេកទេសទាក់ទិននឹងគោលនយោបាយពាណិជ្ជកម្ម
- យោងតាមការចាំបាច់របស់រាជរដ្ឋាភិបាល

## សំរេច

**មាត្រា១ .-** កែសំរួល និងបំពេញបន្ថែមមាត្រា ២ នៃអនុក្រឹត្យលេខ ១៨ អនក្រ.បក ចុះថ្ងៃទី ១៣ ខែកុម្ភៈ ឆ្នាំ ២០០១ ស្តីពីការបង្កើតគណៈកម្មាធិការតម្រង់ទិសអន្តរក្រសួង ដើម្បីដឹកនាំដំណើរការនៃគម្រោងការជំនួយបច្ចេកទេស និងរៀបចំយុទ្ធសាស្ត្រពាណិជ្ជកម្ម សំរាប់គាំទ្រការកាត់បន្ថយភាពក្រីក្រនៅកម្ពុជា ដែលមានសមាសភាពដូចខាងក្រោមនេះ :-

| | | | |
|---|---|---|---|
| ១-ឯកឧត្តម | **ចម ប្រសិទ្ធ** | រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម | ជាប្រធាន |
| ២-ឯកឧត្តម | **សួស សារ៉េត** | ប្រធានឧត្តមក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិ | ជាទីប្រឹក្សា |

| | | | |
|---|---|---|---|
| ៣-ឯកឧត្តម | **សុក ស៊ីផាន់ណា** | រដ្ឋលេខាធិការក្រសួងពាណិជ្ជកម្ម | ជាអនុប្រធាន |
| ៤-ឯកឧត្តម | **អ៊ុក រ៉ាប៊ុន** | រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | ជាអនុប្រធាន |
| ៥-ឯកឧត្តម | **ច័ន្ទ គុចអ៊ីច** | រដ្ឋលេខាធិការក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ | ជាអនុប្រធាន |
| ៦-ឯកឧត្តម | **សុន គន្ធរ** | ទីប្រឹក្សារាជរដ្ឋាភិបាលទទួលបន្ទុកសេដ្ឋកិច្ច កសិកម្ម និងជាប្រធានអគ្គនាយកធនាគារអភិវឌ្ឍន៍ | ជាសមាជិក |
| ៧-ឯកឧត្តម | **ត្រាំ អ៊ីវតឹក** | រដ្ឋលេខាធិការក្រសួងសាធារណការ និងដឹកជញ្ជូន | ជាសមាជិក |
| ៨-លោកជំទាវ | **យូ អយ** | រដ្ឋលេខាធិការក្រសួងកិច្ចការនារី និងអតីតយុទ្ធជន | ជាសមាជិក |
| ៩-លោកជំទាវ | **ស៊ិន ស៊ី** | អគ្គលេខាធិការរង រាជរដ្ឋាភិបាល | ជាសមាជិក |
| ១០-ឯកឧត្តម | **ហ៊ុល លឹម** | អនុរដ្ឋលេខាធិការក្រសួងឧស្សាហកម្មរ៉ែ និងថាមពល | ជាសមាជិក |
| ១១-ឯកឧត្តម | **សយ ស៊ីផុន** | អនុរដ្ឋលេខាធិការក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា | ជាសមាជិក |
| ១២-ឯកឧត្តម | **រស់ រ៉េន** | អនុរដ្ឋលេខាធិការក្រសួងទេសចរណ៍ | ជាសមាជិក |
| ១៣-ឯកឧត្តម | **ស្នួន សិទ្ធី** | អគ្គលេខាធិការក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា | ជាសមាជិក |
| ១៤-ឯកឧត្តម | **សយ សុខា** | អគ្គលេខាធិការក្រុមសង្កេតការណ៍សេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ នៃទីស្តីការគណៈរដ្ឋមន្ត្រី | ជាសមាជិក |
| ១៥- លោក | **ឆេង សារឿន** | អគ្គនាយករងបច្ចេកទេសក្រសួងពាណិជ្ជកម្ម | ជាសមាជិក និងជាលេខាធិការ |
| ១៦- លោក | **ទេស អ៊ែតដា** | អគ្គនាយកក្រុមហ៊ុនប្រ៊ីនគ្រេដ | ជាសមាជិក |
| ១៧- លោក | **គីម វ៉ាដា** | អនុប្រធាននាយកដ្ឋានត្រួតពិនិត្យ ធនាគារជាតិនៃកម្ពុជា | ជាសមាជិក |
| ១៨- លោក | **វ៉ាន់ ស៊ូអៀង** | ប្រធានសមាគមរោងចក្រកាត់ដេរកម្ពុជា | ជាសមាជិក |
| ១៩- លោកឧកញ៉ា | **ស៊ន សុខណា** | អនុប្រធានសភាពាណិជ្ជកម្មរាជធានីភ្នំពេញ | ជាសមាជិក |
| ២០- លោកឧកញ៉ា | **គង់ ទ្រីវ** | សមាជិកសភាពាណិជ្ជកម្មរាជធានីភ្នំពេញ | ជាសមាជិក |

**មាត្រា២ .-** គណៈកម្មាធិការនេះ មានភារកិច្ចបន្ថែមទៀតក្នុងការរៀបចំគោលនយោបាយពាណិជ្ជកម្ម ដូចខាងក្រោម :

ក-រៀបចំយុទ្ធសាស្ត្រ និងគោលនយោបាយពាណិជ្ជកម្មឱ្យស៊ីសង្វាក់នឹងគោលនយោបាយសេដ្ឋកិច្ចរួមរបស់រាជរដ្ឋាភិបាលកម្ពុជា សំដៅកាត់បន្ថយភាពក្រីក្រនៅកម្ពុជា ។

ខ-ទាក់ទាញដៃគូវិនិយោគឱ្យមកកម្ពុជា ដើម្បីបង្កើនក្របខ័ណ្ឌដៃគូថ្មីសំរាប់ពាណិជ្ជកម្ម និងអភិវឌ្ឍន៍នៅកម្ពុជា ។

គ- រៀបចំ និងកែសំរួលប្រព័ន្ធការងារ ដើម្បីឱ្យការធ្វើពាណិជ្ជកម្មដំណើរការងាយស្រួល ។

ឃ-ពង្រីកឱ្យបាននូវគោលដៅនាំចេញ និងពង្រីកផលិតផលនាំចេញថ្មី ។

ង-បង្កើតសេវាកម្មគាំទ្រពាណិជ្ជកម្មឱ្យដល់សហគ្រាស ។

ច-រៀបចំតំបន់ភាវូបនីយកម្ម និងការធ្វើវិមជ្ឈការ នៃវិស័យនាំចេញនៅកម្ពុជា ។

ឆ-ពង្រឹងឱ្យបានល្អប្រសើរនូវប្រព័ន្ធទីផ្សារ និងការត្រួតពិនិត្យគុណភាពស្រូវអង្ករ ក្រោយពេលច្រូតកាត់ ដើម្បីពង្រឹងសន្តិសុខស្បៀង ។

**មាត្រា៣ .-** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម រដ្ឋមន្ត្រី រដ្ឋលេខាធិការនៃក្រសួងស្ថាប័ន និងសភាពាណិជ្ជកម្មរាជធានីភ្នំពេញ ត្រូវអនុវត្តតាមអនុក្រឹត្យនេះ ឱ្យមានប្រសិទ្ធភាពខ្ពស់ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ២៨ ខែ មីនា ឆ្នាំ ២០០១

**នាយករដ្ឋមន្ត្រី**

**ហត្ថលេខា និងត្រា**

**ហ៊ុន សែន**

000

## អនុក្រឹត្យលេខ ៣២ អនក្រ.បក

## ស្តីពីការផ្ទេរសណ្ឋាគារឧត្តមភោជនីយដ្ឋាន ???

---

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រម នស/រកម/០១៩៦/១៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ០៤ អនក្រ.បក ចុះថ្ងៃទី ២០ ខែ មករា ឆ្នាំ ២០០០ ស្តីពីការ រៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច និងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រម ០១/នស/៩៣ ចុះថ្ងៃទី ២៨ ខែ ធ្នូ ឆ្នាំ ១៩៩៣ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីអំពីប្រព័ន្ធហិរញ្ញវត្ថុ ហើយត្រូវបានកែប្រែដោយច្បាប់ស្តីពីហិរញ្ញវត្ថុសំរាប់ការគ្រប់គ្រងឆ្នាំ ១៩៩៥ ដែលប្រកាសអោយប្រើដោយព្រះរាជក្រមលេខ ១១នស/៩៤ ចុះ ថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ១៩៩៤ និងត្រូវបានកែប្រែដោយច្បាប់ស្តីពីហិរញ្ញវត្ថុ សំរាប់ការគ្រប់ គ្រងឆ្នាំ ២០០០ ដែលប្រកាសអោយប្រើដោយព្រះរាជក្រមលេខ នស/រកម/១២៩៩/១៥ ចុះថ្ងៃទី ២៥ ខែ ធ្នូ ឆ្នាំ ១៩៩៩
- បានឃើញព្រះរាជក្រម នស/រកម/១២០០/១២ ចុះថ្ងៃទី ៣០ ខែ ធ្នូ ឆ្នាំ ២០០០ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីហិរញ្ញវត្ថុសំរាប់ការគ្រប់គ្រង ឆ្នាំ ២០០១
- បានឃើញអនុក្រឹត្យលេខ ៩៩ អនក្រ.បក ចុះថ្ងៃទី ១៨ ខែ ធ្នូ ឆ្នាំ ២០០០ ស្តីពីការបន្ថែមប្រាក់បៀវត្សជូនមន្ត្រីរាជការ ស៊ីវិល យោធា នគរបាលជាតិ និវត្តជន មន្ត្រីបាត់បង់សមត្ថភាពពលកម្ម និងយុទ្ធជនពិការ
- បានឃើញអនុក្រឹត្យលេខ ០២ អនក្រ.បក ចុះថ្ងៃទី ១០ ខែ មករា ឆ្នាំ ២០០១ ស្តីពីការបែងចែកឥណទានថវិកាចំណាយតាមជំពូក នៃច្បាប់ហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រងឆ្នាំ ២០០១
- បានឃើញអនុក្រឹត្យលេខ ០៣ អនក្រ.បក ចុះថ្ងៃទី ១០ ខែ មករា ឆ្នាំ ២០០១ ស្តីពីការផ្ទេរឥណទានថវិកា
- តាមសំណើរបស់ឯកឧត្តមទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

**សំរេច**

**មាត្រា១ .-** ត្រូវបានអនុញ្ញាតអោយផ្ទេរឥណទានថវិកា ពីជំពូក ៤០ ( ចំណាយផ្សេងៗ ) ចំនួន ១៥.០០០ លានរៀល ( ដប់ប្រាំលានរៀល ) មកជំពូក ១០ (បៀវត្ស និងប្រាក់បំណាច់ ) ដើម្បីបន្ថែម

ប្រាក់បៀវត្សចំនួន ១០% លើបៀវត្សសុទ្ធសាធ ជូនមន្ត្រីរាជការ ស៊ីវិល យោធា នគរបាលជាតិ និវត្តជន មន្ត្រីបាត់បង់សមត្ថភាពពលកម្ម និងយុទ្ធជនពិការ ទូទាំងប្រទេសសំរាប់ការគ្រប់គ្រងឆ្នាំ ២០០១ ។

**មាត្រា២ .-** ការបែងចែកឥណទានថវិកាចំណាយផ្ទៃក្នុងជំពូកទាំងនេះ តាមប្រការ កថាខ័ណ្ឌ និងវាក្យខ័ណ្ឌ ត្រូវ ធ្វើឡើងដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

**មាត្រា៣ .-** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ២៨ ខែ មីនា ឆ្នាំ ២០០១

**នាយករដ្ឋមន្ត្រី**

**ហត្ថលេខា និងត្រា**

**ហ៊ុន សែន**

បានយកសេចក្តីជំរាបជូន

សម្តេចនាយករដ្ឋមន្ត្រី ដើម្បីចុះហត្ថលេខា

ហត្ថលេខា គាត ឈន់

ទេសរដ្ឋមន្ត្រី

រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

## អនុក្រឹត្យលេខ ១២២ អនក្រ.ប្រក

## ស្តីពីការតែងតាំងមន្ត្រីរាជការ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញអនុក្រឹត្យលេខ ១៣ អនក្រ.បក ចុះថ្ងៃទី ១០ ខែ មីនា ឆ្នាំ ១៩៩៤ ស្តីពីការបង្កើតក្រុមប្រឹក្សាអ្នកច្បាប់
- យោងតាមសំណូមពរការងារចាំបាច់

**សំរេច**

**មាត្រា១** .- តែងតាំងមន្ត្រីរាជការ ០៣ រូប នៃក្រុមប្រឹក្សាអ្នកច្បាប់ ដែលមានរាយនាមខាងក្រោម :

១-លោក **លុក ញ៉ឹម** ជាអនុប្រធានក្រុមជំនាញ មានឋានៈស្មើ **អគ្គនាយករង**

២-លោក **ទូច សឹងហាយ** ជាអនុប្រធានក្រុមជំនាញ មានឋានៈស្មើ **អគ្គនាយករង**

៣-លោក **សូ ទ្រៃ** ជាលេខាធិការក្រុមជំនាញ មានឋានៈស្មើ **ប្រធាននាយកដ្ឋាន**

**មាត្រា២** .- រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួងស្ថាប័នពាក់ព័ន្ធ ក្រុមប្រឹក្សាអ្នកច្បាប់ និងសាមីខ្លួនដូចមានចែងក្នុងមាត្រា ១ ត្រូវអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ២៦ ខែ មីនា ឆ្នាំ ២០០១

**នាយករដ្ឋមន្ត្រី**

**ហត្ថលេខា និងត្រា**

**ហ៊ុន សែន**

## អនុក្រឹត្យលេខ ១២៣ អនក្រ.ប្រក
## ស្តីពីការជូនមេដាយស្ថាបនាជាតិ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៤ ស្តីពីការប្រកាសអោយប្រើគ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់អភិបាលខេត្តតាកែវ

**សំរេច**

**មាត្រា១ ._** ត្រូវបានបំពាក់ **មេដាយមាសស្ថាបនាជាតិ** ប្រគេន និងជូនសប្បុរសជន ទាំងក្នុងនិងក្រៅប្រទេសចំនួន ០៥ រូប ដែលបានបរិច្ចាគថវិកាផ្ទាល់ខ្លួន ដើម្បីជួយកសាង សាលារៀន ព្រះវិហារ កុដិ សាលាធម្មសភា ក្លោងទ្វារ ក្នុងវត្តអង្គតាសោម ស្រុកត្រាំកក់ ខេត្តតាកែវ ដូចមានរាយនាមខាងក្រោម :

១-ព្រះគ្រូធីរៈវង្សចារ **ខែម សុខ** ព្រះអនុគណស្រុកត្រាំកក់ និងជាចៅអធិការវត្តអង្គតាសោម
ថវិកាចំនួន ១៣.៧៨០ ដុល្លាអាមេរិក

២-ព្រះតេជគុណ **អ៊ុក សារឿន** គង់នៅវត្តពុទ្ធិកសហព័ន្ធប្រទេសបារាំង
ថវិកាចំនួន ៥៦.៥០០ ដុល្លាអាមេរិក

៣-ឧត្តមសេនីយ៍ត្រី **ម៉ៅ សុផាន់** មេបញ្ជាការកងពលតូចលេខ ៧០
ថវិកាចំនួន ១៦.៣៤៦ ដុល្លាអាមេរិក

៤-ឯកឧត្តមអ្នកឧកញ៉ា **ម៉ៅ ធ្វី** អ្នកតំណាងរាស្ត្រមណ្ឌលកំពង់ធំ
ថវិកាចំនួន ១២.៧៥០ ដុល្លាអាមេរិក

៥-ឧកញ៉ា **ហេង សារ៉ាត់** នាយកក្រុមហ៊ុនចំការកៅស៊ូស្នួល
ថវិកាចំនួន ១១.២០០ ដុល្លាអាមេរិក

**មាត្រា២ .-** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និងអភិបាលខេត្តតាកែវ ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី ២៧ ខែ មីនា ឆ្នាំ ២០០១

**នាយករដ្ឋមន្ត្រី**

**ហត្ថលេខា និងត្រា**

**ហ៊ុន សែន**

---

## អនុក្រឹត្យលេខ ១២៤ អនក្រ.តត
## ស្តីពីការជូនមេដាយស្ថាបនាជាតិ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការប្រកាសប្រើគ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់អភិបាលខេត្តតាកែវ

## សំរេច

**មាត្រា១ .-** ត្រូវបានបំពាក់ **មេដាយមាសស្ថាបនាជាតិ** ប្រគេន និងជូនសប្បុរសជនចំនួន ០២ រូប ដែលបានបរិច្ចាគថវិកាផ្ទាល់ខ្លួន ដើម្បីជួយកសាង និងជួសជុលសាលារៀន ព្រះវិហារ ក្លោងទ្វារ និងរបង ក្នុងវត្តមង្គលមានល័ក្ខ ឃុំត្រពាំងធំខាងជើង ស្រុកត្រាំកក់ ខេត្តតាកែវ ដូចមានរាយនាមខាង ក្រោមនេះ :

១-ព្រះតេជគុណ **សៅ តារាទី** ព្រះគ្រូសូត្រស្តាំវត្តមង្គលមានល័ក្ខទឹកប្រាក់ចំនួន ១៦.៥៨១ ដុល្លាអាមេរិក

២-លោក **នូ ម៉ិនថា** ប្រធានក្រុមហ៊ុនជលផលកម្ពុជា ទឹកប្រាក់ចំនួន ១៨.៧៦០ ដុល្លាអាមេរិក

**មាត្រា២ .-** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និងអភិបាលខេត្តតាកែវ ត្រូវអនុវត្តអនុក្រឹត្យនេះអោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី ២៧ ខែ មីនា ឆ្នាំ ២០០១

**នាយករដ្ឋមន្ត្រី**

**ហត្ថលេខា និងត្រា**

**ហ៊ុន សែន**

## អនុក្រឹត្យលេខ ១២៥ អនក្រ.តត

## ស្តីពីការជូនមេដាយស្ថាបនាជាតិ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការប្រកាសប្រើគ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់អភិបាលខេត្តតាកែវ

បណ្ណសារដ្ឋានជាតិ
ថ្ងៃទី______ខែ______ឆ្នាំ________

**សម្រេច**

**មាត្រា១ .-** ត្រូវបានបំពាក់ **មេដាយមាសស្ថាបនាជាតិ** ជូនលោក **ខួន ឆាន** ដែលបានបរិច្ចាគថវិកាផ្ទាល់ខ្លួន ចំនួន ១២.០០០ ដុល្លារអាមេរិក ជួយកសាងសាលាធម្មសភា ០១ ខ្នង មានបណ្តោយ ២៩ម ទទឹង ១៧ ម ក្នុងវត្តអង្គប្រសើរ ឃុំតាភេម ស្រុកត្រាំកក់ ខេត្តតាកែវ ។

**មាត្រា២ .-** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និងអភិបាលខេត្តតាកែវ ត្រូវអនុវត្តអនុក្រឹត្យនេះអោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី ២៧ ខែ មីនា ឆ្នាំ ២០០១

**នាយករដ្ឋមន្ត្រី**

**ហត្ថលេខា និងត្រា**

**ហ៊ុន សែន**

---

**អនុក្រឹត្យលេខ ១២៦ អនក្រ.តត**

**ស្តីពីការជូនមេដាយ ស្ថាបនាជាតិ**

---

**រាជរដ្ឋាភិបាល**

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការប្រកាសប្រើគ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី

ថ្ងៃ____ខែ____ឆ្នាំ



## សំរេច

**មាត្រា១** .- ត្រូវបានប្រគល់ **មេដាយស្ថាបនាជាតិ** តាមលំដាប់ថ្នាក់ជូនសប្បុរសជនចំនួន ២៧ រូប ដែលបានបរិច្ចាគធនធានផ្ទាល់ខ្លួនចូលរួមជួសជុលផ្លូវលេខ ២២ ពីផ្លូវបំបែកស្រុកចំការលើ ទៅកាន់ទីរួមស្រុកស្ទឹងត្រង់ ជួសជុលផ្លូវលំពីឃុំទ្រៀល ស្រុកបារាយណ៍ ខេត្តកំពង់ធំ ទៅកាន់ឃុំចំការអណ្តូង ស្រុកចំការលើ ខេត្តកំពង់ចាម និងស្ពានថ្មមួយកន្លែង កសាងព្រះវិហារ និងសាលារៀនភូមិ ៣២ ក្នុងមូលដ្ឋានចំការកៅស៊ូស្វាមាស និងព្រះវិហារ ភូមិលេខ ១ ក្នុងមូលដ្ឋានចំការកៅស៊ូសហគ្រាន់ ដូចមានរាយនាមជូនខាងក្រោម :

**ក.មេដាយមាសស្ថាបនាជាតិចំនួន ០៧ រូប:**

| | | |
|---|---|---|
| ១-លោក | **ចាន់ ហ៊ិត** | ១៨.000 USD |
| ២-លោក | **ឃឹម លុច្ស** | ១០.៨00 USD |
| ៣-លោក | **គឹម សំអឿន** | ១០.0៥0 USD |
| ៤-លោក | **ម៉ៅ ធនិន** | ១០.៤00 USD |
| ៥-លោក | **ថៃ ថេន** | ១០.៦00 USD |
| ៦-លោក | **លឹម សុភាព** | ១០.0៥0 USD |
| ៧-លោកស្រី | **គឹម នុតនិត្យា** | ១០.0៥0 USD |

**ខ.មេដាយប្រាក់ស្ថាបនាជាតិចំនួន ០៨ រូប:**

| | | |
|---|---|---|
| ១-ឧបាសិកា | **ស៊ិន ទើខយី** | ៥.000 USD |
| ២-លោក | **កែវ សុខ** | ៥.000 USD |
| ៣-លោក | **នូ សេដ្ឋា** | ៥.000 USD |
| ៤-លោក | **អ៊ូ សារិន** | ៥.000 USD |
| ៥-លោក | **គង់ ចាន់ធូ** | ៥.000 USD |
| ៦-លោក | **ខៀវ សាន** | ៥.000 USD |
| ៧-លោក | **ប៊ុន ហៃ** | ៥.000 USD |
| ៨-លោក | **កុយ សាវុធ** | ៥.000 USD |

**គ-មេដាយសេរីភាពស្ថាបនាជាតិចំនួន ១២ រូប:**

| | | |
|---|---|---|
| ១-លោក | **ហួន នឿន** | ១.០០០ USD |
| ២-លោក | **យូ សំអឿន** | ១.០០០ USD |
| ៣-លោក | **ហែម គំរុណ** | ១.០០០ USD |
| ៤-លោក | **ទង់ ឈួម** | ១.០០០ USD |
| ៥-លោក | **ឈិត ទិសុទ្ធ** | ១.០០០ USD |
| ៦-លោក | **តាន់ ចាន់ថន** | ១.០០០ USD |
| ៧-លោក | **ប្លាក់ ចាន់សោភា** | ១.០០០ USD |
| ៨-លោក | **គេន កុលបុត្រ** | ១.០០០ USD |
| ៩-លោក | **អ៊ុំ បណ្ឌិត** | ១.០០០ USD |
| ១០-អ្នកស្រី | **ស៊ុំ ស៊ីវហេង** | ១.០០០ USD |
| ១១-អ្នកស្រី | **សេង សារ៉ែន** | ១.០០០ USD |
| ១២-លោក | **យុន សុខា** | ១.០០០ USD |

**មាត្រា៣ .-** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និងខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី ត្រូវអនុវត្ត អនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី ២៧ ខែ មីនា ឆ្នាំ ២០០១

**នាយករដ្ឋមន្ត្រី**

**ហត្ថលេខា និងត្រា**

**ហ៊ុន សែន**

---

**អនុក្រឹត្យលេខ ១២៧ អនក្រ.គត**

**ស្តីពីការជូនមេដាយស្ថាបនាជាតិ**

---

**រាជរដ្ឋាភិបាល**

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការប្រកាសប្រើគ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី

**សំរេច**

**មាត្រា១ .-** ត្រូវបានប្រគល់ **មេដាយស្ថាបនាជាតិ** តាមលំដាប់ថ្នាក់ជូនសប្បុរសជនចំនួន ១២ រូប ដែលបានបរិច្ចាគធនធានផ្ទាល់ខ្លួនចូលរួមកសាងអាគារស្នាក់នៅរបស់កងឯកភាពអង្គរក្ស និងព្រះវិហារវត្តត្រពាំងវែង ឃុំព្រះនិពាន្ធ ស្រុកគងពិសី ខេត្តកំពង់ស្ពឺ ដូចមានរាយនាមជូនខាងក្រោម :

**ក.មេដាយមាសស្ថាបនាជាតិចំនួន ១០ រូប :**

| | | |
|---|---|---|
| ១-ឧបាសិកា | **គាត់ ឡឹង** | ១៧.០០០ USD |
| ២-ឧបាសិកា | **សុខ ជុំ** | ១៧.០០០ USD |
| ៣-លោក | **ខេន សុភា** | ១០.៥០០ USD |
| ៤-លោកស្រី | **ឃុន សុខអឹា** | ១០.២៥០ USD |
| ៥-លោក | **ជ័យ ផេង** | ១០.០១២ USD |
| ៦-លោក | **ហេង ឧត្តរ** | ១០.០០០ USD |
| ៧-លោក | **ញឹក សារិ** | ១០.០០០ USD |
| ៨-លោក | **តែ តាំងប៉រ** | ១០.០០០ USD |
| ៩-លោក | **មុំ កុសល** | ១០.០០០ USD |
| ១០-លោក | **ពិន សុវណ្ណ** | ១០.០០០ USD |

**ខ-មេដាយប្រាក់ស្ថាបនាជាតិចំនួន ០២ រូប :**

១-លោក **ជា ខឿ** ៥.០០០ USD

២-លោក **សុខ ម៉ឺន** ៥.០០០ USD

**មាត្រា២ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី និងខុទ្ទកាល័យសម្ដេចនាយករដ្ឋមន្ត្រី ត្រូវអនុវត្ត អនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី ២៧ ខែ មីនា ឆ្នាំ ២០០១

**នាយករដ្ឋមន្ត្រី**

**ហត្ថលេខា និងត្រា**

**ហ៊ុន សែន**

**អនុក្រឹត្យលេខ ១២៨ អនក្រ.តត**

**ស្ដីពីការជូនមេដាយ ការងារ**

**រាជរដ្ឋាភិបាល**

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្ដីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្ដីពីការប្រកាសប្រើគ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់ខុទ្ទកាល័យសម្ដេចនាយករដ្ឋមន្ត្រី

## សំរេច

**មាត្រា១ ._** ត្រូវបានប្រគល់ **មេដាយការងារ** តាមលំដាប់ថ្នាក់ជូន នាយទាហាន នាយទាហានរង នៃកងឯកភាពអង្គរក្សសម្តេច ហ៊ុន សែន ចំនួន ៣៧ រូប ដែលមានស្នាដៃល្អក្នុងការបំពេញភារកិច្ចជូនជាតិមាតុភូមិ ដូចមានរាយនាមជូនខាងក្រោម :

**ក._មេដាយមាសការងារចំនួន ១០ រូប :**

| | | |
|---|---|---|
| ១-លោកវរសេនីយ៍ឯក | **សុខ, យ៉ាន** | មេបញ្ជាការរងអង្គរក្សសម្តេច ហ៊ុន សែន |
| ២-លោកវរសេនីយ៍ឯក | **សោម ជន** | មេបញ្ជាការរងអង្គរក្សសម្តេច ហ៊ុន សែន |
| ៣-លោកវរសេនីយ៍ឯក | **សុខ ចារុវណ្ណ** | មេបញ្ជាការរងអង្គរក្សសម្តេច ហ៊ុន សែន |
| ៤-លោកវរសេនីយ៍ឯក | **គង់ វណ្ណា** | មេបញ្ជាការរងអង្គរក្សសម្តេច ហ៊ុន សែន |
| ៥-លោកវរសេនីយ៍ឯក | **ម៉ែន គរម្យ** | មេបញ្ជាការរងអង្គរក្សសម្តេច ហ៊ុន សែន |
| ៦-លោកវរសេនីយ៍ទោ | **អន សារិទ្ធ** | នាយរងសេនាធិការ |
| ៧-លោកវរសេនីយ៍ទោ | **ឌឹម សរី** | នាយការិយាល័យព្រហ្មទណ្ឌ |
| ៨-លោកវរសេនីយ៍ទោ | **កែវ សុខគី** | នាយទាហានការពារផ្ទាល់ |
| ៩-លោកវរសេនីយ៍ទោ | **លឹម សុធា** | មេបញ្ជាការបញ្ជាការដ្ឋាន |
| ១០-លោកវរសេនីយ៍ទោ | **សោម សួគ៌ធិដា** | នាយការិយាល័យទី ១ |
| ១១-លោកវរសេនីយ៍ទោ | **ព្រហ្ម ពន្លឺ** | នាយរងការិយាល័យទី ១ |
| ១២-លោកវរសេនីយ៍ទោ | **ហួរ វ៉ាន់** | មេបញ្ជាការរងវរសេនាតូច ៩៩៤ |
| ១៣-លោកវរសេនីយ៍ទោ | **សរ សាវ៉ាន់** | នាយទាហានការពារផ្ទាល់ |
| ១៤-លោកវរសេនីយ៍ត្រី | **ម៉ុន តារា** | នាយទាហានការពារផ្ទាល់ |
| ១៥-លោកវរសេនីយ៍ត្រី | **មាស ស៊ីថុន** | នាយរងការិយាល័យទី ៥ |
| ១៦-លោកវរសេនីយ៍ត្រី | **ឃួន វណ្ណា** | នាយទាហានការពារផ្ទាល់ |
| ១៧-លោកវរសេនីយ៍ត្រី | **ស៊ុន ចាន់សុគី** | នាយផ្នែកបញ្ជូនសារ |
| ១៨-លោកវរសេនីយ៍ត្រី | **ហាម បូនី** | មេបញ្ជាការរងវរសេនាតូចកុម្ម៉ង់ដូ |
| ១៩-លោកវរសេនីយ៍ត្រី | **ឡេង គឿន** | មេបញ្ជាការរងវរសេនាតូចកងរាជអាវុធហត្ថ |

២០-លោកវរសេនីយ៍ត្រី **សុខ សុផា** នាយរងការិយាល័យហ្វីកហ្វីន

២១-លោកវរសេនីយ៍ត្រី **អ៊ុន នុត** ជំនួយការវរសេនាតូច ២៤៦

២២-លោកវរសេនីយ៍ត្រី **យង់ ម៉ិនថាត** ជំនួយការហិរញ្ញវត្ថុ

២៣-លោកវរសេនីយ៍ត្រី **សំ សុគន្ធា** នាយទាហានការពារផ្ទាល់

២៤-លោកវរសេនីយ៍ត្រី **អន ណារ៉ាត្រី** នាយរងការិយាល័យទី ៣

២៥-លោកអនុសេនីយ៍ឯក **នួន ឡឿន** នាយទាហានការពារផ្ទាល់

២៦-លោកអនុសេនីយ៍ឯក **ឆេត សុជាតិ** បញ្ជាការរងកងអនុសេនាធំកងរាជអាវុធហត្ថ

២៧-លោកអនុសេនីយ៍ឯក **អ៊ុច បញ្ញោត** ជំនួយការលេខាធិការដ្ឋាន

**ខ-មេដាយប្រាក់ការងារចំនួន ១០ រូប:**

១-លោកវរសេនីយ៍ទោ **មាស យ័ន្ត** បញ្ជាការរងវរសេនាតូច ៩៩៤

២-លោកវរសេនីយ៍ទោ **សំ សារឿន** បញ្ជាការរងវរសេនាតូចកងរាជអាវុធហត្ថ

៣-លោកវរសេនីយ៍ទោ **ហ៊ា សារឿន** បញ្ជាការរងវរសេនាតូចកុម្ម៉ង់ដូ

៤-លោកវរសេនីយ៍ត្រី **កែវ ពិសិដ្ឋ** នាយទាហានការពារផ្ទាល់

៥-លោកវរសេនីយ៍ត្រី **សុះ ភារី** នាយទាហានការពារផ្ទាល់

៦-លោកវរសេនីយ៍ត្រី **សាយ សាគង់** នាយទាហានការពារផ្ទាល់

៧-លោកវរសេនីយ៍ត្រី **សុខ គីមអេង** បញ្ជាការរងវរសេនាតូចអន្តរាគមន៍

៨-លោកវរសេនីយ៍ត្រី **ស៊ឹម ផាន** បញ្ជាការអនុសេនាធំជើងទឹក

៩-លោកអនុសេនីយ៍ត្រី **ចៅ សារី** នាយទាហានការពារផ្ទាល់

១០-លោកអនុសេនីយ៍ឯក **ជា ពិសី** ជំនួយការមេបញ្ជាការអង្គរក្ស

**មាត្រា២ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និងខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី ២៧ ខែ មីនា ឆ្នាំ ២០០១

**នាយករដ្ឋមន្ត្រី**

**ហត្ថលេខា និងត្រា**

**ហ៊ុន សែន**

# អនុក្រឹត្យលេខ ១២៩ អនក្រ.តត
## ស្តីពីការតែងតាំងមន្ត្រីរាជការ

### រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៣ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការបង្កើតក្រសួងសាធារណការ និងដឹកជញ្ជូន
- បានឃើញអនុក្រឹត្យលេខ ១៤/អនក្រ.បក ចុះថ្ងៃទី ០៣ ខែ មីនា ឆ្នាំ ១៩៩៨ ស្តីពីការ រៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងសាធារណការ និងដឹកជញ្ជូន
- យោងតាមសំណើរបស់ក្រសួងសាធារណការ និងដឹកជញ្ជូន

### សំរេច

**មាត្រា១ .-** ត្រូវបានតែងតាំងលោក **ពៅ ម៉ាលី** ជាអគ្គនាយករង នៃអគ្គនាយកដ្ឋានដឹកជញ្ជូន នៃក្រសួងសាធារណការ និងដឹកជញ្ជូន ។

**មាត្រា២ .-** បទប្បញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

**មាត្រា៣ .-** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងសាធារណការ និងដឹកជញ្ជូន រដ្ឋលេខាធិការ នៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ សហរដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួន ដូចមានចែងក្នុងមាត្រា ១ ត្រូវអនុវត្តអនុក្រឹត្យនេះ អោយមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ២៧ ខែ មីនា ឆ្នាំ ២០០១

**នាយករដ្ឋមន្ត្រី**

**ហត្ថលេខា និងត្រា**

**ហ៊ុន សែន**

# អនុក្រឹត្យលេខ ១៣០ អនក្រ.តត
# ស្តីពីការតែងតាំងមន្ត្រីរាជការ

---

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញអនុក្រឹត្យលេខ ៧៦/អនក្រ.បក ចុះថ្ងៃទី ០១ ខែ ធ្នូ ឆ្នាំ ១៩៩៨ ស្តីពីការបង្កើតខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា
- យោងតាមសំណូមពរការងារចាំបាច់របស់រាជរដ្ឋាភិបាល

## សំរេច

**មាត្រា១ .-** ត្រូវបានតែងតាំងលោក **ថោ វឌ្ឍនា** ជាជំនួយការរបស់ឯកឧត្តម សម សុគ្គា ទីប្រឹក្សាផ្ទាល់សម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា មានឋានៈស្មើ ប្រធាននាយកដ្ឋាន ។

**មាត្រា២ .-** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ សហរដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួន ត្រូវអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ២៧ ខែ មីនា ឆ្នាំ ២០០១

**នាយករដ្ឋមន្ត្រី**

**ហត្ថលេខា និងត្រា**

**ហ៊ុន សែន**

---

# អនុក្រឹត្យលេខ ១៣១ អនក្រ.តត

# ស្តីពីការតែងតាំងមន្ត្រីត្រួតពិនិត្យរដ្ឋ

# អមធនាគារអភិវឌ្ឍន៍ជនបទ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ជស/រកម/០៦៩៦/០៣ ចុះថ្ងៃទី ១៧ ខែ មិថុនា ឆ្នាំ ១៩៩៦ ស្តីពី លក្ខន្តិកៈទូទៅនៃសហគ្រាសសាធារណៈ
- បានឃើញអនុក្រឹត្យលេខ ៩៥ អនក្រ.បក ចុះថ្ងៃទី ១៦ ខែ វិច្ឆិកា ឆ្នាំ ១៩៩៩ ស្តីពីការធ្វើវិសោធនកម្មលើអនុក្រឹត្យលេខ ០១ អនក្រ.បក ចុះថ្ងៃទី ០១ ខែ មករា ឆ្នាំ ១៩៩៨ ស្តីពីការបង្កើតធនាគារអភិវឌ្ឍន៍ជនបទ
- បានឃើញលក្ខន្តិកៈនៃធនាគារអភិវឌ្ឍន៍ជនបទ ចុះថ្ងៃទី ៣០ ខែវិច្ឆិកា ឆ្នាំ ១៩៩៩
- បានឃើញអនុក្រឹត្យលេខ ៤៣៣ អនក្រ.តត ចុះថ្ងៃទី ០៩ ខែ កក្កដា ឆ្នាំ ១៩៩៩ ស្តីពីការតែងតាំងប្រធានអគ្គនាយករបស់ធនាគារអភិវឌ្ឍន៍ជនបទ
- តាមសំណើរបស់ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

## សំរេច

**មាត្រា១ :** តែងតាំងលោក **ចាប សុវណ្ណ** ជាមន្ត្រីត្រួតពិនិត្យរដ្ឋ អមធនាគារអភិវឌ្ឍន៍ជនបទ ។

**មាត្រា២ .-** បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

**មាត្រា៣ .-** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រី រដ្ឋលេខាធិការ នៃក្រសួង ស្ថាប័នដែលពាក់ព័ន្ធ ប្រធានអគ្គនាយកនៃធនាគារអភិវឌ្ឍន៍ជនបទ

និងសាមីខ្លួន ត្រូវទទួលអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ២៨ ខែ មីនា ឆ្នាំ ២០០១

**នាយករដ្ឋមន្ត្រី**

**ហត្ថលេខា និងត្រា**

**ហ៊ុន សែន**

---

## អនុក្រឹត្យលេខ ១៣២ អនក្រ.តត
## ស្តីពីការជូនមេដាយស្ថាបនាជាតិ

## រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការប្រកាសប្រើគ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

- យោងតាមសំណើរបស់ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី

## សម្រេច

**មាត្រា១ .-** ត្រូវបានបំពាក់ **មេដាយមាសស្ថាបនាជាតិ** ជូនលោកបណ្ឌិត **សឺវ៉ន្ធ សុទ្ធ** តំណាងក្រុមបញ្ញាជនខ្មែរនៅប្រទេសបារាំង ដែលបានធ្វើអំណោយឯកសារវិទ្យាសាស្ត្រសំរាប់តំកល់ទុកក្នុងបណ្ណាល័យសម្តេច ហ៊ុន សែន នៅសាកលវិទ្យាល័យភូមិន្ទភ្នំពេញចំនួនពីរលើក លើកទី១ មានតម្លៃគិតជាទឹកប្រាក់ចំនួន ២៥០.០០០ ដុល្លាអាមេរិក និងលើកទី ២ ចំនួន ៣២ កេស ទម្ងន់ប្រមាណ ២ តោន ។

**មាត្រា២ .-** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី ២៨ ខែ មីនា ឆ្នាំ ២០០១

**នាយករដ្ឋមន្ត្រី**

**ហត្ថលេខា និងត្រា**

**ហ៊ុន សែន**

---

**អនុក្រឹត្យលេខ ១៣៣ អនក្រ.តត**

**ស្តីពីការជូនមេដាយស្ថាបនាជាតិ**

---

## រាជរដ្ឋាភិបាល

- បានឃើ[illegible]ញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- [illegible]ព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ [illegible]ពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- [illegible]នឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការប្រកាសប្រើគ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់នាយកដ្ឋានតំកល់ឯកសារជាតិ នៃទីស្តីការគណៈរដ្ឋមន្ត្រី

**សំរេច**

**មាត្រា១** : ត្រូវបានបំពាក់ **មេដាយមាសស្ថាបនាជាតិ** ជូនអង្គការជប៉ុនចំនួនពីរ :

-អង្គការ TOYOTA FOUNDATION បានបរិច្ចាគថវិកាចំនួន ៦៥.០០០ ដុល្លារអាមេរិក សំរាប់ទិញសំភារៈជួសជុលឯកសារ និងជួយឧបត្ថម្ភអ្នកជំនាញការអូស្ត្រាលី រយៈពេលបីឆ្នាំ ១៩៩៩-២០០១

-អង្គការ JAPAN FOUDATION ASIA CENTER បានបរិច្ចាគថវិការចំនួន ២៥.០០០ ដុល្លារអាមេរិក សំរាប់ទិញឧបករណ៍មីក្រូហ្វីល ។

ជំនួយឧបត្ថម្ភទាំងអស់នេះ ធ្វើអោយនាយកដ្ឋានតំកល់ឯកសារជាតិ មានលទ្ធភាព ជួសជុល និងថតចំលងឯកសារចាស់ៗ ដែលពុកផុយដើម្បីរក្សាទុកបំរើការស្រាវជ្រាវបានយូរអង្វែង ។

**មាត្រា២.-** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និងនាយកដ្ឋានតំកល់ឯកសារជាតិ ត្រូវអនុវត្ត អនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី ២៨ ខែ មីនា ឆ្នាំ ២០០១

**នាយករដ្ឋមន្ត្រី**

**ហត្ថលេខា និងត្រា**

**ហ៊ុន សែន**

---

## អនុក្រឹត្យលេខ ១៣៤ អនក្រ.គត

## ស្តីពីការជូនមេដាយការងារ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការប្រកាសប្រើគ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍

## សម្រេច

**មាត្រា១ ._** ត្រូវបានបំពាក់ **មេដាយការងារ** តាមលំដាប់ថ្នាក់ជូនមន្ត្រីរាជការ នៃក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ ១៩០ រូប ដែលមានស្នាដៃល្អក្នុងការបំពេញភារកិច្ច លើការងារប្រៃសណីយ៍ និងទូរគមនាគមន៍ ក្នុងឆ្នាំ ២០០០ ដូចមានរាយនាមខាងក្រោម :

**ក._មេដាយប្រាក់ការងារ :**

| | | |
|---|---|---|
| ១-លោក | **គុយ ពុំ** | នាយកខុទ្ទកាល័យ |
| ២-លោក | **ញាន ស្រស់** | ប្រធាននាយកដ្ឋានផែនការ-ហិរញ្ញវត្ថុ |
| ៣-លោក | **ផាល់ ឧុត្តរិកា** | អនុប្រធាននាយកដ្ឋានផែនការ-ហិរញ្ញវត្ថុ |
| ៤-កញ្ញា | **ឡេ ម៉ាយគៀង** | អនុប្រធាននាយកដ្ឋានផែនការ-ហិរញ្ញវត្ថុ |
| ៥-លោក | **ពូច ហេង** | ប្រធាននាយកដ្ឋានទូរគមនាគមន៍ក្នុងប្រទេស |
| ៦-លោក | **ពត ស៊្រាង** | អនុប្រធាននាយកដ្ឋានទូរគមនាគមន៍ក្នុងប្រទេស |
| ៧-លោក | **ឈ័ស ម៉ូរ៉ាត** | អនុប្រធាននាយកដ្ឋានទូរគមនាគមន៍ក្នុងប្រទេស |
| ៨-លោក | **លី សំអាន** | ប្រធាននាយកដ្ឋានទូរគមនាគមន៍អន្តរជាតិ |
| ៩-លោក | **ឡាយ ឧុទ្ធី** | អនុប្រធាននាយកដ្ឋានទូរគមនាគមន៍អន្តរជាតិ |
| ១០-លោក | **ត្រី សេង** | អនុប្រធាននាយកដ្ឋានទទួលបន្ទុកក្តាប់រួមអធិការដ្ឋាន |
| ១១-លោក | **ព្រាប សុរិទ្ធី** | អនុប្រធាននាយកដ្ឋានប្រៃសណីយ៍ |
| ១២-លោក | **ស៊ា ណារ៉េត** | ប្រធាននាយកដ្ឋានគ្រប់គ្រងរលកអាកាសវិទ្យុគមនាគមន៍ |
| ១៣-លោក | **តុប សុខខួន** | ប្រធាននាយកដ្ឋាននយោបាយទូរគមនាគមន៍និយ័ត |
| ១៤-លោក | **ហ៊ុល គុណវឌ្ឍ** | អនុប្រធាននាយកដ្ឋាននយោបាយទូរគមនាគមន៍និយ័ត |

**ខ._មេដាយសំរិទ្ធការងារ :**

| | | |
|---|---|---|
| ១-លោក | **អាំ សំអាត** | ប្រធានមន្ទីរប្រៃសណីយ៍ ខេត្តសៀមរាប |
| ២-លោក | **ដេត ពីរសិទ្ធ** | ប្រធានមន្ទីរប្រៃសណីយ៍ ខេត្តរតនគីរី |
| ៣-លោក | **សួន នន** | ប្រធានមន្ទីរប្រៃសណីយ៍ ខេត្តកោះកុង |
| ៤-លោក | **ម៉ៅ ផល្លា** | ប្រធានមន្ទីរប្រៃសណីយ៍ ខេត្តស្វាយរៀង |
| ៥-អ្នកស្រី | **ម៉ន សារី** | អនុប្រធានមន្ទីរប្រៃសណីយ៍ ខេត្តតាកែវ |

| | | |
|---|---|---|
| ៦-លោក | សាន់ គឹមសិន | ប្រធានមន្ទីរប្រៃសណីយ៍ ខេត្តកំពង់ចាម |
| ៧-លោក | យស់ សុធា | ប្រធានមន្ទីរប្រៃសណីយ៍ ក្រុងព្រះសីហនុ |
| ៨-លោក | លី មុនីនាថ | ប្រធានមន្ទីរប្រៃសណីយ៍ ខេត្តព្រៃវែង |
| ៩-លោក | អ៊ុំ ឆែ | ប្រធានមន្ទីរប្រៃសណីយ៍ ខេត្តពោធិសាត់ |
| ១០-លោក | អោក ម៉ូរ៉ា | ប្រធានមន្ទីរប្រៃសណីយ៍ ខេត្តបន្ទាយមានជ័យ |
| ១១-លោក | នួន សុវណ្ណ | ប្រធានមន្ទីរប្រៃសណីយ៍ ខេត្តព្រះវិហារ |
| ១២-លោក | ម៉ែន កែវ | ប្រធានមន្ទីរប្រៃសណីយ៍ ខេត្តកំពង់ស្ពឺ |
| ១៣-លោក | រិន សុខុម | ប្រធានមន្ទីរប្រៃសណីយ៍ ខេត្តឧត្តរមានជ័យ |
| ១៤-លោក | គ្រឹម ឌូម៉ា | ប្រធានមន្ទីរប្រៃសណីយ៍ ខេត្តបាត់ដំបង |
| ១៥-លោក | អ៊ុក តារុណ | ប្រធានមន្ទីរប្រៃសណីយ៍ ខេត្តកំពត |
| ១៦-លោក | សាល់ ស៊ីថារិទ្ធ | ប្រធានមន្ទីរប្រៃសណីយ៍ ខេត្តកំពង់ធំ |
| ១៧-លោក | ម៉ែន ទ៉ុយ | ប្រធានមន្ទីរប្រៃសណីយ៍ ខេត្តមណ្ឌលគិរី |
| ១៨-លោក | ឡាយ សុមេធី | ប្រធានមន្ទីរប្រៃសណីយ៍ ខេត្តក្រចេះ |
| ១៩-លោក | និត សារ៉េត | ប្រធានមន្ទីរប្រៃសណីយ៍ ខេត្តស្ទឹងត្រែង |
| ២០-លោក | សាច ណារុត | ប្រធានមន្ទីរប្រៃសណីយ៍ ក្រុងកែប |
| ២១-លោក | យស់ សុផន | ប្រធានមន្ទីរប្រៃសណីយ៍ ខេត្តកំពង់ឆ្នាំង |
| ២២-លោក | ហ៊ុយ សារិន | ប្រធានមន្ទីរប្រៃសណីយ៍ ក្រុងប៉ៃលិន |
| ២៣-លោក | ហួន ចន្ថា | អនុប្រធានមន្ទីរប្រៃសណីយ៍ ខេត្តកណ្តាល |
| ២៤-លោក | អ៊ិច សុខុម | ប្រធានការិយាល័យបុគ្គលិក |
| ២៥-លោក | ប៉ុក សុផាត | ប្រធានការិយាល័យរដ្ឋបាល |
| ២៦-លោក | ដួន ដារ៉ូ | អនុប្រធានការិយាល័យបុគ្គលិក |
| ២៧-អ្នកស្រី | ម៉ុំ បូរសាត | ប្រធានការិយាល័យរដ្ឋបាល |
| ២៨-លោក | យោង តារា | អនុប្រធានការិយាល័យអធិការកិច្ច |
| ២៩-លោក | កែវ សារិន | ប្រធានការិយាល័យអាជីវកម្មប្រៃសណីយ៍ |
| ៣០-លោក | វង្ស ស៊ីម | ប្រធានការិយាល័យរដ្ឋបាលប្រៃសណីយ៍ |

| | | |
|---|---|---|
| ៣១-អ្នកស្រី | **លិម លឿង** | ប្រធានការិយាល័យផែនការប្រៃសណីយ៍ |
| ៣២-លោក | **ចិន សំអឿន** | ប្រធានការិយាល័យ |
| ៣៣-លោក | **ថាច់ សំ** | ប្រធានការិយាល័យ |
| ៣៤-លោក | **សុក ឆៅ** | ប្រធានការិយាល័យ |
| ៣៥-លោក | **ត្រាក់ គារ៉ាវុធ** | ប្រធានការិយាល័យ |
| ៣៦-លោក | **ហេង សារី** | ប្រធានការិយាល័យ |
| ៣៧-លោក | **សេង សែនសុគន្ធ** | ប្រធានការិយាល័យ |
| ៣៨-លោក | **សេង ខា** | អនុប្រធានការិយាល័យអាជីវកម្ម |
| ៣៩-លោក | **អ៊ុក សុគន** | ប្រធានការិយាល័យរដ្ឋបាល |
| ៤០-អ្នកស្រី | **អាន គីមឈុន** | ប្រធានការិយាល័យហិរញ្ញវត្ថុ |
| ៤១-លោក | **ឡេង បូគន្ធ** | ប្រធានការិយាល័យស្ថិតិ |
| ៤២-លោក | **ឡោ ប៊ុន** | ប្រធានការិយាល័យវិក្កយបត្រ |
| ៤៣-លោក | **ខិន អ៊ិន** | ប្រធានការិយាល័យសំភារៈ |
| ៤៤-អ្នកស្រី | **អ៊ុំ គៀន** | អនុប្រធានផ្នែកជំពាក់ពន្ធ |
| ៤៥-លោក | **អ៊ុយ សុខហេង** | ប្រធានការិយាល័យ |
| ៤៦-លោក | **សម្បត្តិ ណារិទ្ធ** | ប្រធានការិយាល័យ |
| ៤៧-លោក | **លឹម វុទ្ធី** | អនុប្រធានការិយាល័យ |
| ៤៨-លោក | **ហ៊ាន ជាវុធជា** | ប្រធានមជ្ឈមណ្ឌលសំរបសំរួលប្រព័ន្ធ |
| ៤៩-លោក | **ទេព ធីរៈ** | មន្ត្រី |
| ៥០-លោក | **ចាប ពិនមុនី** | ប្រធានមជ្ឈមណ្ឌលមាត់ច្រកអន្តរជាតិ |
| ៥១-លោក | **អ៊ូរ មាង** | ប្រធានមជ្ឈមណ្ឌល |
| ៥២-អ្នកស្រី | **អ៊ុន ឯកមុនី** | ប្រធានមជ្ឈមណ្ឌល |
| ៥៣-លោក | **គីម យក់ឡាង** | អនុប្រធានមជ្ឈម់ណ្ឌល |
| ៥៤-លោក | **អ៊ា ធីរៈ** | អនុប្រធានមជ្ឈមណ្ឌល |
| ៥៥-អ្នកស្រី | **ញៀម សេដ្ឋា** | អនុប្រធានមជ្ឈមណ្ឌល |

| | | |
|---|---|---|
| ៥៦-លោក | ខឹន ដារ៉ូ | ប្រធានមជ្ឈមណ្ឌលនិយ័តប្រព័ន្ធ |
| ៥៧-លោក | ហេង សុខវិសេស | មន្ត្រី |
| ៥៨-លោក | ស៊ឹង ថារ៉ា | ប្រធានផ្នែក |
| ៥៩-លោក | គឹម ម៉ុនថា | អនុប្រធានមជ្ឈមណ្ឌល |
| ៦០-លោក | ចូវ ឡេង | ប្រធានមជ្ឈមណ្ឌល |
| ៦១-លោក | នូ សឿន | អនុប្រធានការិយាល័យអាជីវកម្ម |
| ៦២-លោក | ឡៀល ធារី | ប្រធានការិយាល័យ |
| ៦៣-លោក | លី ណារិទ្ធ | អនុប្រធានមជ្ឈមណ្ឌល |
| ៦៤-លោក | សុខ ល័យហេង | ប្រធានការិយាល័យ |
| ៦៥-លោក | ស៊ុន ចំរើន | ប្រធានមជ្ឈមណ្ឌល |
| ៦៦-លោក | ហ៊ត សុត្ថារិទ្ធ | អនុប្រធានមជ្ឈមណ្ឌល |
| ៦៧-លោក | ហួត គីមឡេង | អនុប្រធានមជ្ឈមណ្ឌល |
| ៦៨-លោក | អ៊ឹម ឧត្តា | អនុប្រធានមជ្ឈមណ្ឌល |
| ៦៩-លោក | អុក ដូរ៉ានី | អនុប្រធានមជ្ឈមណ្ឌល |
| ៧០-លោក | អ៊ុច រិទ្ធី | ប្រធានមជ្ឈមណ្ឌល |
| ៧១-លោក | រាំង ចំនួនរិទ្ធី | អនុប្រធានមជ្ឈមណ្ឌល |
| ៧២-លោក | គឹម សំខាន់ | ប្រធានផ្នែកមជ្ឈមណ្ឌល |
| ៧៣-លោក | សួន ស្រៀន | អនុប្រធានផ្នែកមជ្ឈមណ្ឌល |
| ៧៤-លោក | ខេង ឡេន | អនុប្រធានមន្ទីរប្រៃសណីយ៍ ខេត្តសៀមរាប |
| ៧៥-លោក | គឹម ឈន | អនុប្រធានមន្ទីរប្រៃសណីយ៍ ខេត្តស្វាយរៀង |
| ៧៦-អ្នកស្រី | តែន ឆេងហុង | អនុប្រធានមន្ទីរប្រៃសណីយ៍ ខេត្តកំពង់ចាម |
| ៧៧-លោក | វង្ស រិទ្ធី | អនុប្រធានមន្ទីរប្រៃសណីយ៍ ក្រុងព្រះសីហនុ |
| ៧៨-លោក | ឆាយ សុម៉េត | អនុប្រធានមន្ទីរប្រៃសណីយ៍ ខេត្តបាត់ដំបង |
| ៧៩-លោក | អ៊ឹម សុខុម | អនុប្រធានមន្ទីរប្រៃសណីយ៍ ក្រុងប៉ៃលិន |
| ៨០-លោក | ចាន់ ថុល | អនុប្រធានមន្ទីរប្រៃសណីយ៍ ខេត្តកំពង់ឆ្នាំង |

| | | |
|---|---|---|
| ៨១-លោក | អនន្ត អតិថជន | ប្រធានផ្នែកបៀវត្ស |
| ៨២-លោក | កែវ ម៉ុនធឿន | ប្រធានផ្នែកបុគ្គលិក |
| ៨៣-លោក | ថោង ម៉ុនធឿន | ប្រធានផ្នែកបណ្តុះបណ្តាល |
| ៨៤-លោក | រស់ សារុន | ប្រធានផ្នែកសន្តិសុខ |
| ៨៥-លោក | សុខ សាមឿន | មន្ត្រី |
| ៨៦-អ្នកស្រី | ហួត ចាន់បូផា | មន្ត្រី |
| ៨៧-លោក | អ៊ុច គីមនី | មន្ត្រី |
| ៨៨-អ្នកស្រី | សែម សុភារី | ប្រធានផ្នែក |
| ៨៩-អ្នកស្រី | យ៉ាង ចាន់ហាន់ | អនុប្រធានផ្នែក |
| ៩០-លោក | ជិន សុធឿន | ប្រធានផ្នែក |
| ៩១-លោក | តោគ ណារ៉ាន | ប្រធានផ្នែក |
| ៩២-អ្នកស្រី | ហឿង សុធី | ប្រធានផ្នែក |
| ៩៣-លោក | ហួត ចាន់យ៉ារ៉េត | ប្រធានសាខា |
| ៩៤-លោក | នាង ប៊ុណ្ណាឧត្តមា | ប្រធានផ្នែក |
| ៩៥-លោក | លីម ឆាយ | ប្រធានផ្នែក |
| ៩៦-លោក | ហែម ស៊ី | អនុប្រធានផ្នែក |
| ៩៧-អ្នកស្រី | យិន សារុំ | ប្រធានផ្នែក |
| ៩៨-លោក | ឡាយ គីមឡុង | ប្រធានផ្នែក |
| ៩៩-លោក | វ៉ាន់ សូម៉ាច | ប្រធានសាខា |
| ១០០-លោក | ឡុច សុផល | ប្រធានផ្នែក |
| ១០១-លោក | កែវ ស៊ីថា | មន្ត្រី |
| ១០២-លោក | ខាន់ សុភា | មន្ត្រី |
| ១០៣-លោក | ឃឹម សារ៉ាង | មន្ត្រី |
| ១០៤-លោក | គុល ញ៉ក់ | មន្ត្រី |
| ១០៥-អ្នកស្រី | ឱត្យ ស៊ីចំន្ទ | អនុប្រធានផ្នែក |

១០៦-អ្នកស្រី នង ធីតា មន្ត្រី
១០៧-លោក នួន គឿន មន្ត្រី
១០៨-លោក នៅ ឈុំ មន្ត្រី
១០៩-លោក ទ្រៀង ស៊ីណាត មន្ត្រី
១១០-អ្នកស្រី ម៉ូដេត មុនីឡថារ៉ា មន្ត្រី
១១១-លោក ម៉េង ជីវ មន្ត្រី
១១២-លោក លី សុខុន ប្រធានផ្នែក
១១៣-អ្នកស្រី អ៊ា វណ្ណារី មន្ត្រី
១១៤-លោក ថ៉ែន ធី មន្ត្រី
១១៥-អ្នកស្រី សរ ដារី មន្ត្រី
១១៦-លោក សន វី ប្រធានផ្នែក
១១៧-លោក សរ យ៉េន មន្ត្រី
១១៨-លោក ស៊ឹម ធី ប្រធានផ្នែក
១១៩-អ្នកស្រី ស្វួន ណារិទ្ធ មន្ត្រី
១២០-លោក ហៃ ហួរ អនុប្រធានផ្នែក
១២១-លោក ហែម យ៉ុន ប្រធានផ្នែក
១២២-អ្នកស្រី អៀង សុផា មន្ត្រី
១២៣-លោក យឹម ពន្លី មន្ត្រី
១២៤-លោក ប៉ែន វុទ្ធី ប្រធានផ្នែក
១២៥-លោក ស៊ឹម ស៊ី ប្រធានផ្នែក
១២៦-លោក ច័ន្ទ វិមល ប្រធានផ្នែក
១២៧-លោក មាស ថាវ មន្ត្រី
១២៨-អ្នកស្រី កែវ ចន្ថា ប្រធានផ្នែក
១២៩-លោក ហ៊ាន សី មន្ត្រី
១៣០-លោក សុខ ស៊ាន ប្រធានផ្នែក

១៣១-លោក **អ៊ុំ ទិចិត្រ** អនុប្រធានផ្នែក
១៣២-លោក **ឡេង គឹមធី** មន្ត្រី
១៣៣-លោក **ឆៀម គាត** ប្រធានផ្នែក
១៣៤-លោក **ឈិន ម៉ុនឡេង** ប្រធានផ្នែក
១៣៥-លោក **សុខ សុខវណ្ណារិទ្ធ** ប្រធានផ្នែក
១៣៦-លោក **ស្វាយ សុន** អនុប្រធានផ្នែក
១៣៧-អ្នកស្រី **ម៉ូ អារម៉េណា** មន្ត្រី
១៣៨-អ្នកស្រី **ចាម សុភី** មន្ត្រី
១៣៩-លោក **ឱ្ងច ទិចិត្រ** មន្ត្រី
១៤០-លោក **ម៉ាអុន ម៉ាអូណាត** មន្ត្រី
១៤១-លោក **ស្រុង ចន្ធី** មន្ត្រី
១៤២-អ្នកស្រី **អ៊ួង សម្បូរណ៌** មន្ត្រី
១៤៣-លោក **ម៉ៅ ពុទ្ធី** មន្ត្រី
១៤៤-អ្នកស្រី **ម៉ែន ច័ន្ទរស្មី** មន្ត្រី
១៤៥-លោក **សុទ្ធ ជ័យ** ប្រធានផ្នែកគណនេយ្យប្រៃសណីយ៍ ខេត្តកំពង់ធំ
១៤៦-អ្នកស្រី **ឈុន នារី** ប្រធានផ្នែករដ្ឋបាលប្រៃសណីយ៍ ខេត្តកំពង់ធំ
១៤៧-លោក **គុជ តារ៉ា** ប្រធានការិយាល័យប្រៃសណីយ៍ ខេត្តកំពង់ឆ្នាំង
១៤៨-អ្នកស្រី **ប្រាក់ ណារិទ្ធ** ប្រធានការិយាល័យប្រៃសណីយ៍ ខេត្តកំពង់ឆ្នាំង
១៤៩-អ្នកស្រី **ម៉ុត ណាទី** ប្រធានការិយាល័យប្រៃសណីយ៍ ខេត្តតាកែវ
១៥០-លោក **អ៊ី ចាន់** ប្រធានការិយាល័យប្រៃសណីយ៍ ខេត្តតាកែវ
១៥១-អ្នកស្រី **ច័ន្ទ រតនា** មន្ត្រីប្រៃសណីយ៍ ខេត្តកំពត
១៥២-អ្នកស្រី **ឱ្ងច ឌីណា** មន្ត្រីប្រៃសណីយ៍ ខេត្តកំពត
១៥៣-លោក **សេក រុន** ប្រធានផ្នែកប្រៃសណីយ៍ ក្រុងប៉ៃលិន
១៥៤-លោក **ឱ្ងច អាំងហេង** ប្រធានមជ្ឈមណ្ឌលប្រៃសណីយ៍ ខេត្តកណ្តាល
១៥៥-អ្នកស្រី **ឃឹម សេដា** អនុប្រធានផ្នែកប្រៃសណីយ៍ ខេត្តកណ្តាល

| | | |
|---|---|---|
| ១៥៦-លោក | **ចាន់ សុគន្ធ** | មន្ត្រី ខេត្តកំពង់ចាម |
| ១៥៧-លោក | **កែវ វុឌ្ឍី** | មន្ត្រីប្រៃសណីយ៍ ខេត្តកំពង់ចាម |
| ១៥៨-លោក | **ទូច វុទ្ធី** | មន្ត្រីប្រៃសណីយ៍ ខេត្តកោះកុង |
| ១៥៩-លោក | **ហ៊ី ខា** | មន្ត្រីប្រៃសណីយ៍.ខេត្តក្រចេះ |
| ១៦០-អ្នកស្រី | **ឃ្លី គីមអឿន** | មន្ត្រីប្រៃសណីយ៍ ខេត្តក្រចេះ |
| ១៦១-លោក | **អ៊ុច ម៉ៅ** | មន្ត្រីប្រៃសណីយ៍ ខេត្តស្ទឹងត្រែង |
| ១៦២-អ្នកស្រី | **សុខ គីមអាន** | មន្ត្រីប្រៃសណីយ៍ ខេត្តស្ទឹងត្រែង |
| ១៦៣-លោក | **ហុង ម៉ុនធី** | មន្ត្រីប្រៃសណីយ៍ ខេត្តសៀមរាប |
| ១៦៤-អ្នកស្រី | **ចាន់ សោភី** | មន្ត្រីប្រៃសណីយ៍ ខេត្តសៀមរាប |
| ១៦៥-អ្នកស្រី | **និត្យ ចិន្ដា** | មន្ត្រីប្រៃសណីយ៍ ខេត្តរតនគីរី |
| ១៦៦-លោក | **អ៊ន បូរ៉ាន់** | មន្ត្រីប្រៃសណីយ៍ ខេត្តរតនគីរី |
| ១៦៧-លោក | **យស់ វណ្ណៈ** | មន្ត្រីប្រៃសណីយ៍ ក្រុងព្រះសីហនុ |
| ១៦៨-លោក | **សាន វុធធឿន** | មន្ត្រីប្រៃសណីយ៍ ក្រុងព្រះសីហនុ |
| ១៦៩-លោក | **ផន សុផា** | មន្ត្រីប្រៃសណីយ៍ ខេត្តព្រៃវែង |
| ១៧០-អ្នកស្រី | **សៅ សាវឿន** | មន្ត្រីប្រៃសណីយ៍.ខេត្តព្រៃវែង |
| ១៧១-អ្នកស្រី | **រស់ សារិន** | មន្ត្រីប្រៃសណីយ៍ ខេត្តបាត់ដំបង |
| ១៧២-លោក | **សុខ រ៉ូ** | មន្ត្រីប្រៃសណីយ៍ ខេត្តបាត់ដំបង |
| ១៧៣-លោក | **គង់ ដារ៉ា** | មន្ត្រីប្រៃសណីយ៍ ខេត្តបន្ទាយមានជ័យ |
| ១៧៤-លោក | **ម៉ឹង សុខ** | មន្ត្រីប្រៃសណីយ៍ ខេត្តបន្ទាយមានជ័យ |
| ១៧៥-អ្នកស្រី | **វ័ន្ត សូម៉ាលី** | មន្ត្រីប្រៃសណីយ៍ ខេត្តស្វាយរៀង |
| ១៧៦-លោក | **ម៉ុំ សារ៉ែន** | មន្ត្រីប្រៃសណីយ៍ ខេត្តស្វាយរៀង |

**មាត្រា២ .-** រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី និងរដ្ឋមន្ត្រីក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី ២៩ ខែ មីនា ឆ្នាំ ២០០១

**នាយករដ្ឋមន្ត្រី**

**ហត្ថលេខា និងត្រា**

**ហ៊ុន សែន**

**អនុក្រឹត្យលេខ ១៣៥ អនក្រ.គត**

**ស្តីពីការជូនមេដាយស្ថាបនាជាតិ**

***

**រាជរដ្ឋាភិបាល**

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការប្រកាសអោយប្រើគ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់អភិបាលខេត្តព្រៃវែង

**សំរេច**

**មាត្រា១** ._ ត្រូវបានបំពាក់ **មេដាយស្ថាបនាជាតិ** តាមលំដាប់ថ្នាក់ ប្រគេន និងជូនសប្បុរសជន ដែលមានព្រះទ័យទុកដាក់ និងបរិច្ចាគថវិកាក្នុងការកសាងព្រះវិហារ និងសាលាបាលី វត្តពោធិខ្វាវ ឃុំថ្មពូន ស្រុកកញ្ជ្រៀច ខេត្តព្រៃវែង ដូចមានរាយព្រះនាម និងនាមខាងក្រោមនេះ ÷

**ក_មេដាយមាសស្ថាបនាជាតិ :**

-ព្រះតេជគុណ **ចាន់ អ៊ុច** ចៅអធិការវត្តពោធិខ្វាវ

**ខ_មេដាយប្រាក់ស្ថាបនាជាតិ :**

-លោក **សូ សំណាង** ទឹកប្រាក់ចំនួន ៥.២០០ ដុល្លារអាមេរិក

**គ_មេដាយសំរឹទ្ធស្ថាបនាជាតិ :**

-ពុទ្ធបរិស័ទចំណុះជើងវត្តពោធិខ្វាវ ទឹកប្រាក់ចំនួន ៣.២០០ ដុល្លារអាមេរិក

**មាត្រា២ ._** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងអភិបាលខេត្តព្រៃវែង ត្រូវអនុវត្តអនុក្រឹត្យនេះ ឱ្យទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី ២៩ ខែ មីនា ឆ្នាំ ២០០១

**នាយករដ្ឋមន្ត្រី**

**ហត្ថលេខា និងត្រា**

**ហ៊ុន សែន**

---

**អនុក្រឹត្យលេខ ១៣៦ អនក្រ.តត**

**ស្តីពីការជូនមេដាយស្ថាបនាជាតិ**

***

**រាជរដ្ឋាភិបាល**

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការប្រកាសប្រើគ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់អភិបាលខេត្តកំពង់ស្ពឺ

**សំរេច**

**មាត្រា១ ._** ត្រូវបានបំពាក់ **មេដាយស្ថាបនាជាតិ** តាមលំដាប់ថ្នាក់ ជូនសប្បុរសជនចំនួន ០២ រូប ដែលបានបរិច្ចាគថវិកាផ្ទាល់ខ្លួន ដើម្បីជួយកសាងសមិទ្ធផលនានាក្នុងវត្តភ្នំតាមោគ ឃុំស្រង់ ស្រុកគងពិសី ខេត្តកំពង់ស្ពឺ ដូចមានរាយនាមខាងក្រោមនេះ ÷

**ក_មេដាយមាសស្ថាបនាជាតិ :**

-លោក **លៀង ផន** និងអ្នកស្រី **ឈឹម ណារី** ថវិកាចំនួន ១០៥.៩៣២ ដុល្លារអាមេរិក

ខ-មេដាយប្រាក់ស្ថាបនាជាតិ:

-លោក ផេង លី និងអ្នកស្រី សេង ហុង ថវិកាចំនួន ៧.០២៧ ដុល្លារអាមេរិក

**មាត្រា២ .-** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និងអភិបាលខេត្តកំពង់ស្ពឺ ត្រូវអនុវត្តអនុក្រឹត្យនេះ ឱ្យទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី ២៩ ខែ មីនា ឆ្នាំ ២០០១

**នាយករដ្ឋមន្ត្រី**

**ហត្ថលេខា និងត្រា**

**ហ៊ុន សែន**

---

## អនុក្រឹត្យលេខ ១៣៧ អនក្រ.តត

## ស្តីពីការតែងតាំងមន្ត្រីរាជការ

***

## រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី

-បានឃើញអនុក្រឹត្យលេខ ៧០ អនក្រ.បក ចុះថ្ងៃទី ០៥ ខែ សីហា ឆ្នាំ ១៩៩៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅរបស់ក្រសួងពត៌មាន

-យោងតាមសំណើរបស់ក្រសួងពត៌មាន

## សំរេច

**មាត្រា១ .-** តែងតាំងលោក ព្រុំ ឈួន ជាប្រធាននាយកដ្ឋានថតរូប របស់អគ្គនាយកដ្ឋានទីភ្នាក់ងារសារពត៌មានកម្ពុជា " AKP " នៃក្រសួងពត៌មាន ។

មាត្រា២ .- រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងពត៌មាន រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង-ស្ថាប័នពាក់ព័ន្ធ អគ្គនាយកដ្ឋានទីភ្នាក់ងារសារពត៌មានកម្ពុជា "AKP" និងសាមីខ្លួន ត្រូវអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ២៩ ខែ មីនា ឆ្នាំ ២០០១

**នាយករដ្ឋមន្ត្រី**

**ហត្ថលេខា និងត្រា**

**ហ៊ុន សែន**

## ២. សេចក្តីសំរេច

រាជធានីភ្នំពេញ ថ្ងៃទី ២៧ ខែ មីនា ឆ្នាំ ២០០១

**សេចក្តីសំរេចលេខ ១៤ សសរ**

**ស្តីពីការបង្កើតគណៈកម្មការដោះស្រាយគោលនយោបាយ**

**សំណង់ស្នាក់នៅបណ្តោះអាសន្នក្នុងមជ្ឈមណ្ឌលកុលាបទី១**

***

**រាជរដ្ឋាភិបាល**

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រមលេខ នស/រកម/០៩៩៩/១០ ចុះថ្ងៃទី ១៨ ខែ កញ្ញា ឆ្នាំ ១៩៩៩ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងកិច្ចការនារី និងអតីតយុទ្ធជន

-បានឃើញអនុក្រឹត្យលេខ ៨៨ អនក្រ.បក ចុះថ្ងៃទី ០៧ ខែ តុលា ឆាំ ១៩៩៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅរបស់ក្រសួងកិច្ចការនារី និងអតីតយុទ្ធជន

-យោងតាមសំណូមពរការងារចាំបាច់របស់រាជរដ្ឋាភិបាល

**សំរេច**

**ប្រការ១ :**

បង្កើតគណៈកម្មការ ដើម្បីដោះស្រាយគោលនយោបាយសំណង់ស្នាក់នៅបណ្តោះអាសន្នក្នុងមណ្ឌលកូលាបទី ១ ដែលមានសមាសភាពដូចខាងក្រោម :

| | | | |
|---|---|---|---|
| ១-លោកជំទាវ | **យូ អយ** | រដ្ឋលេខាធិការ ក្រសួងកិច្ចការនារី និងអតីតយុទ្ធជន | ប្រធាន |
| ២-ឯកឧត្តម | **ម៉ិន សម** | អនុរដ្ឋលេខាធិការ ក្រសួងសេដ្ឋកិច្ច ហិរញ្ញវត្ថុ | អនុប្រធាន |
| ៣-ឯកឧត្តម | **កើត សារ៉េត** | អនុរដ្ឋលេខាធិការ ក្រសួងរៀបចំដែនដីនគរូបនីយកម្ម និងសំណង់ | អនុប្រធាន |
| ៤-ឯកឧត្តម | **សេង លឹមនៅ** | អនុរដ្ឋលេខាធិការ ទីស្តីការគណៈរដ្ឋមន្ត្រី | សមាជិក |
| ៥-ឯកឧត្តម | **ចេវ គឹមហេង** | អភិបាលរងរាជធានីភ្នំពេញ | សមាជិក |
| ៦-លោក | **អ៊ុច សារូ** | នាយករងខុទ្ទកាល័យ ក្រសួងមហាផ្ទៃ | សមាជិក |
| ៧-លោក | **ទៀវ សាគន្ធ** | អគ្គនាយករងរដ្ឋបាល និងហិរញ្ញវត្ថុ នៃក្រសួងសង្គមកិច្ចការងារបណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា | សមាជិក |

**ប្រការ២ :**

គណៈកម្មការនេះ មានភារកិច្ចដូចខាងក្រោម :

-ដោះស្រាយទីតាំងមជ្ឈមណ្ឌលកូលាបទី១ ដោយលើកទិសដៅការឱ្យមានប្រសិទ្ធភាពយកពលរដ្ឋដែលស្នាក់នៅបណ្តោះអាសន្នចេញពីមជ្ឈមណ្ឌលកូលាបទី១ ដើម្បីធ្វើជាទីស្តីការរបស់ក្រសួងកិច្ចការនារី និងអតីតយុទ្ធជន និងមជ្ឈមណ្ឌលអភិវឌ្ឍន៍ស្ត្រី ។

-ស្រាវជ្រាវស្ថិតិពិតប្រាកដ ដោយបែងចែកតាមប្រភេទអ្នកស្នាក់នៅក្នុងបរិវេណមជ្ឈមណ្ឌលកូលាបទី១ ទាំងមូល តាមតំណាក់កាលនៃពេលវេលាស្នាក់នៅ ហើយធ្វើការវាយតំលៃឱ្យបានសមស្របលើការប៉ះពាល់ដល់សំណង់ ដើម្បីកំណត់ប្រភេទនៃការដោះស្រាយគោលនយោបាយឧបត្ថម្ភ ដាក់ជូនរាជរដ្ឋាភិបាលពិនិត្យសំរេច ។

-លើកគំរោងអំពីតំរូវការថវិកាស្នើសុំគោលការសំរេចពីរាជរដ្ឋាភិបាល ដើម្បីធ្វើការដោះស្រាយគោលនយោបាយដល់ប្រជាពលរដ្ឋ ដែលបានរស់នៅបណ្តោះអាសន្នក្នុងមជ្ឈមណ្ឌលកូលាបទី១ ក្នុងគោលដៅធ្វើការជួសជុល និងសាងសង់ថ្មី ទីស្តីការរបស់ក្រសួងកិច្ចការនារី និងអតីតយុទ្ធជន ។

-ធ្វើរបាយការណ៍សរុបអំពីលទ្ធផល ការងាររបស់គណៈកម្មការជូនរាជរដ្ឋាភិបាល ។

**ប្រការ៣ :**

គណៈកម្មការមានសិទ្ធិបង្កើតអនុគណៈកម្មការ ឬក្រុមការងារមួយចំនួន ព្រមទាំងមានមន្ត្រីជំនាញ ដើម្បីជំនួយការតាមការចាំបាច ។ គណៈកម្មការនេះមានសិទ្ធិប្រើប្រាស់ត្រារបស់ក្រសួងកិច្ចការនារី និងអតីតយុទ្ធជន ចំពោះបណ្តាលិខិតឯកសារជាផ្លូវការពាក់ព័ន្ធនឹងការងារនេះ ។

**ប្រការ៤ :**

សមាជិកគណៈកម្មការត្រូវចូលរួមប្រជុំតាមការអញ្ជើញរបស់ប្រធានគណៈកម្មការ ។

**ប្រការ៥ :**

គណៈកម្មការនេះត្រូវរំសាយជាស្វ័យប្រវត្តិក្រោយពេលដែលបានបញ្ចប់ភារកិច្ចរបស់ខ្លួន ។

**ប្រការ៦ :**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា រដ្ឋមន្ត្រីក្រសួងកិច្ចការនារី និងអតីតយុទ្ធជន អភិបាលរាជធានីភ្នំពេញ និងសាមីជនដូចមានក្នុងប្រការ១ ត្រូវអនុវត្តតាមសេចក្តីសំរេច ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

**នាយករដ្ឋមន្ត្រី**

**ហត្ថលេខា និងត្រា**

**ហ៊ុន សែន**

# II- ការងារមណ្ឌលក្រសួង

## ១_ធនាគារជាតិនៃកម្ពុជា

រាជធានីភ្នំពេញ ថ្ងៃទី ៣០ ខែ មីនា ឆ្នាំ ២០០១

**ប្រកាសលេខ ធ ៥_០១_៦៥ ប្រក**

**ស្តីពីការដាក់អោយប្រើប្រាស់មូលប្បទានប័ត្រគំរូថ្មី**

****

**ទេសាភិបាល ធនាគារជាតិ នៃកម្ពុជា**

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/២៧ ចុះថ្ងៃទី ២៦ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃធនាគារជាតិនៃកម្ពុជា

-បានឃើញព្រះរាជក្រឹត្យ ជស/រកត/០៣៩៨/៨៥ ចុះថ្ងៃទី ១០ ខែ មីនា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងឯកឧត្តម ជា ចាន់តូ ជាអគ្គទេសាភិបាលនៃធនាគារជាតិនៃកម្ពុជា

-បានឃើញការចាំបាច់ត្រូវដាក់ឱ្យប្រើប្រាស់នូវមូលប្បទានប័ត្រតាមគំរូថ្មី អោយសមស្របតាមស្តង់ដារអន្តរជាតិ

-តាមសំណើរបស់អគ្គនាយកដ្ឋាន

**សំរេច**

**ប្រការ១ :**

ដាក់ឱ្យប្រើប្រាស់មូលប្បទានប័ត្រតាមគំរូបោះពុម្ពថ្មី ២ប្រភេទគឺ មូលប្បទានប័ត្រអតិថិជនសំរាប់ចេញឱ្យម្ចាស់គណនីនៅធនាគារកណ្តាល និងមូលប្បទានប័ត្រធនាគារ សំរាប់ធនាគារកណ្តាលផ្ទាល់ ក្រោមលក្ខណៈសំគាល់ ដូចមានក្នុងឧបសម្ព័ន្ធភ្ជាប់មកជាមួយប្រកាសនេះ ។

**ប្រការ២ :**

មូលប្បទានប័ត្រទាំង ២ ប្រភេទ ដែលមានចែងក្នុងប្រការ ១ ត្រូវដាក់ឱ្យប្រើជំនួសមូលប្បទានប័ត្រតាមគំរូចាស់ទាំងឡាយរបស់ធនាគារជាតិ នៃកម្ពុជា ។

បណ្ណសារដ្ឋានជាតិ
ថ្ងៃទី____ខែ____ឆ្នាំ____

**ប្រការ៣ :**

អគ្គនាយកដ្ឋាន អគ្គលេខាធិការដ្ឋាន អគ្គបេឡា អគ្គាធិការដ្ឋាន គ្រប់នាយកដ្ឋាន អង្គភាព និងគ្រប់គ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុ នៅក្រោមឱវាទ និងក្រោមអាណាព្យាបាលធនាគារជាតិនៃ កម្ពុជា ត្រូវអនុវត្តម៉ឺងម៉ាត់នូវប្រកាសនេះ តាមភារកិច្ចរៀងៗខ្លួន ។

**ប្រការ៤ :**

ប្រកាសនេះមានប្រសិទ្ធភាពអនុវត្ត ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

**ទេសាភិបាល**

**ហត្ថលេខា និងត្រា**

**ជា ចាន់តូ**

**ឧបសម្ព័ន្ធ**

**លក្ខណៈសំគាល់មូលប្បទានប័ត្រថ្មី**

(ផ្អែកតាមប្រការ ១ នៃប្រកាសស្តីពីការដាក់ឱ្យប្រើប្រាស់មូលប្បទានប័ត្រគំរូថ្មី លេខ ធ៥០១-៦៥ ប្រក. ចុះថ្ងៃទី ៣០ មីនា ២០០១ របស់ធនាគារជាតិនៃកម្ពុជា

**១-មូលប្បទានប័ត្រអតិថិជន** មានលក្ខណៈសំគាល់ដូចតទៅ :

**ក-លក្ខណៈទូទៅ :**

-បណ្តោយ ១៦៦ មម ទទឹង ៨៣ មម ពណ៌ចំបងគឺពណ៌ផ្ទៃមេឃ និងពណ៌ត្រួយចេក ។

-នៅប៉ែកខាងលើមូលប្បទានប័ត្រ ផ្នែកខាងឆ្វេងមានអក្សរខ្មែរ និងអក្សរអង់គ្លេសពណ៌ខៀវ "**ធនាគារជាតិនៃកម្ពុជា**" និង " National Bank of Cambodia " ព្រមទាំងអាស័យដ្ឋាន " ទីស្នាក់ការ ២២-២៤ មហាវិថីព្រះនរោត្តម ភ្នំពេញ" និង " 22-24 Preah Norodom Blvd, Phnom Penh " ចំណែកឯផ្នែកខាងស្តាំ មានផ្ទៃបោះពុម្ពពណ៌ពងមាន់ជារាងពងក្រពើ ហើយមានអក្សរ " ថ្ងៃ ខែ ឆ្នាំ " និង " Date...... " នៅពីលើនោះ ។

-នៅប៉ែកកណ្តាលនៃសន្លឹកមូលប្បទានប័ត្រ ផ្នែកខាងឆ្វេងមានអក្សរខ្មែរ និងអក្សរអង់គ្លេស "បើកឱ្យ /Pay to " និង " ចំនួនទឹកប្រាក់ /The sum of " និងមានបន្ទាត់ចំនួនបីខ្សែបន្តពីអក្សរទាំងនោះ សំរាប់ចុះចំនួនទឹកប្រាក់ជាអក្សរ ឯផ្នែកខាងស្តាំវិញមានប្រអប់រាងបួនជ្រុងទ្រវែងមួយ ដែលខាងក្នុងនោះ

មានបន្ទាត់មួយផ្គុំឡើងដោយចំណុចពងត្រីជាកន្លែងសំរាប់ចុះចំនួនទឹកប្រាក់ជាលេខ ហើយមានអក្សរខ្មែរ និងអក្សរអង់គ្លេស "ឬអ្នកកាន់ /or Bearer " នៅពីលើប្រអប់ និង " **ហត្ថលេខា** /Signature " នៅពីក្រោមប្រអប់ ។

-នៅប៉ែកខាងក្រោមនៃសន្លឹកមូលប្បទានប័ត្រ មានបន្ទាត់ឆ្នូរមួយកាត់សន្ធឹងពីចុងខាងឆ្វេងដល់ចុងខាងស្តាំ ។ តាមបណ្តោយបន្ទាត់នោះ ផ្នែកខាងឆ្វេង ខាងក្រោមបន្ទាត់មានអក្សរ "មូលប្បទានប័ត្រលេខ" និង " Cheque " ដែលមានបោះពុម្ពដោយទឹកខ្មៅពណ៌ក្រហម នូវលេខ-មាលានៃសន្លឹកមូលប្បទានប័ត្រនៅពីមុខនោះ ឯផ្នែកកណ្តាលខាងលើបន្ទាត់មានអក្សរ *"មិនត្រូវចុះហត្ថលេខាក្រោមបន្ទាត់/No Signature below this line "* និងខាងក្រោមបន្ទាត់មានអក្សរ "លេខគណនី " និង "Account No" ជាកន្លែងសំរាប់ចុះឈ្មោះ និងលេខគណនីអតិថិជន ។

ក្រៅពីលក្ខណៈសំគាល់ទូទៅដូចបានរៀបរាប់ខាងលើ នៅលើសន្លឹកមូលប្បទានប័ត្រ ចាប់ពីចំណុចកណ្តាលទៅខាងឆ្វេងមានរំលេចរូបសញ្ញាធនាគារជាតិនៃកម្ពុជា ដែលមានទំហំប្រហែល ១/៣ នៃសន្លឹកមូលប្បទានប័ត្រ ។

**ខ-លក្ខណៈពិសេស :**

-នៅប៉ែកកណ្តាលនៃសន្លឹកមូលប្បទានប័ត្រ បន្ទាត់ចំនួនបីខ្សែដែលតពីមុខអក្សរ "បើកឱ្យ/Pay to" និង "ចំនួនទឹកប្រាក់/The sum of" គឺជាខ្សែបន្ទាត់ផ្គុំឡើងដោយអក្សរតូចល្អិត "NATIONAL BANK OF CAMBODIA" ដែលអាចអានបានពេលដែលឆ្លុះមើលដោយកែវពង្រីក ។

-នៅផ្នែកកណ្តាលនៃរង្វង់រាងពងក្រពើមានអក្សរ "NBC" បោះពុម្ពដោយទឹកខ្មៅអទិស្សមាន ដែលអក្សរនេះអាចមើលឃើញតែក្រោមរស្មីពណ៌ស្វាយប៉ុណ្ណោះ ។

-នៅក្នុងផ្ទៃទាំងមូលនៃកូនប្រអប់រាងបួនជ្រុងទ្រវែង ដែលសំរាប់ចុះចំនួនទឹកប្រាក់ជាលេខ និងនៅបរិវេណគំនូសបន្ទាត់បីខ្សែ ដែលជាកន្លែងសំរាប់ចុះចំនួនទឹកប្រាក់ជាអក្សរ មានផ្ទៃបោះពុម្ពរាងបួនជ្រុងទ្រវែងពីរដាច់ពីគ្នា ដែលប្រើទឹកខ្មៅអទិស្សមាន ហើយផ្ទៃបោះពុម្ពទាំងពីរនេះ មានចំណាំងពន្លឺក្រោមរស្មីពណ៌ស្វាយ ។

-លេខ-មាលានៃមូលប្បទានប័ត្រត្រូវបានបោះពុម្ពដោយទឹកថ្នាំពណ៌ក្រហម ដែលមានចំណាំងពន្លឺក្រោមរស្មីពណ៌ស្វាយ ។

**២-មូលប្បទានប័ត្រធនាគារ** (BANKER'S CHEQUE) មានលក្ខណៈសំគាល់ដូចតទៅ :

**ក‑លក្ខណៈទូទៅ :**

-បណ្ដោយ ១៦៦ មម ទទឹង ៨៣ មម ពណ៌ចំបង គឺពណ៌លឿង និងពណ៌ផ្ទៃមេឃ ។

-នៅប៉ែកខាងលើមូលប្បទានប័ត្រ ផ្នែកខាងឆ្វេងមានអក្សរខ្មែរ និងអក្សរអង់គ្លេសពណ៌ខៀវ "**ធនាគារជាតិនៃកម្ពុជា**" និង " National Bank of Cambodia " ព្រមទាំងអាស័យដ្ឋាន " ទីស្នាក់ការ ២២-២៤ មហាវិថីព្រះនរោត្តម ភ្នំពេញ" និង " 22-24 Preah Norodom Blvd, Phnom Penh " ចំណែកឯផ្នែកខាងស្ដាំ មានផ្ទៃបោះពុម្ពពណ៌លឿងជារាងពងក្រពើ ហើយមានអក្សរ " ថ្ងៃ ខែ ឆ្នាំ " និង " Date....... " នៅពីលើនោះ ។

-នៅប៉ែកកណ្ដាលនៃសន្លឹកមូលប្បទានប័ត្រ ផ្នែកខាងឆ្វេងមានអក្សរខ្មែរ និងអក្សរអង់គ្លេស "បើកឱ្យ /Pay to " និង " ចំនួនទឹកប្រាក់ /The sum of " និងមានបន្ទាត់ចំនួនបីខ្សែបន្តពីអក្សរទាំងនោះសំរាប់ចុះចំនួនទឹកប្រាក់ជាអក្សរ ឯផ្នែកខាងស្ដាំវិញមានប្រអប់រាងបួនជ្រុងទ្រវែងមួយ ដែលខាងក្នុងនោះមានបន្ទាត់មួយផ្គុំឡើងដោយចំណុចពងត្រីជាកន្លែងសំរាប់ចុះចំនួនទឹកប្រាក់ជាលេខ ហើយមានអក្សរខ្មែរ និងអក្សរអង់គ្លេស "ឬអ្នកកាន់ "ហត្ថលេខាអ្នកទទួលសិទ្ធិ Authorized Singature " នៅពីក្រោមប្រអប់ ។

-នៅប៉ែកខាងក្រោមនៃសន្លឹកមូលប្បទានប័ត្រ មានបន្ទាត់ឆ្នូតមួយកាត់សន្លឹងពីចុងខាងឆ្វេងដល់ចុងខាងស្ដាំ ។ តាមបណ្ដោយបន្ទាត់នោះ ផ្នែកខាងឆ្វេង ខាងក្រោមបន្ទាត់មានអក្សរ "មូលប្បទានប័ត្រលេខ" និង " Cheque " ហើយមានបោះពុម្ពដោយទឹកខ្មៅពណ៌ក្រហម នូវលេខ-មាលានៃសន្លឹកមូលប្បទានប័ត្រនៅពីមុខនោះ ។ ឯផ្នែកកណ្ដាលខាងលើបន្ទាត់មានអក្សរ *"មិនត្រូវចុះហត្ថលេខាក្រោមបន្ទាត់/No Signature below this line* "។

ក្រៅពីលក្ខណៈសំគាល់ទូទៅដូចបានរៀបរាប់ខាងលើ នៅលើសន្លឹកមូលប្បទានប័ត្រ ចាប់ពីចំណុចកណ្ដាលទៅខាងឆ្វេងមានរំលេចរូបសញ្ញាធនាគារជាតិនៃកម្ពុជា ដែលមានទំហំប្រហែល ១/៣ នៃសន្លឹកមូលប្បទានប័ត្រ ។

**ខ‑លក្ខណៈពិសេស :**

-នៅប៉ែកកណ្ដាលនៃសន្លឹកមូលប្បទានប័ត្រ បន្ទាត់ចំនួនបីខ្សែដែលតពីមុខអក្សរ "បើកឱ្យ/Pay to" និង "ចំនួនទឹកប្រាក់/The sum of" គឺជាខ្សែបន្ទាត់ផ្គុំឡើងដោយអក្សរតូចល្អិត "NATIONAL BANK OF CAMBODIA" ដែលអាចអានបានពេលដែលឆ្លុះមើលដោយកែវពង្រីក ។

-នៅផ្ទៃកណ្តាលនៃរង្វង់រាងពងក្រពើមានអក្សរ "NBC" បោះពុម្ពដោយទឹកខ្មៅអទិស្សមាន ដែលអក្សរនេះអាចមើលឃើញតែក្រោមរស្មីពណ៌ស្វាយប៉ុណ្ណោះ ។

-នៅក្នុងផ្ទៃទាំងមូលនៃកូនប្រអប់រាងបួនជ្រុងទ្រវែង ដែលសំរាប់ចុះចំនួនទឹកប្រាក់ជាលេខ និងនៅបរិវេណគំនូសបន្ទាត់បីខ្សែ ដែលជាកន្លែងសំរាប់ចុះចំនួនទឹកប្រាក់ជាអក្សរ មានផ្ទៃបោះពុម្ពរាងបួនជ្រុងទ្រវែងពីរដាច់ពីគ្នា ដែលប្រើទឹកខ្មៅអទិស្សមាន ហើយផ្ទៃបោះពុម្ពទាំងពីរនេះ មានចំណាំងពន្លឺក្រោមរស្មីពណ៌ស្វាយ ។

-លេខ-មាលានៃមូលប្បទានប័ត្រត្រូវបានបោះពុម្ពដោយទឹកថ្នាំពណ៌ក្រហម ដែលមានចំណាំងពន្លឺក្រោមរស្មីពណ៌ស្វាយ ។

---

រាជធានីភ្នំពេញ ថ្ងៃទី ៣០ ខែ មីនា ឆ្នាំ ២០០១

## ប្រកាសលេខ ធ ៧-០១-៦៦ ប្រក

## ស្តីពីការដកហូតអាជ្ញាប័ណ្ណ និងជំរះបញ្ជីធនាគារកសិករ

## ថៃ មហាជន ចំកាត់ សាខា ភ្នំពេញ

****

## ទេសាភិបាល ធនាគារជាតិ នៃកម្ពុជា

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/២៧ ចុះថ្ងៃទី ២៦ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃធនាគារជាតិនៃកម្ពុជា

-បានឃើញព្រះរាជក្រមលេខ នស/រកម/១១៩៩/១៣ ចុះថ្ងៃទី ១៨ ខែ វិច្ឆិកា ឆ្នាំ ១៩៩៩ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីគ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុ

-បានឃើញព្រះរាជក្រឹត្យ ជស/រកត/០៣៩៨/៨៥ ចុះថ្ងៃទី ១០ ខែ មីនា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងឯកឧត្តម ជា ចាន់តូ ជាអគ្គទេសាភិបាលនៃធនាគារជាតិនៃកម្ពុជា

-បានឃើញលិខិតស្នើសុំជំរះបញ្ជី ដោយស្ម័គ្រចិត្តតាមលិខិត ចុះថ្ងៃទី ០៧ ខែ ធ្នូ ឆ្នាំ ២០០០ របស់ធនាគារកសិករ ថៃ មហាជន ចំកាត់ សាខា ភ្នំពេញ

-បានឃើញអាជ្ញាប័ណ្ណលេខ ៣៣ ចុះថ្ងៃទី ១៥ ខែ សីហា ឆ្នាំ ១៩៩៨ ដែលចេញឱ្យធនាគារកសិករ ថៃ មហាជន ចំកាត់ សាខា ភ្នំពេញ

-យោងតាមសំណើរបស់នាយកដ្ឋានត្រួតពិនិត្យ

## សម្រេច

**ប្រការ១ :**

ដក អាជ្ញាប័ណ្ណប្រកបអាជីវកម្មធនាគារពាណិជ្ជលេខ ៣៣ ចុះថ្ងៃទី ១៥ ខែ សីហា ឆ្នាំ ១៩៩៨ ដែលចេញឱ្យធនាគារកសិករ ថៃ មហាជន ចំកាត់ សាខា ភ្នំពេញ ។

**ប្រការ២ :**

ធនាគារកសិករ ថៃ មហាជន ចំកាត់ សាខា ភ្នំពេញត្រូវជ្រើសតាំងអ្នកជំរះបញ្ជីក្នុងរយៈពេល ៦០ថ្ងៃធ្វើការពីបញ្ជីក្រុមហ៊ុនសួនការគណនីប្រតិស្រុត ។ រាល់សោហ៊ុយចំណាយជាបន្ទុករបស់ធនាគារកសិករ ថៃ មហាជន ចំកាត់ សាខា ភ្នំពេញ ។

**ប្រការ៣ :**

ក្នុងករណីធនាគារកសិករ ថៃ មហាជន ចំកាត់ សាខា ភ្នំពេញ មិនបានគោរពតាមកាលកំណត់ខាងលើ ធនាគារជាតិនៃកម្ពុជានឹងធ្វើការតែងតាំងអ្នកជំរះបញ្ជីតាមការកំណត់មាត្រា ៥២ នៃច្បាប់ស្តីពីគ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុ ។

**ប្រការ៤ :**

អ្នកជំរះបញ្ជីមានភារកិច្ច :

-រៀបចំជាបន្ទាន់នូវការវាយតំលៃធនាគារ

-គ្រប់គ្រងកិច្ចការប្រចាំថ្ងៃ ដោយការពារឱ្យបានជាអតិបរមានូវសាធនភាពរបស់ធនាគារ និងរក្សាសិទ្ធិរបស់អ្នកផ្ញើប្រាក់ និងឥណទាយក ។

-ជំរះបញ្ជីទ្រព្យសកម្ម និងសងបំណុលរបស់ធនាគារក្រោមការត្រួតពិនិត្យរបស់ធនាគារជាតិនៃកម្ពុជា ។

**ប្រការ៥ :**

អគ្គនាយកដ្ឋាន អគ្គលេខាធិការដ្ឋាន អគ្គបេឡា អគ្គាធិការដ្ឋាន គ្រប់នាយកដ្ឋាន អង្គភាពគ្រប់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុនៅក្រោមឱវាទ និងក្រោមអាណាព្យាបាលធនាគារជាតិនៃ កម្ពុជាត្រូវអនុវត្តម៉ឺងម៉ាត់នូវប្រកាសនេះ តាមភារកិច្ចរៀង១ខ្លួន ។

**ប្រការ៦ :**

ប្រកាសនេះមានប្រសិទ្ធភាពអនុវត្ត ចាប់តាំងពីថ្ងៃចុះហត្ថលេខាតទៅ ។

**ទេសាភិបាល**

**ហត្ថលេខា និងត្រា**

**ជា ចាន់តូ**

## ២_ទីស្តីការរដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល

## ប្រកាស

រាជធានីភ្នំពេញ ថ្ងៃទី ២៦ ខែ មីនា ឆ្នាំ ២០០១

**ប្រកាសលេខ ២១២ ឧរថកឧ.ប្រក**

**រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល**

***

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ របស់ព្រះករុណាព្រះបាទសម្តេចនរោត្តសីហនុ ព្រះចៅក្រុងកម្ពុជាធិបតី ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា ។

-បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៥ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ។

-បានឃើញអនុក្រឹត្យលេខ ៣៥ អនក្រ.បក ចុះថ្ងៃទី ២៦ ខែ មេសា ឆ្នាំ ១៩៩៩ របស់រាជរដ្ឋាភិបាលកម្ពុជា ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅរបស់ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល

-បានឃើញលិខិតលេខ ៣៨៤/០១ គ.រ.ក ចុះថ្ងៃទី ០២-០២-២០០១ របស់ក្រុមប្រឹក្សា អភិវឌ្ឍន៍កម្ពុជា ។

-បានឃើញលិខិតលេខ ៧៦ សណប.ស្ត វហ.បស្ត ចុះថ្ងៃទី ២២-០១-២០០១ របស់សាលា ក្រុងភ្នំពេញ ។

-បានឃើញលិខិតលេខ ១៣៨ ឆត.ស ចុះថ្ងៃទី ២៣-០១-២០០១ របស់សាលាក្រុងភ្នំពេញ ។

-យោងពាក្យស្នើរបស់ក្រុមហ៊ុន ជ្រេហ្គន រីវើរីសស (ខេមបូឌា) ចុះថ្ងៃទី ០៦ -៣-២០០១។

## សំរេច

**ប្រការ១** : អនុញ្ញាតឱ្យក្រុមហ៊ុនដ្រេហ្គុន រីវើរីសស (ខេមបូឌា) (DRAGON RIVER RESOURCES (CAMBODIA) LTD.) តំណាងដោយលោក IYER SESHADRI RISHINARADA MANGALAM VENKATESWARAN សញ្ជាតិឥណ្ឌា ភេទប្រុស អាយុ ៦៤ ឆ្នាំ កាន់លិខិតឆ្លងដែន Z 1053559 ចុះថ្ងៃទី ១៥-៤-៩៩ បង្កើតរោងចក្រផលិត សន្ទឹកស័ង្កសី ដែលមានផ្លាកឈ្មោះថា " ដ្រេហ្គុន រី វើរ រី សស (ខេមបូឌា)" មានទីតាំងស្ថិតនៅផ្លូវមុនិរ៉េត ភូមិដំណាក់ធំ សង្កាត់ស្ទឹងមានជ័យ ខ័ណ្ឌមានជ័យ រាជធានីភ្នំពេញ ។

**ប្រការ២** : ក្រុមហ៊ុនត្រូវរៀបចំរោងចក្រទៅតាមប្លង់ ដែលបានតំកល់ទុកនៅក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ។

**ប្រការ៣** : រោងចក្រនេះត្រូវបានអនុញ្ញាតឱ្យផលិត "សន្ទឹកស័ង្កសី " ទៅតាមគំរូដែលតំកល់ទុក ហើយត្រូវធ្វើរបាយការណ៍ប្រចាំខែ អំពីស្ថានភាពផលិតកម្មរបស់រោងចក្រ ជូនក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ។

**ប្រការ៤** : ក្រុមហ៊ុនត្រូវលើកបង្ហាញ "ផ្លាកឈ្មោះរោងចក្រ" របស់ខ្លួនជាអក្សរខ្មែរមានទំហំធំជាង និងនៅពីលើអក្សរផ្សេងទៀត នៅកន្លែងដែលងាយមើលឃើញនៅខាងមុខរោងចក្រ ។

**ប្រការ៥** : ការពង្រីកផលិតកម្ម ផ្លាស់ប្តូរមុខផលិតផល ផ្លាស់ប្តូរទីតាំងរោងចក្រ ឬបង្កើតសាខារោងចក្រ ក្រុមហ៊ុនត្រូវសុំការអនុញ្ញាតពីក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ។

**ប្រការ៦** : រាល់ការនាំចេញនូវផលិតផលសំរេច ក្រុមហ៊ុនត្រូវស៊ើវិញ្ញាបនប័ត្របញ្ជាក់ផលិតកម្ម ពីក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ។

**ប្រការ៧** : ក្រុមហ៊ុនត្រូវធានាសុវត្ថិភាពឧស្សាហកម្ម និងគុណភាពផលិតផល ព្រមទាំងត្រូវគោរពឱ្យបានម៉ឺងម៉ាត់ នូវច្បាប់ស្តីពីការងារ ច្បាប់ស្តីពីកិច្ចការពារបរិស្ថាន និងការគ្រប់គ្រងធនធានធម្មជាតិ និងច្បាប់ បទប្បញ្ញត្តិនានា ដែលពាក់ព័ន្ធនឹងផលិតកម្ម អាជីវកម្មរបស់ក្រុមហ៊ុន ។

**ប្រការ៨** : ក្នុងករណីប្រព្រឹត្តល្មើសច្បាប់ ឬល្មើសចំពោះប្រការណាមួយដែលបានចែងខាងលើ ប្រកាសនេះនឹងត្រូវដកហូតវិញដោយគ្មានសំណងឡើយ ។

**ប្រការ៩ :** អគ្គនាយកឧស្សាហកម្ម នៃក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ប្រធានមន្ទីរឧស្សាហកម្ម រ៉ែ និងថាមពលរាជធានីភ្នំពេញ និងប្រធានក្រុមហ៊ុនជ្រៃហ្គូនវីរើរីសស (ខេមបូឌា) ត្រូវអនុវត្តប្រកាសនេះ តាមមុខការរៀងៗខ្លួន ។

**ប្រការ១០:** ប្រកាសនេះមានអនុភាពគតិយុត្ត ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

**ហត្ថលេខា និងត្រា**

**សុយ សែម**

រាជធានីភ្នំពេញ ថ្ងៃទី ៣០ ខែ មីនា ឆ្នាំ ២០០១

## ប្រកាសលេខ ២២៩ ឧរថម.ប្រក

## ស្តីអំពីស្តង់ដារឧស្សាហកម្មកម្ពុជា CS 022-2001

## "គោលការណ៍ទូទៅនៃប្រព័ន្ធចេញវិញ្ញាបនបត្របញ្ជាក់ផលិតផលដោយភាគីទី ៣"

***

## រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា

-បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៥ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ស្តីពីការបង្កើតក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល

-បានឃើញព្រះរាជក្រមលេខ នស/រកម/០៦០០/០០១ ចុះថ្ងៃទី ២១ ខែ មិថុនា ឆ្នាំ ២០០០ ច្បាប់ ស្តីពីការគ្រប់គ្រងគុណភាព សុវត្ថិភាពលើផលិតផលទំនិញ និងសេវា

-បានឃើញអនុក្រឹត្យលេខ ៣៥ អនក្រ.បក ចុះថ្ងៃទី ២៦ ខែ មេសា ឆ្នាំ ១៩៩៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅរបស់ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល.

-បានឃើញអនុក្រឹត្យលេខ 04 អនក្រ ចុះថ្ងៃទី ២៦ ខែ កុម្ភៈ ឆ្នាំ ១៩៩២ ស្ដីពីការគ្រប់គ្រង និងការត្រួតពិនិត្យគុណភាពផលិតផលឧស្សាហកម្ម-សិប្បកម្ម

-បានឃើញប្រកាសលេខ ៩៦៣ នប.ប្រក ចុះថ្ងៃទី ២៩ ខែ វិច្ឆិកា ឆ្នាំ ១៩៩៩ ស្ដីពីការចុះបញ្ជីផលិតផលឧស្សាហកម្មរបស់ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល

-យោងតាមស្ថានភាពជាក់ស្ដែងនាពេលបច្ចុប្បន្ន

**សំរេច**

**ប្រការ១** : បង្កើតស្តង់ដារឧស្សាហកម្មកម្ពុជា CS 002-2001 ស្ដីពី "**គោលការណ៍ទូទៅ នៃប្រព័ន្ធចេញវិញ្ញាបនប័ត្របញ្ជាក់ផលិតផល ដោយភាគីទី ៣**" សំរាប់អនុវត្តចំពោះការចេញវិញ្ញាបនប័ត្របញ្ជាក់ផលិតផល ដែលចែងឡើងដើម្បីធ្វើឱ្យមានភាពសមស្រប និងឆ្លើយតបទៅនឹងសេចក្ដី ត្រូវការរបស់អ្នកប្រើប្រាស់ ដូចមានចែងយ៉ាងពិស្ដារនៅក្នុងឧបសម្ព័ន្ធភ្ជាប់ជាមួយប្រកាសនេះ ។

**ប្រការ២** : ស្តង់ដារឧស្សាហកម្មកម្ពុជា CS 002-2001 ស្ដីពីគោលការណ៍ទូទៅនៃប្រព័ន្ធចេញវិញ្ញាបនប័ត្របញ្ជាក់ផលិតផលដោយភាគីទី ៣ នេះត្រូវបានយកលំនាំតាមសៀវភៅណែនាំ ISO/IEC GUIDE 28-1982 General rules for a model third-party certification system for products ទាំងស្រុង ដោយប្រើ ISO/IEC GUIDE 28-1982 ជាភាសាអង់គ្លេសនេះធ្វើជាច្បាប់គោល ។

**ប្រការ៣** : ប្រកាស ឬសេចក្ដីសំរេចទាំងឡាយណា ដែលផ្ទុយនឹងប្រកាសនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

**ប្រការ៤** : ប្រកាសនេះមានប្រសិទ្ធភាពអនុវត្តចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

**ហត្ថលេខា និងត្រា**

**ស៊ុយ សែម**

# ខ្នបសម្ព័ន្ធ

## ស្តង់ដារឧស្សាហកម្មកម្ពុជា

INDUSTRIAL STANDARDS OF
CAMBODIA
CS 002-2001
ISO/IEC Guide 28-1984

## គោលការណ៍ទូទៅ
## នៃប្រព័ន្ធចេញវិញ្ញាបនប័ត្រផលិតផល
## ដោយភាគី ទី ៣

GENERAL RULES FOR A MODEL THIRD-PARTY
CERTIFICATION SYSTEM FOR PRODUCTS

ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល

២០០១

## គោលការណ៍ទូទៅនៃគំរូប្រព័ន្ធចេញវិញ្ញាបនប័ត្រផលិតផល
## ដោយភាគីទី ៣

### ០. បុព្វកថា

គោលការណ៍ទូទៅជាគំរូទាំងនេះ មានប្រសិទ្ធភាពសំរាប់ប្រភេទនៃប្រព័ន្ធចេញវិញ្ញាបនប័ត្រ ដូចខាងក្រោម ៖

ប្រព័ន្ធចេញវិញ្ញាបនប័ត្រដោយភាគីទី ៣ នៃការកំណត់ការអនុលោមតាមស្តង់ដារផលិតផល រួងតាមការធ្វើតេស្តដំបូង ហើយនិងការវាយតំលៃលើប្រព័ន្ធគ្រប់គ្រងគុណភាពតាមរោងចក្រមួយ និង ការទទួលយកនូវការប្រព្រឹត្តិទៅតាមការត្រួតពិនិត្យ ដោយគិតបញ្ចូលទាំងប្រព័ន្ធគ្រប់គ្រងគុណភាព តាមរោងចក្រ និងការធ្វើតេស្តគំរូផលិតផលពីរោងចក្រ និងទីផ្សារសេរី ។

<u>សំគាល់</u> ៖ ប្រព័ន្ធគំរូនេះទាក់ទងទៅនឹងប្រព័ន្ធលេខ ៥ ដូចដែលបានអធិប្បាយនៅក្នុងការបោះពុម្ព ISO/ITC ដែលនិយាយពីការចេញវិញ្ញាបនប័ត្រ គោលការណ៍ និងការអនុវត្តន៍ជាក់ស្តែង ។ ប្រព័ន្ធនេះ

ត្រូវបានគេជ្រើសរើសយក ព្រោះវាជាប្រព័ន្ធមួយដែលទូលំទូលាយបំផុត ហើយថែមទាំងអាចផ្ដល់នូវគ្រឹះដ៏ប្រសើរ ចំពោះការអភិវឌ្ឍន៍ជាយថាហេតុនៃប្រព័ន្ធដទៃទៀត ។

អត្តសញ្ញាណកម្មនៃការអនុលោមអាចមាននៅក្នុងទំរង់វិញ្ញាបនប័ត្រអនុលោម ឬ សញ្ញាអនុលោម ( សូមមើល ISO/IESC Guide 23 ) ។

អង្គភាពចេញវិញ្ញាបនប័ត្រកំរិតជាតិ យ៉ាងហោចណាស់ត្រូវតែមានរចនាសម្ព័ន្ធអង្គភាពមួយសមរម្យ និងប្រើប្រាស់បុគ្គលិក បរិក្ខារ និងនីតិវិធីដែលអនុលោមតាមលក្ខណៈវិនិច្ឆ័យ ដែលមាននៅក្នុង ISO Guide 24 និង ISO/IEC Guide 25 ( ការបោះពុម្ពផ្សាយចុងក្រោយ ) ។

គំរោងការចេញវិញ្ញាបនប័ត្រណាមួយក្រោមប្រព័ន្ធ តំរូវនូវស្តង់ដារមួយជាមុនដែលសមរម្យសំរាប់គោលបំណងនៃការចេញវិញ្ញាបនប័ត្រ ( សូមមើល ISO/IEC Guide 7) ។

១-ឯកសារយោងផ្សេងៗ :

ISO Guide2, General terms and their definitions concerning standardization and certification.

ISO/IEC Guide 7, Requirements for standards suitable for product certification.

ISO/IEC Guide 23, Methods of indicating conformity with standards for thied-party certification systems.

ISO/ Guide 23, Guidelines for the acceptance of testing and inspection agencies by certification bodies.

ISO/IEC Guide 25, General requirements for the technical competence of testing laboratories.

---

[1] គោលការណ៍ណែនាំអំពីកម្មវត្ថុនេះ កំពុងស្ថិតក្នុងការរៀបចំនៅក្នុង ISO/CERTICO.

២-និយមន័យ :

និយមន័យទាំងឡាយដែលពាក់ព័ន្ធ ISO Guide 2-1980 ហើយនឹងសេចក្តីបន្ថែមនៅក្នុង Addendum 1-1981 អាចអនុវត្តបាន ។

៣-លក្ខខ័ណ្ឌជាមូលដ្ឋាន :

លក្ខខ័ណ្ឌទាំងឡាយជាមូលដ្ឋានសំរាប់ទទួលបាន និង ទុកអោយបន្តនូវអាជ្ញាប័ណ្ណ[2] ដើម្បីចេញវិញ្ញាណបនប័ត្រអនុលោម ឬដើម្បីប្រើប្រាស់សញ្ញាអនុលោមគឺថាអ្នកស្នើសុំ ឬ អ្នកកាន់អាជ្ញាប័ណ្ណត្រូវអនុវត្តតាមគោលការណ៍ទូទៅនេះ នឹងគោលការណ៍ជាក់លាក់[3] នៃគំរោងការពាក់ព័ន្ធហើយគាត់ស្នើសុំ

អត្តសញ្ញាណកម្មនៃការអនុលោមតែប៉ុណ្ណោះ ចំពោះផលិតផលដែលក្នុងនៅរយៈពេលអាជ្ញាប័ណ្ណនោះ និងនៅក្នុងការអនុលោមជាមួយស្តង់ដារដែលពាក់ព័ន្ធ ។

៤-សំណុំលិខិតស្នើសុំអាជ្ញាប័ណ្ណ :

សំណុំលិខិតស្នើសុំត្រូវបានធ្វើនៅលើទំរង់ពិសេសមួយ ដែលអាចទទួលបានពីអង្គភាពចេញវិញ្ញាបនប័ត្រ ។ ឧទាហរណ៍មួយនៃទំរង់បែបបទនេះគឺមាននៅក្នុង *ឧបសម្ព័ន្ធ ខ* ។ សំណុំលិខិតស្នើសុំទាក់ទងទៅនឹងផលិតផលជាក់លាក់ ឬក្រុមផលិតផលដែលបានកំណត់ដោយគំរោងការចេញវិញ្ញាបនប័ត្រ និង ដែលបានបញ្ជាក់ក្នុងគោលការណ៍ជាក់លាក់[៣] ។ ជាធម្មតាគឺវាគួរតែគ្របដណ្តប់ទៅលើ ផលិតផលដែល ចេញពីរោងចក្រតែមួយប៉ុណ្ណោះ ។

អង្គភាពចេញវិញ្ញាបនប័ត្រ ស្ថិតលើការយល់ព្រមទទួលសំណុំលិខិតស្នើសុំមួយ ដែលគ្រប់គ្រាន់ពេញលេញ និងស្ថិតលើការដែលបានទទួលប្រាក់កក់ ប្រសិនបើមានការតំរូវ ត្រូវឆ្លើយបញ្ជាក់ដល់អ្នកស្នើសុំ វិញ និងផ្តល់ដំណើងបន្ថែមជាចាំបាច់សំរាប់ដំណើរការដាក់ពាក្យស្នើសុំនោះ ។

៥-ការធ្វើអធិការកិច្ចដំបូងចំពោះរោងចក្រ និងប្រព័ន្ធគ្រប់គ្រងគុណភាព[៤] និងការធ្វើតេស្តដំបូង :

៥-១ លក្ខណៈទូទៅ :

ក្រោយពីមានការឆ្លើយបញ្ជាក់ថា ទទួលយល់ព្រមលើការស្នើសុំនោះ អង្គភាពចេញវិញ្ញាបនប័ត្រ ត្រូវធ្វើការសំរុះសំរួលដែលចាំបាច់ជាមួយអ្នកស្នើសុំ ចំពោះការធ្វើអធិការកិច្ចដំបូងដោយយោងទៅ តាមគោលការណ៍នៃគំរោងការ ។

---

[២] សំរាប់គោលបំណងនៃឯកសារនេះពាក្យ "អាជ្ញាប័ណ្ណ" និង "អ្នកកាន់អាជ្ញាប័ណ្ណ" ត្រូវបានប្រើប្រាស់រួមគ្នាសំរាប់ការផ្តល់អាជ្ញាប័ណ្ណ គឺមានន័យតែម្យ៉ាងសំរាប់បង្ហាញថា អ្នកស្នើសុំត្រូវបានយល់ព្រមដោយអង្គភាពចេញវិញ្ញាបនប័ត្រ ។

[៣] សំរាប់គោលការណ៍ជាក់លាក់សូមមើលឧបសម្ព័ន្ធ "ក"

[៤] ផ្នែកនេះនៅតែស្ថិតនៅក្រោមការពិនិត្យពិច័យ ពីការធានាគុណភាព ISO/TC 176, Quality assurance នៅឡើយ ។

អង្គភាពចេញវិញ្ញាបនប័ត្រ ទទួលខុសត្រូវចំពោះរាល់សកម្មភាពទាំងអស់ក្នុងការចេញវិញ្ញាបនប័ត្រ ចាប់តាំងពីការធ្វើតេស្ត និងការធ្វើអធិការកិច្ចដំបូង ការវាយតំលៃលើប្រព័ន្ធគ្រប់គ្រងគុណភាពរបស់រោងចក្រ ដោយឆ្លងតាមការតាមដានពិនិត្យលើផលិតផលដែលបានផលិត ។

អង្គភាពចេញវិញ្ញាបនប័ត្រ ត្រូវជូនដំណឹងដល់អ្នកស្នើសុំនូវលទ្ធផលនៃការធ្វើអធិការកិច្ច និងការធ្វើតេស្តដំបូង ។

ប្រសិនបើអង្គភាពចេញវិញ្ញាបនប័ត្រ មិនពេញចិត្តដោយថាការតំរូវទាំងអស់សំរាប់ចេញអាជ្ញាប័ណ្ណមិនមានលក្ខណៈគ្រប់គ្រាន់នោះ ត្រូវជូនដំណឹងដល់អ្នកស្នើសុំវិញអំពីចំណុចទាំងឡាយដែលគេពុំបានបំពេញនៅក្នុងសំណុំលិខិតស្នើសុំ ។

ប្រសិនបើអ្នកស្នើសុំអាចបង្ហាញថា ការដោះស្រាយត្រូវបានទទួលយកដើម្បីឆ្លើយតបទៅនឹងការតំរូវទាំងអស់ក្នុងកំឡុងពេលដែលបានកំណត់មួយ អង្គភាពចេញវិញ្ញាបនប័ត្រនឹងត្រូវធ្វើបន្តឡើងវិញនូវផ្នែកដែលចាំបាច់លើនិតិវិធីនៃការធ្វើអធិការកិច្ច និងការធ្វើតេស្តដំបូងតែប៉ុណ្ណោះ ។ បើមិនដូចនេះទេ ពាក្យស្នើសុំនឹងត្រូវទុកជាមោឃៈ ។

នៅពេលមានការកំណត់តំលៃ ដែលត្រូវបានកំណត់ដោយអង្គភាពចេញវិញ្ញាបនប័ត្រថាជាចំណែកនៃនីតិវិធីក្នុងការដាក់ពាក្យសុំ ការចុះបញ្ជីពាក្យសុំថ្មី ការពន្យារពេលកំណត់តំលៃអាចត្រូវបានតំរូវអោយធ្វើតាម ។

ការធ្វើអធិការកិច្ចសារជាថ្មីអាចមិនចាំបាច់ធ្វើឡើយ ចំពោះផលិតផលប្រភេទតែមួយដែលបញ្ជូនមកពេលក្រោយបន្តបន្ទាប់ ។

៥-២ <u>ការវាយតំលៃប្រព័ន្ធគ្រប់គ្រងគុណភាពរោងចក្រ</u> :

ការវាយតំលៃលើប្រព័ន្ធគ្រប់គ្រងគុណភាពរោងចក្ររបស់អ្នកស្នើសុំបង្កើតឡើងជាចំណែកនៃការធ្វើអធិការកិច្ចដំបូង ។ ការវាយតំលៃនេះ អាចត្រូវបានធ្វើទៅតាមការតំរូវដែលបានកំណត់ក្នុងគោលការណ៍ជាក់លាក់នៃគំរោងការអនុវត្ត ។

រាល់ការកត់ត្រាទាំងឡាយ ដែលបានមកពីការប្រតិបត្តិប្រព័ន្ធគ្រប់គ្រងគុណភាព ទាក់ទងទៅនឹងការចេញវិញ្ញាបនប័ត្រ ត្រូវមានលក្ខណៈងាយស្រួលសំរាប់ការធ្វើអធិការកិច្ចរបស់អង្គភាពចេញវិញ្ញាបនប័ត្រ ។

អ្នកស្នើសុំត្រូវធានាថា ការទទួលខុសត្រូវចំពោះអង្គភាពចេញវិញ្ញាបនប័ត្រលើប្រព័ន្ធគ្រប់គ្រងគុណភាព គឺត្រូវតែបានកំណត់ច្បាស់លាស់ ឧទាហរណ៍ : តែងតាំងជនណាម្នាក់ដែលឯករាជ្យមិនពាក់ព័ន្ធពីការគ្រប់គ្រងផលិតកម្មរហូតដល់ការអនុវត្តន៍បច្ចេកទេស ហើយត្រូវមានលក្ខណៈសម្បត្តិគ្រប់

គ្រាន់សំរាប់ទំនាក់ទំនងជាមួយអង្គភាពចេញវិញ្ញាបនប័ត្រដើម្បីធានាថា ប្រព័ន្ធគ្រប់គ្រងគុណភាពត្រូវបានប្រតិបត្តិ ។

៥-៣ ការធ្វើតេស្តដំបូង :

៥-៣-១ ការជ្រើសរើសគំរូផលិតផល :

ការជ្រើសរើសយកគំរូផលិតផលសំរាប់ធ្វើតេស្ត និងការពិនិត្យត្រូវតែផ្អែកទៅលើគោលការណ៍នៃគំរោងការ ។

គំរូផលិតផលត្រូវតែជាតំណាងនៃផលិតផលក្នុងខ្សែសង្វាក់ផលិតកម្មទាំងមូល ឬក្រុមផលិតកម្មដែលនឹងត្រូវបញ្ជាក់ និងត្រូវផលិតចេញពីឧបករណ៍ផលិតកម្ម និងត្រូវប្រមូលផ្តុំតំឡើង ទាំងមូលដោយប្រើវិធីសាស្ត្រដែលបានបង្កើតសំរាប់ដំណើរការផលិតកម្ម ។

នៅពេលដែលការធ្វើតេស្តគំរូតាងផ្អែកទៅលើគំរូផលិតផលដើម ជាការគេអោយ ការធ្វើតេស្តដែលមានការបញ្ជាក់ ឬការពិនិត្យគួរត្រូវធ្វើគំរូផលិតផលនៃផលិតកម្ម ។

៥-៣-២ ដំណើរការនៃការធ្វើតេស្តដំបូង :

ការធ្វើតេស្តដំបូងគឺអនុវត្តដោយយោងទៅតាមស្តង់ដារដែលអាចអនុវត្តបាន និងគោលការណ៍ជាក់លាក់នៃគំរោងការ ។

៥-៣-៣ ការប្រើប្រាស់ទិន្នន័យតេស្តដែលបានធ្វើដោយស្ថាប័នដទៃក្រៅពីអង្គភាពចេញវិញ្ញាបនប័ត្រ:

នៅពេលដែលអង្គភាពចេញវិញ្ញាបនប័ត្រសំរេចយកទិន្នន័យតេស្តដែលធ្វើដោយអង្គភាពផ្សេងៗ ឬដោយភ្នាក់ងារធ្វើតេស្តដែលខ្លួនបានចាត់តាំង អង្គភាពចេញវិញ្ញាបនប័ត្រធានាអោយប្រាកដថាភាគីដឹកនាំធ្វើតេស្តបានអនុវត្តតាមលក្ខណៈវិនិច្ឆ័យ ដែលកំណត់ក្នុងសៀវភៅណែនាំ ISO Guide 24 និង ISO/IEC Guide 25 ។

៦-ការផ្តល់អាជ្ញាប័ណ្ណ :

នៅពេលដែលបានបំពេញសព្វគ្រប់តាមដែលបានកសាងការគំរូវ អង្គភាពចេញវិញ្ញាបនប័ត្រត្រូវជូនដំណឹងដល់អ្នកស្នើសុំ ដាក់ជូនគាត់អោយចុះហត្ថលេខាលើកិច្ចព្រមព្រៀងផ្តល់អាជ្ញាប័ណ្ណ[៦]

[៥] ដូចដែលបានប្រើក្នុងនេះ "ការធ្វើតេស្តដំបូង" សំដៅចំពោះដំណើរការរបស់អង្គភាពចេញវិញ្ញាបនប័ត្រនៅមុនការផ្តល់អោយឬការពន្យារពេលនៃអាជ្ញាប័ណ្ណ ។ ការកំណត់ការធ្វើតេស្តដំបូង បានធ្វើតាមគំរូវនៃស្តង់ដារ ដែលអាចទទួលយកបាន ។ គេច្រើនហៅថា "type testing"

[៦]ប្រសិនបើប្រព័ន្ធចេញវិញ្ញាបនប័ត្រមួយយោងតាមច្បាប់ ដែលបញ្ជាក់លំអិតអំពីប្រព័ន្ធនេះ តាមសំណួរ ហើយប្រសិនបើប្រព័ន្ធនេះត្រូវគ្រប់គ្រងដោយស្ថាប័នរដ្ឋាភិបាល ឬស្ថាប័នស្ដីទីដែលធ្វើការ ជំនួសរដ្ឋាភិបាល កិច្ចព្រមព្រៀងបែបនេះអាចមិនជាការចាំបាច់ទេ ។ (លុះត្រាតែបានធ្វើរួច) ហើយទីបញ្ចប់ត្រូវចេញអាជ្ញាប័ណ្ណ ។ (ឧទាហរណ៍អំពីកិច្ចព្រមព្រៀង មួយ និងអាជ្ញាប័ណ្ណមួយបែបនេះ បានដាក់បញ្ចូលនៅក្នុងឧបសម្ព័ន្ធ គ ) ។

៧-ការបន្តសុពលភាពអាជ្ញាប័ណ្ណ :

អ្នកកាន់អាជ្ញាប័ណ្ណដែលចង់សុំបន្តសុពលភាពអាជ្ញាប័ណ្ណ ដើម្បីអនុញ្ញាតអោយសំណុំលិខិត ស្នើសុំអត្តសញ្ញាណកម្មអនុលោមតាមប្រភេទផលិតផលបន្ថែម ឬម៉ូដែលនៃផលិតផលដែលផលិតនៅក្នុងរោងចក្រតែមួយតាមស្តង់ដារដូចគ្នា ដូចផលិតផលដែលមានអាជ្ញាប័ណ្ណស្ថិតនៅជាធរមានអ្នកកាន់អាជ្ញាប័ណ្ណ ត្រូវដាក់ពាក្យសុំនៅអង្គភាពចេញវិញ្ញាបនប័ត្រ ដោយប្រើទំរង់ សំណុំលិខិតស្នើសុំធម្មតា (មាននៅក្នុងឧបសម្ព័ន្ធ ខ ) ។ ក្នុងករណីនេះ អង្គភាពចេញវិញ្ញាបនប័ត្រអាចសំរេចមិនអនុវត្តការធ្វើអធិការកិច្ចនៅរោងចក្រឡើយ ប៉ុន្តែត្រូវតំរូវអោយមានការធ្វើតេស្តគំរូផលិតផលនៃប្រភេទផលិតផល ដើម្បីកំណត់ថា ផលិតផលនោះបាន អនុលោមតាមស្តង់ដារ ។ ប្រសិនបើការធ្វើតេស្តបានសំរេច ជោគជ័យនោះ អាជ្ញាប័ណ្ណបន្ថែម នឹងត្រូវបានផ្តល់ជូន ។ ប្រសិនបើអ្នកកាន់អាជ្ញាប័ណ្ណ ចង់ដាក់ពាក្យសុំវិញ្ញាបនប័ត្រចំពោះប្រភេទផលិតផលបន្ថែម ដែលបានផលិតនៅរោងចក្រតែមួយ ប៉ុន្តែស្តង់ដារខុសគ្នា ឬប្រសិនបើអ្នកកាន់អាជ្ញាប័ណ្ណ ចង់ដាក់ពាក្យស្នើសុំវិញ្ញាបនប័ត្រដើម្បីប្រើប្រាស់នៅក្នុងរោងចក្របន្ថែមមួយ ដែលមិនស្ថិតនៅក្រោមសុពលភាពនៃអាជ្ញាប័ណ្ណមុន ផ្នែកទាំងអស់នៃនីតិវិធីសុំណុំលិខិតស្នើសុំដើមដែល មិនគ្របដណ្តប់លើកាលៈទេសៈ នឹងត្រូវបានអនុវត្ត ។

៨-ការពិនិត្យអង្កេត :

អង្គភាពចេញវិញ្ញាបនប័ត្រ អនុវត្តការពិនិត្យអង្កេតផលិតផល ផ្អែកលើមូលដ្ឋាននៃការតំរូវនៃ ស្តង់ដារពាក់ព័ន្ធ និងនៃប្រព័ន្ធគ្រប់គ្រងគុណភាពផ្អែកលើមូលដ្ឋាននៃគោលការណ៍ជាក់ លាក់នៃ គំរោងការ[៧] ។

---

[៧]ក្នុងករណីខ្លះ វាអាចមិនចាំបាច់ដើម្បីពិនិត្យសារឡើងវិញនៃធាតុទាំងអស់ដែលបានកំណត់ សំរាប់ការធ្វើតេស្តដំបូង ។ នេះអាចជាករណីសំរាប់ផលិតផល ដែលបង្កើតដោយអតិថិជន និងត្រូវបានអនុវត្តចំពោះករណីដែលការធ្វើតេស្តដំបូងលំបាកស្មុគស្មាញខ្លាំងពេក ឬក្នុងករណី គំរូប៉ាន់ថ្លៃពេក ។ ក្នុងករណីដូចខាងលើនេះ ការពិនិត្យអង្កេត អាចផ្អែកលើមូល ដ្ឋានត្រួត ពិនិត្យប៉ុណ្ណោះឬភ្ជាប់ជាមួយនឹងការធ្វើតេស្តងាយៗដែលធានាថា ផលិតផល ស្ថិតក្នុងការ អនុលោមទៅតាមគំរូប៉ាន់ដែលបានធ្វើតេស្ត ។ ការធ្វើតេស្ត កំណត់បែបនេះគួរត្រូវបាន អធិប្បាយនៅក្នុងគោលការណ៍ជាក់លាក់នៃគំរោងការ ។

អង្គភាពចេញវិញ្ញាបនប័ត្រ អាចតែងតាំងភ្នាក់ងារមួយដើម្បីអនុវត្តការពិនិត្យអង្កេតដែលស្ថិត នៅក្រោមអំណាច និងការទទួលខុសត្រូវរបស់ខ្លួនហើយបានអនុវត្តភារកិច្ចស្របទៅនឹងលក្ខ-ខ័ណ្ឌដែលបានយល់ព្រម ។ ភ្នាក់ងារណាដែលតែងតាំងដោយអង្គភាពចេញវិញ្ញាបនប័ត្រ ត្រូវមានគ្រប់លក្ខណៈសម្បត្តិ និងមានបុគ្គលិកដែលមានសមត្ថភាពចាំបាច់សំរាប់ការពិនិត្យ អង្កេតគ្រប់គ្រាន់ ។ លទ្ធផលនៃការពិនិត្យអង្កេត នឹងត្រូវបានជូនដំណឹងដល់អ្នកកាន់អាជ្ញាប័ណ្ណ ។

អ្នកកាន់អាជ្ញាប័ណ្ណ ត្រូវជូនដំណឹងដល់អង្គភាពចេញវិញ្ញាបនប័ត្រ អំពីបំណងកែប្រែផ្លាស់ប្តូរ ណាមួយក្នុងផលិតផលខ្សែសង្វាក់ផលិតកម្ម ឬ ប្រព័ន្ធគ្រប់គ្រងគុណភាពដែលអាចប៉ះពាល់ ដល់ការប្រព្រឹត្តិតាមនៃផលិតផល ហើយវាក៏អាស្រ័យទៅនឹងអង្គភាពចេញវិញ្ញាបនប័ត្រ ដើម្បីកំណត់ថាតើ ការផ្លាស់ប្តូរនោះតំរូវអោយមានការធ្វើតេស្ត និងការធ្វើអធិការកិច្ចដំបូង ផ្សេងទៀត ឬការស៊ើបអង្កេតដទៃទៀតឬទេ ក្នុងករណីបែបនេះ អ្នកកាន់អាជ្ញាប័ណ្ណនឹងមិន ត្រូវបានអនុញ្ញាតអោយបញ្ចេញផលិតផលដែលជាលទ្ធផលបានមកពីការកែប្រែឡើយ លុះណា តែអង្គភាពចេញវិញ្ញាបនប័ត្របានជូន ដំណឹងដល់ អ្នកកាន់អាជ្ញាប័ណ្ណសិន ។

អ្នកកាន់អាជ្ញាប័ណ្ណ ត្រូវរក្សាទុកនូវឯកសារនៃការតវ៉ាទាំងឡាយដែលពាក់ព័ន្ធទៅនឹងផលិតផល ក្រោមអាជ្ញាប័ណ្ណ និងទុកបង្ហាញជូនអង្គភាពចេញវិញ្ញាបនប័ត្រនៅពេលមានសំណូមពរ ។

៩-ការប្រើប្រាស់សញ្ញាអនុលោម និង ការដាក់សញ្ញា :

៩-១ សញ្ញាអនុលោម :

ក្នុងករណីដែលប្រព័ន្ធប្រើប្រាស់សញ្ញាអនុលោម គោលការណ៍នៃ ISO/IEC GUIDE 23 គួរត្រូវបានអនុវត្តតាម ។

សញ្ញាអនុលោមបែបនេះត្រូវតែផ្សេងគ្នាហើយ :

-ត្រូវតែជាម្ចាស់ក្នុងចរិតដើម ដោយមានការការពារស្របច្បាប់ពាក់ព័ន្ធទៅនឹងសមាសភាគ និងការត្រួតពិនិត្យនៃការប្រើប្រាស់ ។

-ត្រូវបានដាក់លេខកូដ ឬ បើមិនដូច្នេះទេ ត្រូវបានគូរគំនូសជាជំនួយក្នុងការស្រាវជ្រាវរកនូវ ការធ្វើក្លែងបន្លំ ឬទ្រង់ទ្រាយនៃការប្រព្រឹត្តិរំលោភដទៃទៀត

-មិនត្រូវផ្ទេរពីផលិតផលមួយទៅផលិតផលមួយផ្សេងទៀតឡើយ

-ត្រូវតែបិទដោយផ្ទាល់ចំពោះជំពូកនីមួយៗ នៃផលិតកម្ម លើកលែងតែទំហំជាក់ស្តែងនៃជំពូក ឬប្រភេទផលិតផលមិនអនុគ្រោះអោយបិទបាន ក្នុងករណីនេះគេអាចបិទសញ្ញាទៅលើកញ្ចប់ តូចបំផុតដែលមានដាក់លក់លើទីផ្សារ ។

៩-២ ការដាក់សញ្ញា :

ក្នុងកាលៈទេសៈជាក់ស្តែង វាអាចសមស្របដើម្បីប្រើប្រាស់ការដាក់សញ្ញាដទៃទៀត រួមផ្សំ ជាមួយសញ្ញាអនុលោម ដូចជា :

-ឈ្មោះ ឬ ពាណិជ្ជសញ្ញានៃអង្គភាពចេញវិញ្ញាបនប័ត្រ ដែលមិនអាចកំណត់ប្រើជាសញ្ញា អនុលោមបាន

-ឈ្មោះចំណាត់ថ្នាក់ផលិតផលដែលមិនច្បាស់លាស់ពេញលេញ

-អត្តសញ្ញាណកម្មស្តង់ដារដែលពាក់ព័ន្ធ

ការដាក់សញ្ញាបែបនេះ ត្រូវអនុលោមទៅតាមគោលការណ៍ជាក់លាក់នៃគំរោងការ ។

ក្នុងករណីធ្វើការកែតំរូវបន្ថែមបន្ថយស្តង់ដារមួយ ដែលផ្អែកលើគំរោងការចេញវិញ្ញាបនប័ត្រ ជាសំខាន់គឺការដាក់សញ្ញា ត្រូវបង្ហាញយ៉ាងច្បាស់លាស់ពីការបោះពុម្ពសមស្របអំពីស្តង់ដារ ដែលកំពុងយកមកពិនិត្យបន្ថែមបន្ថយ ឬការដាក់សញ្ញាកូដ កាលបរិច្ឆេទដែលអាចអនុវត្តបាន ដើម្បីផ្តល់ពត៌មាន ត្រឹមត្រូវដល់អ្នកប្រើប្រាស់នូវការតំរូវចំពោះផលិតផល ។

១០-ការផ្សព្វផ្សាយជាសាធារណៈដោយអ្នកកាន់អាជ្ញាប័ណ្ណ :

អ្នកកាន់អាជ្ញាប័ណ្ណមានសិទ្ធិផ្សព្វផ្សាយថា គាត់ត្រូវបានអនុញ្ញាតអោយប្រើវិញ្ញាបនប័ត្រ អនុលោមមួយ ឬបិទសញ្ញាអនុលោមលើផលិតផលដែលបានសុំអាជ្ញាប័ណ្ណ ។

ក្នុងគ្រប់ករណី អ្នកកាន់អាជ្ញាប័ណ្ណត្រូវតែយកចិត្តទុកដាក់ខ្ពស់ចំពោះការបោះពុម្ពផ្សាយ និង ផ្សព្វផ្សាយពាណិជ្ជកម្មថា គ្មានការភាន់ច្រឡំកើតឡើងរវាងផលិតផលដែលមាន និង ផលិត ផលដែលគ្មានវិញ្ញាបនប័ត្រឡើយ ។

បើសិនផលិតករមានបំណងផ្សព្វផ្សាយជាផ្នែក១នៃរបាយការណ៍តេស្ត ដែលទាក់ទងទៅនឹងការបញ្ជាក់នៃផលិតផលដែលមានវិញ្ញាបនប័ត្រ នោះចាំបាច់ត្រូវមានកិច្ចព្រមព្រៀងជាលាយ -លក្ខណ៏អក្សររបស់អង្គភាពចេញវិញ្ញាបនប័ត្រ ។

អ្នកកាន់អាជ្ញាប័ណ្ណមិនត្រូវបញ្ជាក់ពីមុខងារការអះអាង ឬក៏ដូចគ្នានឹងពត៌មាននៃអ្នកប្រើប្រាស់ដែលអាចធ្វើអោយអ្នកទិញភាន់ច្រឡំជឿថា ការប្រព្រឹត្តិទៅរបស់ផលិតផល ឬការប្រើប្រាស់ របស់វាបានស្ថិតនៅក្រោមការបញ្ជាក់ដោយវិញ្ញាបនប័ត្រឡើយដែលតាមពិតមិនមែន សោះ ។ សៀវភៅណែនាំ ឬពត៌មាននៃអ្នកប្រើប្រាស់ដទៃទៀតដែលភ្ជាប់ជាមួយផលិតផល និងដែលបានទាក់ ទងនឹងគំរោងការចេញវិញ្ញាបនប័ត្រត្រូវបានអនុម័តដោយអង្គភាពចេញ វិញ្ញាបនបត្រ ប្រសិនបើមានការតំរូវ ដោយគោលការណ៍ជាក់លាក់នៃគំរោងការ ។

១១-ការរក្សាការសំងាត់ :

អង្គភាពចេញវិញ្ញាបនប័ត្រ ជាអ្នកទទួលខុសត្រូវក្នុងការធានាថា និយោជិកទាំងឡាយ និង ភ្នាក់ងាររបស់ខ្លួន (សូមមើលប្រយោគ៨ កថាខ័ណ្ឌទី២) ត្រូវរក្សាការសំងាត់ដែលពាក់ព័ន្ធទៅ នឹងពត៌មានសំងាត់ទាំងអស់ ដែលបានដឹងដោយសារលទ្ធផលទំនាក់ទំនងជាមួយអ្នកកាន់អាជ្ញា-ប័ណ្ណ ។

១២-ការប្រព្រឹត្តិរំលោភលើការប្រើប្រាស់ វិញ្ញាបនប័ត្រ ឬ សញ្ញាអនុលោម :

អង្គភាពចេញវិញ្ញាបនប័ត្រត្រូវដំណើរការកម្មវិធីឆែកមើល ដែលជាផ្នែក មួយនៃកម្មវិធីរបស់ ខ្លួនដើម្បីត្រួតពិនិត្យអោយបានត្រឹមត្រូវចំពោះការប្រើប្រាស់វិញ្ញាបនប័ត្រឬសញ្ញាអនុលោម ។

ការយោងទាំងឡាយណាដែលមិនត្រឹមត្រូវចំពោះប្រព័ន្ធចេញវិញ្ញាបនប័ត្រ ឬ ការប្រើប្រាស់ ដោយយល់ច្រឡំលើវិញ្ញាបនប័ត្រ ឬសញ្ញាដែលបានរកឃើញក្នុងការផ្សព្វផ្សាយក្នុងកាតាឡុក ។ល។ គួរតែត្រូវធ្វើការដោះស្រាយដោយអំពើសមស្របទាំងឡាយដែលអាច រួមទាំងការប្តឹង ទៅតុលាការ ឬ អំពើកែតំរូវ ឬ ការកែតំរូវលើការផ្សព្វផ្សាយកន្លងមក ។

ក្នុងករណីអ្នកកាន់អាជ្ញាប័ណ្ណប្រើប្រាស់វិញ្ញាបនប័ត្រ ឬ សញ្ញាអនុលោមមិនត្រឹមត្រូវនោះ ត្រូវអនុវត្តវិធានការកែតំរូវ ។

១៣-ការព្យួរអាជ្ញាប័ណ្ណផលិតផល :

អាជ្ញាប័ណ្ណដែលអនុវត្តចំពោះផលិតផលជាក់លាក់មួយ អាចត្រូវបានព្យួរទុកក្នុងរយៈពេលមួយ ជាកំណត់ឧទាហរណ៍ ក្នុងករណីដូចខាងក្រោម :

-ប្រសិនបើការពិនិត្យអង្កេតបង្ហាញអោយឃើញថា គ្មានការប្រព្រឹត្តិតាមការតំរូវដើមនៃការផ្តល់ និង ការប្រើប្រាស់អាជ្ញាប័ណ្ណ (ឬគោលការណ៍នៃការព្យួរទុក) នោះមិនចាំបាច់ដកហូត ភ្លាម១ទេ

-ប្រសិនបើក្នុងករណីការប្រើប្រាស់វិញ្ញាបនប័ត្រឬសញ្ញាអនុលោមមិនបានត្រឹមត្រូវឧទាហរណ៍ ការបោះពុម្ពឬការផ្សព្វផ្សាយមិនត្រឹមត្រូវ ហើយអ្នកកាន់អាជ្ញាប័ណ្ណមិនបានចាត់ វិធានការ ដោះស្រាយ ឬ កែតំរូវអោយបានសមស្រប និងទាន់ពេលវេលា

-ប្រសិនបើមានការរំលោភចំពោះគោលការណ៍នៃគំរោងការ ឬ ចំពោះនីតិវិធីរបស់អង្គភាព ចេញវិញ្ញាបនប័ត្រ ។

អ្នកកាន់អាជ្ញាប័ណ្ណ មិនត្រូវបញ្ជាក់បង្ហាញថា ផលិតផលណាមួយបានទទួលវិញ្ញាបនប័ត្រទេ នៅពេលដែលអាជ្ញាប័ណ្ណនៃផលិតផលនោះត្រូវបានព្យួរទុក ។

អាជ្ញាប័ណ្ណមួយអាចត្រូវបានព្យួរទុកដែរ បន្ទាប់ពីមានការយល់ព្រមទៅវិញទៅមករវាង អង្គភាពចេញវិញ្ញាបនប័ត្រ និងអ្នកកាន់អាជ្ញាប័ណ្ណសំរាប់រយៈពេលកំណត់មួយនៃការមិនដំណើរការ ផលិតកម្មឬក៏សំរាប់មូលហេតុផ្សេងៗ ។

ការព្យួរទុកអាជ្ញាប័ណ្ណជាផ្លូវការនឹងត្រូវបានបញ្ជាក់ដោយអង្គភាពចេញវិញ្ញាបនប័ត្រក្នុងលិខិត ចុះបញ្ជីមួយ ផ្ញើជូនចំពោះផលិតករ ( ឬដោយមធ្យោបាយណាមួយដែល មានតំលៃស្មើ ) ។

អង្គភាពចេញវិញ្ញាបនប័ត្រត្រូវបង្ហាញថា ការព្យួរទុកអាជ្ញាប័ណ្ណនឹងត្រូវលុបចោលវិញក្រោម លក្ខខ័ណ្ឌណាមួយ ឧទាហរណ៍បានអនុវត្តវិធានការកែតំរូវដោយយោងទៅតាមប្រយោគ១៥ ។

នៅពេលចប់រយៈពេលនៃការព្យួរទុកអាជ្ញាប័ណ្ណ អង្គភាពចេញវិញ្ញាបនប័ត្រត្រូវតាមស៊ើប អង្កេតមើលថាតើល័ក្ខខ័ណ្ឌដែលបានបង្ហាញអោយអនុវត្តលើអាជ្ញាប័ណ្ណជាថ្មី ត្រូវបានបំពេញ ហើយ ឬនៅ ។

នៅពេលដែលរាល់ល័ក្ខខ័ណ្ឌត្រូវបានបំពេញរួចហើយនោះ ការព្យួរទុកអាជ្ញាប័ណ្ណនឹងត្រូវលុបចោលដោយផ្ញើសេចក្តីបញ្ជាក់ជាផ្លូវការប្រាប់ផលិតករថា អាជ្ញាប័ណ្ណត្រូវមានសុពលភាព ឡើងវិញហើយ ។

បើសិនជាល័ក្ខខ័ណ្ឌមិនត្រូវបានបំពេញទេនោះ អង្គភាពចេញវិញ្ញាបនប័ត្រត្រូវដកហូតអាជ្ញា ប័ណ្ណតែម្តង ។

១៤-ការដកហូត និងការលុបចោលអាជ្ញាប័ណ្ណ :

១៤-១ ក្រៅពីការព្យួរទុកអាជ្ញាប័ណ្ណ អាជ្ញាប័ណ្ណមួយអាចត្រូវបានដកហូតក្នុងករណីដូចខាងក្រោម :

-ប្រសិនបើការពិនិត្យអង្កេតបង្ហាញអោយឃើញថា ការអនុវត្តន៏មានលក្ខណៈខុសធ្ងន់ធ្ងរទៅនឹងការតំរូវដើមនៃការផ្តល់ និង ការប្រើប្រាស់អាជ្ញាប័ណ្ណ

-ប្រសិនបើអ្នកកាន់អាជ្ញាប័ណ្ណខកខានមិនបានអនុវត្តការទូទាត់តាមកាលកំណត់នៃកាតព្វកិច្ចហិរញ្ញវត្ថុ

-ប្រសិនបើមានការប្រព្រឹត្តិល្មើសដទៃណាមួយទៀតពីកិច្ចព្រមព្រៀងអាជ្ញាប័ណ្ណ

-ប្រសិនបើវិធានការទាំងឡាយដែលត្រូវប្រកាន់យកដោយអ្នកកាន់អាជ្ញាប័ណ្ណមិនបានគ្រប់គ្រាន់ក្នុងកំឡុងពេលនៃការព្យួរទុក ។

ក្នុងករណីខាងលើ អង្គភាពចេញវិញ្ញាបនប័ត្រមានសិទ្ធិដកហូតអាជ្ញាប័ណ្ណដោយជូនដំណឹងជាលិខិតផ្លូវការដល់អ្នកកាន់អាជ្ញាប័ណ្ណ ( ឬដោយមធ្យោបាយដែលមានតំលៃស្មើគ្នា ) ។ ពាក់ព័ន្ធទៅនឹងការបញ្ជាក់អំពីការកំណត់ពេលវេលា សូមមើលប្រការ១០នៃគំរូកិច្ចព្រមព្រៀងអាជ្ញាប័ណ្ណ ( ឧបសម្ព័ន្ធ ) ។

អ្នកកាន់អាជ្ញាប័ណ្ណ អាចផ្តល់ការប្រកាសអំពីការតវ៉ា ហើយអង្គភាពចេញវិញ្ញាបនប័ត្រធ្វើការ ពិចារណាថា តើការតវ៉ាអាច ឬមិនអាច ដោយអាស្រ័យទៅនឹងករណីជាក់ស្តែងដើម្បីសំរេចបន្តការដកហូត ឬការលុបចោល អាជ្ញាប័ណ្ណ ។

មុននឹងដកហូតអាជ្ញាប័ណ្ណ អង្គភាពចេញវិញ្ញាបនប័ត្រត្រូវសំរេចដោយពឹងផ្អែកទៅ លើផលវិបាកទាំងឡាយ ដែលទាក់ទងទៅនឹងរាល់ផលិតផលដែលបានបញ្ជាក់ទទួលស្គាល់ក្នុងអាជ្ញាប័ណ្ណ ថាតើ សញ្ញាអនុលោមត្រូវតែ ដកហូតចេញពីផលិតផលទាំងអស់ក្នុងឃ្លាំងស្តុកឬទេ ហើយក៏អាចអនុវត្តចំពោះផលិតផលដែលបានលក់ នៅ លើទីផ្សារផងដែរ ឬថាតើត្រូវបានអនុញ្ញាតអោយក្នុងរយៈពេលមួយខ្លី ដើម្បីអោយប ញ្ចូញផលិតផលក្នុងស្តុក ដែលបានបិទសញ្ញារួចហើយ ប្រសិនបើការងារនោះស្ថិតក្នុងការ តំរូវជាចាំបាច់ ។

១៤-២ ម៉្យាងទៀតអាជ្ញាប័ណ្ណអាចត្រូវបានលុបចោលក្នុងករណីដូចខាងក្រោម :

-ប្រសិមបើអ្នកកាន់អាជ្ញាប័ណ្ណគ្មានបំណងបន្តអាជ្ញាប័ណ្ណ

-ប្រសិនបើស្តង់ដារ ឬគោលការណ៍ទាំងឡាយត្រូវផ្លាស់ប្តូរ ហើយអ្នកកាន់អាជ្ញាប័ណ្ណមិនអាច ធានាបាន ឬក៏មិនអាចធានាអនុវត្តតាមការតំរូវថ្មីបាន ( ប្រយោគ ១៦ )

-ប្រសិនបើផលិតផលត្រូវបានឈប់ផលិត ឬអ្នកកាន់ប័ណ្ណឈប់ធ្វើជំនួញ ឬផ្អែកលើមូលដ្ឋាននៃ ល័ក្ខខ័ណ្ឌទាំង ឡាយដែលមានបញ្ជាក់នៅក្នុងកិច្ចព្រមព្រៀងអាជ្ញាប័ណ្ណ ។

១៤-៣ ការដកហូត ឬការលុបចោលអាជ្ញាប័ណ្ណ អាចត្រូវបានផ្សព្វផ្សាយដោយអង្គភាពចេញ វិញ្ញាបនប័ត្រ ។

១៥-សកម្មភាពកែតំរូវ :

ក្នុងករណីនៃការប្រើវិញ្ញាបនប័ត្រ ឬសញ្ញាអនុលោមមិនបានត្រឹមត្រូវ គួរអនុវត្តសកម្មភាពកែតំរូវដើម្បីការ ពារការប្រើប្រាស់របស់វា ។

<u>សំគាល់</u> : គោលការណ៍ណែនាំអំពីការកែតំរូវក្នុងករណីមានការប្រព្រឹត្តរំលោភក្នុងការប្រើ សញ្ញាអនុលោម កំពុងស្ថិតក្នុងការរៀបចំបោះពុម្ពផ្សាយ ។

១៦-ការប្រតិបត្តិលើការកែប្រែស្តង់ដារ ( សូមមើលក្នុងប្រការ១១ នៃឧបសម្ព័ន្ធ គ )

មានគត្តាមួយចំនួនដែលត្រូវលើកយកមកពិចារណានៅពេលកំណត់កាលបរិច្ឆេទដែលក្នុងនោះ ការតំរូវនៃផលិតផលក្នុងស្តង់ដារកែសំរួលមួយនឹងត្រូវចូលជាធរមាន ( ការបរិច្ឆេទជាធរមាន ) នៅពេលដែល ការបោះពុម្ពស្តង់ដារមុនមានមូលដ្ឋានក្នុងការចេញវិញ្ញាបនប័ត្ររួចហើយ ។

កាលបរិច្ឆេទជាធរមាននៃការកែប្រែស្តង់ដារមួយត្រូវបានបោះពុម្ពផ្សាយដោយអង្គភាពចេញ វិញ្ញាបនប័ត្រ ហើយអ្នកកាន់អាជ្ញាប័ណ្ណទាំងអស់ដែលមានឈ្មោះនៅក្នុងបញ្ជីក្រោមគំរោងការដែលនឹង ត្រូវពិភាក្សា នឹងត្រូវបានផ្តល់ពេលវេលាគ្រប់គ្រាន់ដើម្បីធ្វើការដាក់ស្នើឡើងវិញ ។

កត្តាទាំងឡាយដែលត្រូវពិចារណាក្នុងការជ្រើសរើសកាលបរិច្ឆេទជាធរមានមានដូចខាងក្រោម ប៉ុន្តែមិនចាំបាច់តឹងតែងពេកទេ :

-ភាពបន្ទាន់នៃការអនុលោមតាមការតំរូវអំពីសុខភាព សុវត្ថិភាព ឬបរិស្ថានដែលបានកែប្រែ

-ថេរវេលា និងថវិកាសំរាប់រៀបចំដំឡើងឧបករណ៍ឡើងវិញ និងការផលិតផលិតផល អនុលោមតាមការតំរូវដែលបានកែសំរួល

-បរិមាណដែលមានក្នុងស្តុក អាចត្រូវធ្វើឡើងវិញដើម្បីឆ្លើយតបទៅនឹងការតំរូវដែលបានកែសំរួល

-ការជៀសវាងការទាញយកផលប្រយោជន៍ខាងពាណិជ្ជកម្មដោយអចេតនា ទៅលើការផលិត ឬ គំរោងការណាមួយ

-បញ្ហាដែលបានប្រតិបត្តិរបស់អង្គភាពចេញវិញ្ញាបនប័ត្រ ។

១៧-ការទទួលខុសត្រូវ :

ក្នុងករណីមានបញ្ហាពាក់ព័ន្ធទៅនឹងការទទួលខុសត្រូវលើផលិតផល បញ្ហានោះត្រូវដោះស្រាយ ដោយផ្អែកលើមូលដ្ឋាននៃប្រព័ន្ធច្បាប់ទាំងឡាយដែលពាក់ព័ន្ធ ។

១៨-ការវិវាទ :

ក្នុងករណីមានការវិវាទ នីតិវិធីបណ្តឹងរបស់អង្គភាពចេញវិញ្ញាបនប័ត្រ អាចនឹងយក ទៅដោះស្រាយចំពោះមុខច្បាប់ ។

១៩-តំលៃអាករ :

តំលៃអាករសំរាប់ប្រតិបត្តិការនៃគំរោងការចេញវិញ្ញាបនប័ត្រគឺត្រូវបានសំរេចដោយអង្គភាព ចេញវិញ្ញា បន-ប័ត្រសំរាប់គំរោងការនីមួយៗ ។

ឧបសម្ព័ន្ធ

បញ្ជីត្រួតពិនិត្យសំរាប់មាតិកាមូលដ្ឋាននៃគោលការណ៍ជាក់លាក់

ចំពោះគំរោងការនីមួយៗ គួរត្រូវបង្កើតនូវគោលការណ៍ជាក់លាក់មួយសំរាប់លើកយកមកពិចារណានូវវិធី - សាស្ត្រផលិត និងប្រភេទផលិតផល ឬក្រុមផលិតផលដែលស្ថិតនៅក្រោមគំរោងការ ( សូមមើលប្រយោគ ៤)

ក្នុងការបង្កើតគោលការណ៍ជាក់លាក់ចំពោះគំរោង ការមួយបញ្ជីត្រួត ពិនិត្យខាងក្រោមអាចត្រូវបានប្រើប្រាស់ដើម្បីកំណត់ផ្នែកទាំងឡាយ ដែល គួរត្រូវបានលើកយកមក ពិចារណាក្នុងចំណោមផ្នែកដទៃទៀត ។

ក/អត្តសញ្ញាណកម្មពេញលេញ នៃផលិតផលនិងស្តង់ដារពាក់ព័ន្ធដែលគំរោងការត្រូវអនុវត្ត ។

ខ/ការតំរូវសំរាប់ការធ្វើតេស្ត និងអធិការកិច្ចដំបូងជា :

-ការជ្រើសរើសផ្នែកនីមួយៗ ដែលនឹងត្រូវធ្វើអធិការកិច្ច និងធ្វើតេស្ត

-និតិវិធីនៃការយកគំរូផលិតផល

-ការធ្វើតេស្តដំបូងលើផលិតផល និងវិធីធ្វើតេស្ត

-ការវាយតំលៃលើលទ្ធផលនៃការធ្វើតេស្ត

-ការធ្វើអធិការកិច្ចដំបូងចំពោះរោងចក្រ

-ការវាយតំលៃលើលទ្ធផលនៃការធ្វើអធិការកិច្ចរោងចក្រ

-ការវាយតំលៃលើប្រព័ន្ធត្រួតពិនិត្យគុណភាពរបស់រោងចក្រ ( សូមមើលសេចក្តីបន្ថែម១ នៅ ឧបសម្ព័ន្ធ ខ )

-ការវាយតំលៃលើសមត្ថកិច្ចរបស់បុគ្គលិករោងចក្រ

-ការវាយតំលៃបរិក្ខារវាស់វែង និងបរិក្ខារធ្វើតេស្តដែលបានប្រើប្រាស់ដោយផលិតកររួមទាំង ការក្រិតខ្នាតផង

-ការដាក់សញ្ញានៃផលិតផល ( ពាក់ព័ន្ធទៅនឹងសញ្ញាអនុលោម )

-បញ្ជីត្រួតពិនិត្យចំពោះការណែនាំដែលអាចធ្វើបាន ( ឧ.ចំពោះការលើកដាក់ឬការប្រើប្រាស់)

-វិញ្ញាបនប័ត្រអនុលោម ( មាតិកានៃឯកសារ ) ។

គ/ការតំរូវចំពោះនីតិវិធីនៃការពិនិត្យអង្កេតដូចជា :

-ពិនិត្យមើលការធ្វើតេស្តផលិតផល និងពិនិត្យមើលការធ្វើអធិការកិច្ចរោងចក្រ

-វាយតំលៃលើលទ្ធផលនៃការពិនិត្យមើល

-ភាពញឹកញាប់ជាអប្បបរមានៃការពិនិត្យមើលការធ្វើតេស្ត និងការធ្វើអធិការកិច្ច

ឃ/វចនាសម្ព័ន្ធអាករ និងតំលៃនៃគំរោងការ ។

ង/សេចក្តីលំអិតនៃកិច្ចសន្យាដែលត្រូវបង្កើតឡើងរវាងអង្គភាពចេញវិញ្ញាបនប័ត្រនិងអ្នកកាន់ អាជ្ញាប័ណ្ណ ។

---

ច/ ប្រសិនបើអាចអនុវត្តបាននោះ ត្រូវមានទំរង់របាយការណ៍ធ្វើតេស្តផង ។

[៨] រួមទាំងការធ្វើអធិការកិច្ចទៅលើវិក្កយបត្រផ្គត់ផ្គង់ចំណូល ដើម្បីផ្ទៀងផ្ទាត់បញ្ជាក់ថាតើវា អនុលោមតាមការតំរូវនៃកិច្ចសន្យា ឬទេ រួមទាំងការស្តុកទំនិញ ព្រមទាំងការដឹកជញ្ជូនក្នុងស្រុកនូវវត្ថុធាតុដើម ផលិតផលពាក់កណ្តាលសំរេច និងផលិតផលសំរេច ។

ឧបសម្ព័ន្ធ ខ

គំរូសណ្ឋានសំរាប់ពាក្យសុំចេញវិញ្ញាបនប័ត្រអនុលោមដោយការ

ប្រើប្រាស់វិញ្ញាបនប័ត្រ ឬសញ្ញាអនុលោម

ផ្ញើជូន ........................................................................ (អង្គភាពចេញវិញ្ញាបនប័ត្រ)

អាស័យដ្ឋាន................................................................................................

ពតិមានទាក់ទងទៅនឹងអ្នកស្នើសុំ :

| ឈ្មោះអ្នកស្នើសុំនិងអាស័យដ្ឋានការិយាល័យដែលបានចុះបញ្ជី : | លេខទូរស័ព្ទ និង ទូរសារ |
|---|---|
| ឈ្មោះ និងមុខងារ អ្នកទទួលខុសត្រូវចំពោះ<br>ប្រព័ន្ធគ្រប់គ្រងគុណភាព :<br>អាស័យដ្ឋានធ្វើអាជីវកម្ម :<br>លេខទូរស័ព្ទ និង ទូរសារ : | ទីកន្លែងផលិតផលិតផល : |

នាមកត្តានៃផលិតផល ពេលមានសំណូមពរអំពីការចេញវិញ្ញាបនប័ត្រអនុលោម :

| សេចក្តីអធិប្បាយអំពីផលិតផល :<br>(សូមមើលកូឡោនពីរដំបូងនៃសំណៅដើមអាជ្ញាប័ណ្ណ ក្នុងសេចក្តីបន្ថែម ១ ក្នុងឧបសម្ព័ន្ធ គ) | ស្តង់ដារពាក់ព័ន្ធ<br>លេខ :<br>ចំណងជើង :<br>កាលបរិច្ឆេទចេញ : | គោលការណ៍កំណត់ពាក់ព័ន្ធ<br>លេខ :<br>ចំណងជើង :<br>កាលបរិច្ឆេទចេញ : |
|---|---|---|

សេចក្តីថ្លែង [៨] ជាមួយគ្នានេះយើងសូមប្រកាសថា យើងនឹងបង់តំលៃទាំងឡាយដែលទាក់ទង នឹងការដាក់ពាក្យសុំនេះ

សេចក្តីថ្លែង : *ជាមួយគ្នានេះយើងសូមប្រកាសថា យើងនឹងសុខចិត្តទទួលយកតាមកិច្ចព្រមព្រៀងមួយក្នុងពេលកំណត់ ដែលទាក់ទងទៅនឹងការចេញវិញ្ញាបនប័ត្រផលិតផលដែលបានបញ្ជាក់ខាង លើ ចំពោះលទ្ធផលវិជ្ជមាននៃការធ្វើតេស្ត និង អធិការកិច្ចដំបូង ។

កាលបរិច្ឆេទដាក់ពាក្យសុំ

ឈ្មោះ និង មុខងារអ្នកដែលមានសិទ្ធិចុះហត្ថលេខាតំណាងអោយអ្នកស្នើសុំ :

............................................................................................(សរសេរអក្សរធំៗច្បាស់)

ហត្ថលេខា ...............................................................................................................

---

*(ឧទាហរណ៍)

សេចក្តីបន្ថែម ១ ទៅលើឧបសម្ព័ន្ធ ខ

គំរូ សំណួរដំបូងសំរាប់ការវាយតំលៃរោងចក្រ

ឧបសម្ព័ន្ធ ចំពោះសំណុំលិខិតស្នើសុំ ................................

សំណួរនេះគួរត្រូវបានបំពេញ ហើយត្រូវបានបញ្ជូនត្រឡប់មកវិញជាមួយទំរង់សំណុំលិខិតស្នើសុំ ។ គឺជាការកំណត់សំរាប់ផ្តល់ពត៌មានជាជំហានដំបូងដែលទាក់ទងទៅនឹងអ្នកស្នើសុំ និងសមត្ថភាពត្រួតពិនិត្យ គុណភាព និង បន្តត្រួតពិនិត្យផលិតផលអនុលោមតាមការគំរូវនៃយថាប្រភេទ ។

ឯកសារនេះនឹងត្រូវបានប្រើប្រាស់ដោយមន្ត្រីអធិការកិច្ចរបស់អង្គភាពចេញវិញ្ញាបនប័ត្រក្នុង កំឡុងពេលពិនិត្យរោងចក្រលើកដំបូង ឬរោងចក្រទាំងឡាយ ដែលបានពាក់ព័ន្ធជាផ្នែកនៃការធ្វើ អធិការកិច្ចដំបូង ។

ពាក្យបន្ថែមអាចបញ្ចូលក្នុងករណីចាំបាច់ ដើម្បីពង្រីកសេចក្តីថ្លែង ។

ឯកសារដាច់ដោយឡែកចំពោះគ្រប់រោងចក្រពាក់ព័ន្ធនីមួយៗ គួរត្រូវបានបំពេញ ឬត្រូវបង្ហាញ អោយច្បាស់លាស់នូវភាពខុសគ្នារវាងរោងចក្រទាំងនោះ ។

សេចក្តីថ្លែងគួរតែរៀបរាប់ពីគ្រឿងបរិក្ខារប្រើប្រាស់ដែលមាន ព្រមទាំងកាលបរិច្ឆេទបំពេញទំរង់បែបបទស្នើសុំផងដែរ ។

ពត៌មានដែលបានផ្តល់នៅក្នុងឯកសារនេះ ត្រូវចាត់ទុកជាការសំងាត់បំផុត ។

ពត៌មាននៅក្នុងកម្មវត្ថុខាងក្រោម នឹងសំរួលដល់ការប្រព្រឹត្តិទៅក្នុងការស្នើសុំ ។

គំរូកាលបរិច្ឆេទ គឺមានប្រយោជន៍សំរាប់ការវាយតំលៃ :

-តើវានឹងជាផលិតកម្ម ឬ គំរូតាងដើមនៃផលិតផល ?

-បើសិនជាគំរូតាងដើម តើការផលិតកំណត់ពេលណា ?

-តើផលិតផលត្រូវបានធ្វើតេស្តតាមស្តង់ដារឬទេ ?

-(ប្រសិនបើមានត្រូវភ្ជាប់របាយការណ៍មកជាមួយ)៖

ភាពបន្ទាន់ នៃសំណុំលិខិតស្នើសុំ ។

---

[៩] គំរូនេះ បានជ្រើសរើសចេញពីចរន្តអនុវត្តជាក់ស្តែងរបស់ជាតិ គ្មានការប៉ុនប៉ងណាមួយត្រូវបានបង្កើត ឡើង ដើម្បីអោយស្របគ្នាទៅនឹងការប្រើពាក្យ ជាមួយនឹងផ្នែកសំខាន់នៃសៀវភៅណែនាំនេះទេ ។ គំរូនេះ អាចប្រែប្រួលទៅតាមស្ថានការណ៍ជាក់ស្តែង សំរាប់គំរោងការដែលបានកើតឡើង ចំពោះមុខ ។

<u>ផ្នែកសំខាន់ៗ សំរាប់វាយតំលៃរោងចក្រ</u>

ផ្នែកទី ១ -រចនាសម្ព័ន្ធ នៃការគ្រប់គ្រងរោងចក្រ

ផ្នែកទី ២ -សំភារៈ សមាសភាគ និងសេវា

ផ្នែកទី ៣ -ផលិតកម្ម

ផ្នែកទិ ៤ -ការត្រួតពិនិត្យគុណភាព នឹង ការធ្វើតេស្ត

ផ្នែកទី ៥ -ការកត់ត្រា និងការតំកល់ឯកសារ

ផ្នែកទី ៦ -ការអនុវត្តន៍នៃការបង្ហាញពីការអនុលោម ។

ផ្នែកទី ១ ៖ រចនាសម្ព័ន្ធ នៃការគ្រប់គ្រងរោងចក្រ

១.១ នីតិវិធិ និង ឯកសារ ៖

សូមផ្តល់នូវពត៌មានតាមប្រព័ន្ធជាមូលដ្ឋាន ដូចខាងក្រោម ៖

១.១.១-តើអ្នកផលិតតាមការបញ្ជាទិញ ឬ សំរាប់ស្តុកទុក ?

១.១.២-តើអ្នកមានចេញបទបញ្ជាការងារ ឬ អ្វីដែលមានតំលៃស្មើឬទេ ?

១.១.៣-បើសិនជាមាន តើជាបទបញ្ជារួម ឬជាបទបញ្ជាសំរាប់ផ្នែកដាច់ដោយឡែកៗ ?

១.១.៤-តើផលិតផល និង សំបកវេចខ្ចប់ ឬ មួយណាក្នុងចំណោមទាំងពីរអនុវត្តតាមអត្តសញ្ញាណកម្ម នៃបទបញ្ជាការងារក្នុងផលិតកម្មដែរឬទេ ?

១.១.៥-បើមិនអនុវត្តតាម តើប្រព័ន្ធអនុវត្តដូចម្តេចដើម្បីបំបែកផលិតផលអោយចេញដាច់ពីគេ ក្នុងករណីដែលគុណភាពមានការសង្ស័យ ?

១.១.៦-សូមផ្តល់នូវពត៌មានពាក់ព័ន្ធផ្សេងទៀត អំពីប្រព័ន្ធជាមូលដ្ឋាន ។

១.២ ការត្រួតពិនិត្យគុណភាព និងបុគ្គលិកអធិការកិច្ច :

សូមផ្តល់ពត៌មានចំពោះការរៀបចំបុគ្គលិកផ្នែកត្រួតពិនិត្យគុណភាពរបស់រោងចក្រ ដូចខាងក្រោម :

១.២.១ ប្រធានផ្នែកធានាគុណភាព

១.២.២ តើធ្វើរបាយការណ៍ទៅអ្នកណា ?

១.២.៣ តើមានផ្នែកត្រួតពិនិត្យគុណភាពនៅដាច់ដោយឡែក ពីផ្នែកអធិការកិច្ច ឬទេ ?

១.២.៤ ប្រសិនបើមានសូមធ្វើការបង្ហាញ

១.២.៤.១ ប្រសិនបើប្រធានផ្នែកអធិការកិច្ច ខុសពីចំណុច ១.២.១

១.២.៤.២ ប្រសិនបើបុគ្គលិកយល់ដឹងអំពីការធ្វើតេស្ត តាមស្តង់ដារដែលពាក់ព័ន្ធ ១.២.៥ តើឆ្មាំឃ្លាំង និងអ្នកបញ្ជាម៉ាស៊ីនផលិតកម្មមានទទួលខុសត្រូវឬទេចំពោះការធ្វើអធិការកិច្ច និងការធ្វើ តេស្តលើ :

១.២.៥.១ សំភារៈ ?

១.២.៥.២ ដំណើរការផលិត ?

១.២.៥.៣ ផលិតផលសំរេច ?

១.២.៦ ប្រសិនបើមាន តើអ្នកទាំងនោះត្រូវបានតាមដានមើលដោយបុគ្គលិកត្រួតពិនិត្យគុណភាព ដែរឬទេ ?

១.២.៧ តើមានអនុវត្តការធ្វើសវនកម្មគុណភាពឬទេ តើអនុវត្តដោយអ្នកណា ?

១.២.៨ សូមផ្តល់ពត៌មានផ្សេងៗ ទៀតអំពីការរៀបចំ បុគ្គលិកត្រួតពិនិត្យគុណភាព ។

**ផ្នែកទី ២ : សំភារៈសមាសភាគ និងសេវា**

២.១ ចំណុចរាយលំអិតការទិញ និង ការធានាគុណភាពសំភារៈ :

សូមលំអិតនូវសំភារៈសំខាន់ៗដែលបានទិញ យថាប្រភេទដែលបានប្រើ និងអ្នកផ្គត់ផ្គង់សំភារៈ សំខាន់ៗដែលបានទំនាក់ទំនង ។

សូមផ្តល់ផងដែរនូវវិធីធានាគុណភាព ដែលបានប្រើនៅពេលទទួលយកសំភារៈសមាសភាគ ( ធាតុផ្សំ) ឬសេវា ដោយបង្ហាញពីសកម្មភាពនៅពេលទាត់ចោលមិនទទួលយក ។

**ផ្នែកទី ៣ : ផលិតកម្ម**

៣.១ ប្រព័ន្ធផលិតកម្ម :

សូមលំអិតនូវជំហានទីមួយៗ ក្នុងផលិតកម្មដូចជាកម្មវិធីផលិត និង ផ្នែកបន្ថែមក្នុងផែនទីដែល បង្ហាញពីដំណាក់ការមានសារៈប្រយោជន៍ ក្នុងខ្សែសង្វាក់ផលិតកម្ម ។

៣.២ ប្រព័ន្ធថែរក្សារោងចក្រ និងបរិក្ខារ :

តើប្រព័ន្ធថែរក្សាក្នុងពេលដំណើរការមានលក្ខណៈដូចម្តេច ?

**ផ្នែកទី ៤ : ការត្រួតពិនិត្យគុណភាព និង ការធ្វើតេស្ត**

៤.១ ប្រព័ន្ធត្រួតពិនិត្យ :

សូមលំអិតនូវប្រព័ន្ធត្រួតពិនិត្យគុណភាព រួមទាំងប្រព័ន្ធយកគំរូផលិតដែលបានធ្វើ និងឯកសារយោងណាមួយសំរាប់ការធ្វើតេស្តទៅតាមស្តង់ដារដែលពាក់ព័ន្ធ ។ កម្មវិធីត្រួតពិនិត្យគុណភាព ឬផ្នែកបន្ថែមដែលយោងឆ្លងទៅនឹង ផែនទីដែលបានគំរូវនៅក្នុងចំណុច ៣.១ គឺមានអត្ថប្រយោជន៍ ។

សូមភ្ជាប់មកជាមួយនូវក្បួនត្រួតពិនិត្យគុណភាព ឬសេចក្តីណែនាំអំពីការត្រួតពិនិត្យគុណភាព ដែលបានផ្តល់អោយបុគ្គលិក ។

៤.២ គ្រឿងបរិក្ខារ ឧបករណ៍សំរាប់ធ្វើតេស្ត :

សូមលំអិតនូវឧបករណ៍ធ្វើតេស្តដែលបានប្រើ ឈ្មោះអ្នកផលិត និង ឯកសារយោង និងបង្ហាញ នូវប្រព័ន្ធ និងភាពញឹកញាប់នៃការពិនិត្យតាមដាន និង វិញ្ញាបនប័ត្រត្រួតពិនិត្យប្រសិនបើមាន ។

**ផ្នែកទី ៥ : ការកត់ត្រា និង ការតំកល់ឯកសារ**

៥.១ លក្ខណៈទូទៅ :

៥.១.១ សូមបង្ហាញនូវទំរង់នៃចំណុចលំអិតមេដូចជា រូបគំនូរ កម្មវិធីផលិតផល បំណែកគំរូ ផលិតផលយោង ។ល។ ថែមទាំងបង្ហាញនូវការកត់ត្រាទូទៅដែលមាន ។

៥.១.២ សូមបង្ហាញនូវប្រព័ន្ធដែលប្រើដើម្បីកែគំរូ និង កែចំណុចលំអិត ។

៥.២ ការប្រព្រឹត្តិតាម ចំណុចលំអិត :

៥.២.១ សូមបង្ហាញកំរិតនៃកំហុស ដែលបានរកឃើញក្នុងរយៈពេល ៦ ខែកន្លងមក ។ ប្រសិនបើការធ្វើតេស្តយោងតាមស្តង់ដារពាក់ព័ន្ធបានអនុវត្តរួចហើយនោះ សូមភ្ជាប់ជាមួយនូវឯកសារថតចំ លងសង្ខេបអំពីលទ្ធផលតេស្តប្រសិនបើមាន ។

៥.២.២ សូមបញ្ជាក់កំរិតនៃការតវ៉ា ឬ ការត្អូញត្អែរដែលស្ថិត នៅក្នុងថេរៈវេលាធានា ឬក៏ស្ថិតនៅក្រោមហេតុផលផ្សេងទៀត និង សូមផ្តល់ទិន្នផលសរុបដោយអត្រាជាភាគរយ ផងដែរ ។

៥.២.៣ តើមានការធ្វើតេស្តឯករាជ្យណាមួយធ្លាប់ត្រូវបានធ្វើទៅលើផលិតផល ដោយប្រឆាំងតបទៅនឹងស្តង់ដារឬទេ ? អ្នកណាជាអ្នកធ្វើ ? សូមភ្ជាប់ច្បាប់ចំលងមកផង ប្រសិន បើមាន ។

ផ្នែកទី ៦ : ការអនុវត្តន៏នូវការបង្ហាញអំពីការអនុលោម :

៦.១ សញ្ញាអនុលោម :

សូមភ្ជាប់ជាមួយនូវភាពសំរាប់ពន្យល់ប្រសិនបើមាន និងបង្ហាញនូវរបៀបជាឧទាហរណ៍ ស្លាកពិសេសការលេចធ្លោ ។ល។ ដែលនឹងត្រូវប្រើដើម្បីបង្ហាញសញ្ញាអនុលោម ។ សូមបង្ហាញថានៅដំណាក់ការមួយណានៃផលិតកម្មដែលសញ្ញាអនុលោមនឹងត្រូវអនុវត្ត ។

៦.២ វិញ្ញាបនប័ត្រ អនុលោម :

សូមភ្ជាប់ជាមួយនូវរូបភាពសំរាប់ពន្យល់ពីរបៀបដែលបានដាក់ស្នើ និងបង្ហាញថាតើនៅ ដំណាក់ការណាមួយនៃផលិតកម្ម ឬការដឹកជញ្ជូនដែលវិញ្ញាបនប័ត្រត្រូវបានចេញអោយ ។ វិញ្ញាបនប័ត្រគំរូត្រូវធ្វើតាមឧទាហរណ៍ក្នុងសេចក្តីបន្ថែម ២ ។

សេចក្តីបន្ថែម ២ ទៅលើឧបសម្ព័ន្ធ ខ

គំរូវិញ្ញាបនប័ត្រអនុលោម .................

វិញ្ញាបនប័ត្រអនុលោម

វិញ្ញាបនប័ត្រលេខ :.................... ................(ឈ្មោះអង្គភាពចេញវិញ្ញាបនប័ត្រ).......................

តាមរយៈនេះសូមបញ្ជាក់ថា................................ ( ក្រុមហ៊ុន ) បានអនុវត្តតាមគោលការណ៍ទូទៅ និងគោលការណ៍ ជាក់លាក់ ដែលបានផ្សព្វផ្សាយលេខ .........................................................................

ស្តីពីគំរោងការចេញវិញ្ញាបនប័ត្រសំរាប់ផលិតកម្មនៃ : .................................( ឈ្មោះផលិតផល)

...............................ដូចមាន បង្ហាញក្នុងកម្មវិធីផលិតជូនភ្ជាប់មកជាមួយ ។

នៅក្នុងចំណោមគោលការណ៍ទាំងនេះ ចាំបាច់ត្រូវបញ្ជូនគំរូផលិតផលដែលមានក្នុងតារាងកម្មវិធីផលិតផលដើម្បីធ្វើការពិនិត្យ និងធ្វើតេស្តដោយអង្គភាពចេញវិញ្ញាបនប័ត្រទៅតាមស្តង់ដារដែល បានយោងនៅក្នុងតារាងកម្មវិធីផលិត ។ ជាបន្ថែមទៀត គំរោងការតំរូវអោយក្រុមហ៊ុន :

ក/ អនុញ្ញាតអោយរោងចក្រទាំងឡាយរបស់ខ្លួនមានទីតាំងនៅ.........................................................

ត្រូវបានទទួលការធ្វើអធិការកិច្ចជាដំណាក់កាលតាមខួបដោយ អង្គភាពចេញវិញ្ញាបនប័ត្រ និង

ខ/ អនុញ្ញាតអោយជ្រើសរើសយកគំរូផលិតផល ដែលមាននៅក្នុងតារាងកម្មវិធី ផលិតនៅទី កន្លែងផលិតកម្ម ឬ នៅលើទីផ្សារដោយឯករាជ្យដើម្បីធ្វើតេស្ត និងពិនិត្យមើលដើម្បីធានាថា ការបន្តការអនុលោមកំពុងត្រូវបានយកចិត្តទុកដាក់ធ្វើ ។

វិញ្ញាបនប័ត្រនេះផ្តល់ដោយគណៈកម្មាធិការចេញវិញ្ញាបនប័ត្រនៃ..................................*

តាមឯកសារលេខ .................. ចុះថ្ងៃទី ខែ ឆ្នាំ

តាមរយៈនេះ ក្រុមហ៊ុន ស្រុះស្រួលគ្នាជាមួយអង្គភាពចេញវិញ្ញាបនប័ត្រ ដើម្បីសង្កេតមើល និង ប្រតិបត្តិអោយបានត្រឹមត្រូវទៅតាមការតំរូវរបស់ស្តង់ដារទាំងឡាយ ដែលមាននៅក្នុងតារាងកម្មវិធីគោលការណ៍ទូទៅ និងគោលការណ៍ជាក់លាក់ និងទៅតាមបទបញ្ជានានាសំរាប់គំរោងការ ដែលអង្គភាពចេញវិញ្ញា - បនប័ត្រអាចបង្កើតឡើង ។

បានចុះហត្ថលេខាដោយអង្គភាពចេញវិញ្ញាបនប័ត្រ :

........................................................................ ........................(នាយក)....................

កាលបរិច្ឆេទ ថ្ងៃទី ខែ ឆ្នាំ

បានចុះហត្ថលេខាដោយតំណាងក្រុមហ៊ុន :

..........................................................................................................................

កាលបរិច្ឆេទ ថ្ងៃទី ខែ ឆ្នាំ

---

*ឈ្មោះអង្គភាពចេញវិញ្ញាបនប័ត្រ

(<u>សំគាល់</u> : គោលការណ៍នៃប្រព័ន្ធចេញវិញ្ញាបនប័ត្រដោយភាគីទីបី អាចបញ្ជាក់ពតិមានបន្ថែមផងដែរ ដើម្បីបំពេញល័ក្ខខ័ណ្ឌ ។)

**ឧបសម្ព័ន្ធ គ**

គំរូកិច្ចព្រមព្រៀងអាជ្ញាប័ណ្ណសំរាប់ការប្រើប្រាស់វិញ្ញាបនប័ត្រ ឬ សញ្ញាអនុលោម

អង្គភាពចេញវិញ្ញាបនប័ត្រ ដែលមានការិយាល័យដែលបានចុះបញ្ជីនៅ ............................ ចាប់ពីពេលនេះតទៅ ត្រូវបានយោងជាអង្គភាពចេញវិញ្ញាបនប័ត្រ នឹងត្រូវបានជាតំណាងក្នុងកិច្ចការ នេះដោយឈ្មោះ............ឋានៈ............ ដើម្បីផ្តល់អាជ្ញាប័ណ្ណដល់ឈ្មោះ............. មានការិយាល័យដែលបានចុះបញ្ជីនៅ.................... ចាប់ពីពេលនេះតទៅត្រូវបានយោងជាអ្នកកាន់អាជ្ញាប័ណ្ណហើយ អាជ្ញាប័ណ្ណសំរាប់បញ្ជាក់ផលិតផលដែលគ្របដណ្តប់ដោយអាជ្ញាប័ណ្ណដែលភ្ជាប់មកជាមួយៈ ដូចដែល បានអនុម័តដោយ អង្គភាពចេញវិញ្ញាបនប័ត្រចំពោះផលិតផលប្រភេទនេះដែលបានបញ្ជាក់នៅក្នុងជួរទី១ នៃអាជ្ញាប័ណ្ណដែលមានតំលៃ ដែលបានត្រួតពិនិត្យដោយអ្នកកាន់អាជ្ញាប័ណ្ណ ដោយអនុលោមទៅតាមស្តង់ដារដែលបានយោងនៅក្នុងជួរទី ២

និងគោលការណ៍ជាក់លាក់ដែលបានយោងនៅក្នុងជួរទី៣ នៃអាជ្ញាប័ណ្ណដែលមានតំលៃ និង តាមល័ក្ខខ័ណ្ឌនៃកិច្ចព្រមព្រៀងទូទៅដូចខាងក្រោម :

ប្រការ ១ : បទបញ្ញាចំពោះការចេញវិញ្ញាបនប័ត្រនិង ការធ្វើអធិការកិច្ច

ការចែងជាល័ក្ខខ័ណ្ឌនៃគោលការណ៍ទូទៅចំពោះប្រព័ន្ធចេញវិញ្ញាបនប័ត្រ អនុវត្តសំរាប់កិច្ចព្រមព្រៀងនេះក៏ដូចជាសំរាប់ស្តង់ដារ និង គោលការណ៍ជាក់លាក់ ដែលបានបញ្ជាក់នៅក្នុងអាជ្ញាប័ណ្ណ ភ្ជាប់មកជាមួយ ។

ប្រការ ២ : សិទ្ធិ និង កាតព្វកិច្ច

២.១ អ្នកកាន់អាជ្ញាប័ណ្ណយល់ព្រមថា ផលិតផលដែលបានទទួលវិញ្ញាបនប័ត្រដែលបានផលិត និងផ្គត់ផ្គង់ដោយខ្លួនឯង ដូចបានបញ្ជាក់ក្នុងអាជ្ញាប័ណ្ណដែលបានផ្អែកលើ និងដែលបានភ្ជាប់ជាមួយកិច្ចព្រមព្រៀងនេះនឹងអនុលោមទៅតាមការត័រូវដែលមានចែងក្នុងស្តង់ដារគោលការណ៍ទូទៅ និងគោលការណ៍ជាក់លាក់ដែលបានបញ្ជាក់នៅក្នុងអាជ្ញាប័ណ្ណ ។ ស្របទៅតាមនេះ អង្គភាពចេញវិញ្ញាបនប័ត្រផ្តល់សិទ្ធិអោយអ្នកកាន់អាជ្ញាប័ណ្ណបញ្ជាក់អំពីផលិតផលដែលឋិតក្រោមអាជ្ញាប័ណ្ណ ដូចបានចែងក្នុងគោលការណ៍ជាក់លាក់នៃគំរោងការ ។

២.២ អ្នកកាន់អាជ្ញាប័ណ្ណយល់ព្រម នឹងមិនរារាំងតំណាងអង្គភាពចេញវិញ្ញាបនប័ត្រ នៅពេល ចូលធ្វើអធិការកិច្ចក្នុងបរិវេណរោងចក្រដែលជាប់ទាក់ទង និងស្ថិតក្រោមសុពលភាពអាជ្ញាប័ណ្ណនៅ ក្នុងពេលម៉ោងធ្វើការធម្មតារបស់រោងចក្រដោយមិនបាច់ជូនដំណឹងជាមុនឡើយ ។

២.៣ អ្នកកាន់អាជ្ញាប័ណ្ណយល់ព្រមថា ផលិតផលណាដែលមានអាជ្ញាប័ណ្ណ នឹងត្រូវបានផលិត អោយដូចទៅនឹងចំណុចលំអិតទាំងឡាយនៃគំរូផលិតផល ដែលអង្គភាពចេញវិញ្ញាបនប័ត្របានទទួល ស្គាល់ដោយការធ្វើតេស្តដំបូងថា បានធ្វើតាមស្តង់ដារ ។

ប្រការ ៣ : ការពិនិត្យអង្កេត

៣.១ យោងទៅតាមល័ក្ខខ័ណ្ឌដែលចែងនៅក្នុងគោលការណ៍ទូទៅចំពោះប្រព័ន្ធចេញវិញ្ញាបនប័ត្រ និងគោលការណ៍ជាក់លាក់ចំពោះគំរោងការដែលបានបញ្ជាក់ក្នុងអាជ្ញាប័ណ្ណ អង្គភាពចេញវិញ្ញាបនប័ត្រ អនុវត្តនូវការពិនិត្យអង្កេតជាបន្តបន្ទាប់ លើការប្រតិបត្តិតាមកាតព្វកិច្ចរបស់អ្នកកាន់អាជ្ញាប័ណ្ណ ។

៣.២ ការពិនិត្យអង្កេតនេះអនុវត្តដោយមន្ត្រីរបស់អង្គភាពចេញវិញ្ញាបនប័ត្រ ឬមន្ត្រីរបស់ភ្នាក់ងារដែលជាតំណាងរបស់អង្គភាពចេញវិញ្ញាបនប័ត្រ ។

ប្រការ ៤ : ពត៌មានអំពីការកែប្រែក្នុងផលិតកម្ម

អ្នកកាន់អាជ្ញាប័ណ្ណត្រូវជូនដំណឹងដល់ អង្គភាពចេញវិញ្ញាបនប័ត្រ ចំពោះរាល់គំរោងកែប្រែណាមួយលើផលិតផលខ្សែសង្វាក់ផលិតកម្ម ឬប្រព័ន្ធគ្រប់គ្រងគុណភាព ។

ប្រការ ៥ : ការតវ៉ា

តាមសំណូមពររបស់អង្គភាពចេញវិញ្ញាបនប័ត្រ អ្នកកាន់អាជ្ញាប័ណ្ណត្រូវរក្សាទុកនូវការកត់ត្រា ទាំឡាយ និងត្រូវរាយការណ៍ទៅអង្គភាពចេញវិញ្ញាបនប័ត្រនូវការតវ៉ាលើចរិតលក្ខណៈទាំង ឡាយនៃផលិតផលដែលស្ថិតក្រោមសុពលភាពនៃអាជ្ញាប័ណ្ណ ។

ប្រការ ៦ : ការផ្សព្វផ្សាយជាសាធារណៈ

៦.១ អ្នកកាន់អាជ្ញាប័ណ្ណមានសិទ្ធិផ្សព្វផ្សាយថា ខ្លួនត្រូវបានអនុញ្ញាតអោយបញ្ជាក់អំពីផលិតផល ដែលមានអាជ្ញាប័ណ្ណ ។

៦.២ ក្នុងចំណោមវិធីសាស្ត្រផ្សព្វផ្សាយដទៃទៀត អង្គភាពចេញវិញ្ញាបនប័ត្រអោយធ្វើការ ផ្សព្វផ្សាយជាសាធារណៈ ចំពោះការអនុញ្ញាតអោយប្រតិបត្តិតាមស្តង់ដារនៅក្នុងទស្សនាវដ្តីសាធារណៈ ។ល។ នឹងចំពោះការលុបចោលកិច្ចព្រមព្រៀងជាមួយអ្នកកាន់អាជ្ញាប័ណ្ណតាម ការសមរម្យ ។

ប្រការ ៧ : ការរក្សាការសំងាត់

អង្គភាពចេញវិញ្ញាបនប័ត្រ ជាអ្នកទទួលខុសត្រូវលើការតាមដានអោយបានថា ការរក្សាការ សំងាត់ត្រូវបានរក្សាដោយមន្ត្រី ឬបុគ្គលិករបស់ខ្លួនពាក់ព័ន្ធទៅនឹងពត៌មានសំងាត់ទាំងអស់ដែលគេ មានឱកាសបានដឹងទៅតាមលទ្ធផលនៃការជួបទាក់ទងជាមួយអ្នកកាន់អាជ្ញាប័ណ្ណ ។

ប្រការ ៨ : ការបង់ប្រាក់

អ្នកកាន់អាជ្ញាប័ណ្ណត្រូវបង់ប្រាក់សំរាប់ការចំណាយទាំងអស់ ដែលពាក់ព័ន្ធទៅនឹងការពិនិត្យ អង្កេតរួមមានការធ្វើតេស្ត អធិការកិច្ច និងការចំណាយលើកិច្ចការរដ្ឋបាល ។

ប្រការ ៩ : កំឡុងពេលកិច្ចព្រមព្រៀង

កិច្ចព្រមព្រៀងនេះចូលជាធរមានចាប់ពីថ្ងៃទី ............ ខែ ............... ឆ្នាំ ............... ហើយមានប្រសិទ្ធភាពដល់ថ្ងៃទី ............... ខែ ................. ឆ្នាំ ................... បើគ្មាន ការដករហូតដោយមានមូលហេតុច្បាស់លាស់ ឬបើគ្មានការលុបចោលរបស់ភាគីណាមួយ ដោយធ្វើ ការជូនដំណឹងជាលិខិតដល់ភាគីឯទៀតទេ ។

ប្រការ ១០ : ការដកហូត-ការលុបចោលអាជ្ញាប័ណ្ណ

ប្រសិនបើការដកហូតការលុបចោលអាជ្ញាប័ណ្ណឈានចូលដល់ចំណុចត្រូវពិភាក្សាដោយមូល ហេតុណាមួយកើតឡើងជាយថាហេតុ ពេលវេលាចាំបាច់នៃការជូនដំណឹងពីមុនចំពោះការដកហូត ការលុបចោល នឹងអាចផ្លាស់ប្តូរ ។

យោងទៅតាមហេតុផលលើការដកហូត-ការលុបចោល ការកំណត់ពេលវេលាតាមលំដាប់ ក្នុងការជូនដំណឹងនឹងត្រូវអនុវត្តដូចខាងក្រោម :

ស្ថានភាពតំរូវអោយបញ្ជូនលិខិតជូនដំណឹងដែល ចំនួនថ្ងៃនៃការជូនដំណឹងមុនចំពោះការអាច វៀបចំឆ្ពោះទៅកាន់ការដកហូត ឬការលុបចោល ដកហូត ឬការលុបចោល

-គោលបំណងរបស់ផលិតករក្នុងការលុបចោល : នឹងត្រូវបញ្ជាក់ដោយអង្គភាពចេញវិញ្ញាបនប័ត្រ

-អង្គភាពចេញវិញ្ញាបនប័ត្រ កំណត់ថាផលិត

ផលនាំអោយ មានគ្រោះថ្នាក់ : គ្មាន

-ការរំលោភលើស្តង់ដារ កំពុងស្ថិតនៅជាធរមាន

ចំពោះមូលហេតុផ្សេងៗ ក្រៅពីសុវត្ថិភាព អតិបរមា ៦០ ថ្ងៃ

-គ្មានការបង់ប្រាក់តាមប្រការ ៨ ទៅអោយ

អង្គភាពចេញវិញ្ញាបនប័ត្រ : អតិបរមា ៣០ ថ្ងៃ

-ការខកខានក្នុងការបំពេញតាមប្រការដទៃទៀត

នៃកិច្ចព្រមព្រៀងអាជ្ញាប័ណ្ណ : អតិបរមា ៦០ ថ្ងៃ

-ការប្រតិបត្តិចាំបាច់តាមការតំរូវថ្មីៗ ដែលទាក់ទង

នឹងការកែសំរួលស្តង់ដារ : ដែលអាចពិភាក្សាគ្នា

ការណែនាំស្តីអំពីការលុបចោល ត្រូវបានបញ្ជូនតាមរយៈសំបុត្រអនុសិដ្ឋ (ឬមធ្យោបាយផ្សេងៗ ដែលមានតំលៃស្មើ ) ទៅភាគីម្ខាងទៀតដោយថ្លែងអំពីមូលហេតុ និង កាលបរិច្ឆេទបញ្ចប់នៃកិច្ចព្រមព្រៀង ។

ប្រការ១១ : ការកែប្រែលើការតំរូវអំពីផលិតផល

១១.១ ប្រសិនបើការតំរូវអនុវត្តចំពោះផលិតផលស្ថិតនៅក្រោមកិច្ចព្រមព្រៀងត្រូវបានកែប្រែនោះ អង្គភាពចេញវិញ្ញាបនប័ត្រត្រូវជូនដំណឹងដល់អ្នកកាន់អាជ្ញាប័ណ្ណជាបន្ទាន់ តាមរយៈសំបុត្រ អនុសិដ្ឋ ( ឬមធ្យោបាយផ្សេងដែលមានតំលៃស្មើ ) ដោយថ្លែងអំពីកាលបរិច្ឆេទនៃការតំរូវ ដែលបាន កែប្រែរួចដែលនឹងចូលជាធរមាន

ហើយណែនាំដល់អ្នកកាន់អាជ្ញាប័ណ្ណនូវសេចក្តីត្រូវ ការណាមួយ សំរាប់ធ្វើការពិនិត្យបន្ថែមលើផលិតផល ដែលជាកម្មវត្ថុនៃកិច្ចព្រមព្រៀងនេះ ។

១១.២ នៅក្នុងកំឡុងពេលកំណត់មួយ បន្ទាប់ពីបានទទួលការណែនាំដែលបានពណ៌នាក្នុងកថាខ័ណ្ឌ ១១.១ អ្នកកាន់អាជ្ញាប័ណ្ណត្រូវជូនដំណឹងដល់អង្គភាពចេញវិញ្ញាបនប័ត្រ ដោយសំបុត្រអនុសិដ្ឋ (ឬមធ្យោបាយផ្សេង ដែលមានតំលៃស្មើ) ថាតើគាត់បានត្រៀមទទួលយកការកែប្រែដែរឬទេ ។ ប្រសិនបើអ្នកកាន់អាជ្ញាប័ណ្ណ ផ្តល់នូវការបញ្ជាក់យល់ព្រម នៅក្នុងកំឡុងពេលកំណត់មួយលើការយល់ព្រម របស់គាត់ក្នុងការកែប្រែ ហើយ បានផ្តល់នូវលទ្ធផលអំពីការពិនិត្យបន្ថែមណា មួយដែលសមរម្យនេះ អាជ្ញាប័ណ្ណបន្ថែមមួយនឹងត្រូវបានចេញ អោយ ឬការកែប្រែដទៃទៀត នៃការកត់ត្រារបស់អង្គភាព ចេញវិញ្ញាបនប័ត្រ ។

១១.៣ ប្រសិនបើអ្នកកាន់អាជ្ញាប័ណ្ណជូនដំណឹងដល់អង្គភាពចេញវិញ្ញាបនប័ត្រ គាត់ពុំត្រូវបានត្រៀមរៀបចំ ដើម្បីទទួលយកការកែប្រែនៅក្នុងកំឡុងពេលបានកំណត់ យោងតាមកថាខ័ណ្ឌ ១១.២ ឬប្រសិនបើគាត់ បណ្តោយអោយពេលវេលានៃការយល់ព្រមកន្លងផុតទៅ ឬប្រសិនបើលទ្ធផលនៃការ ពិនិត្យបន្ថែមពុំសមរម្យ នោះ អាជ្ញាប័ណ្ណដែលគ្រប់ដណ្តប់លើផលិតផលណាមួយនោះនឹងត្រូវអស់ សុពលភាពចាប់ពីថ្ងៃដែលបានដាក់ អោយអនុវត្តលើចំណុចលំអិតទាំងឡាយដែលបានកែប្រែ ។ ប្រសិនបើមិនដូច្នេះទេ លុះត្រាតែត្រូវបានសំរេច ដោយអង្គភាពចេញវិញ្ញាបនប័ត្រ ។

ប្រការ១២ : ភាពទទួលខុសត្រូវខាងផ្លូវច្បាប់

ភាពទទួលខុសត្រូវខាងផ្លូវច្បាប់ នឹងត្រូវបញ្ជាក់ដោយភ្ជាប់ទៅនឹងប្រព័ន្ធស្របច្បាប់ដែល ពាក់ព័ន្ធ ។

ប្រការ១៣ : បណ្តឹងតវ៉ា-វិវាទ

រាល់វិវាទទាំងឡាយដែលអាចកើតឡើងទាក់ទិនទៅនឹងកិច្ចព្រមព្រៀង គឺត្រូវផ្សះផ្សារដោយយោងទៅតាម នីតិវិធីនៃការប្តឹងតវ៉ារបស់អង្គភាពចេញវិញ្ញាបនប័ត្រ ។

បានធ្វើឡើងជាពីរច្បាប់ និង បានចុះហត្ថលេខាដោយអ្នកតំណាងស្របច្បាប់របស់អង្គភាពចេញ វិញ្ញាបនប័ត្រ និងអ្នកស្នើសុំ ។

| | |
|---|---|
| តំណាង អង្គភាពចេញវិញ្ញាបនប័ត្រ | តំណាងអ្នកស្នើសុំ |
| កាលបរិច្ឆេទ :........................... | កាលបរិច្ឆេទ :............................. |
| ហត្ថលេខា ( មុខងារ ) | ហត្ថលេខា ( មុខងារ ) |

សេចក្តីបន្ថែម ១ នៅលើឧបសម្ព័ន្ធ គ

គំរូនៃទំរង់អាជ្ញាប័ណ្ណ សំរាប់ការប្រើប្រាស់វិញ្ញាបនប័ត្រ ឬសញ្ញាអនុលោម

អណ្ណសារដ្ឋានជាតិ
ថ្ងៃទី............ខែ............ឆ្នាំ............

( គំរូពិស្តារនៃវិញ្ញាបនប័ត្រ ឬសញ្ញាអនុលោមត្រូវភ្ជាប់ជាមួយទំរង់នេះ ឬអាចដាក់ចូលជាមួយ ក្នុ )

អាជ្ញាប័ណ្ណលេខ:..............................ចំពោះកិច្ចព្រមព្រៀងលេខ:..............................បានចេញដោយ.

..........................................................................( អង្គភាពចេញវិញ្ញាបនប័ត្រ)

ជូនចំពោះ..........................................................................................( អ្នកកាន់អាជ្ញាប័ណ្ណ)

..........................................................................................................................................

..........................................................................................................................................

| ឈ្មោះផលិតផលដែលបានទទួលអាជ្ញាប័ណ្ណ | ប្រភេទ/លេខ:......ឬវត្ថុផ្សេងៗដែលពិពណ៌នា | ស្តង់ដារ | គោលការណ៍ដាក់លាក់ |
|---|---|---|---|
| | | | |

កាលបរិច្ឆេទចេញអាជ្ញាប័ណ្ណ:..........................................................................................

បានចុះហត្ថលេខាសំរាប់តំណាងអង្គភាពចេញវិញ្ញាបនប័ត្រ:..............................................................

ហត្ថលេខា ( មុខងារ )